សំរាប់លក់

ក្រសួងអប់រំ យុវជន និងកីឡា

# សីលធម៌-ពលរដ្ឋវិជ្ជា

## កំណែ ១២










គ្រឹះស្ថានបោះពុម្ពនិងចែកផ្សាយ

## ជំពូកទី១ តម្លៃមនុស្ស

## មេរៀនទី១ បញ្ញា

### សំណួរ

1. ចូរឱ្យនិយមន័យបញ្ញា។
2. ចូរប្រៀបធៀបបញ្ញា និងសភាវគតិ។
3. ចូរប្រៀបធៀបបញ្ញាមនុស្ស និងសត្វ។
4. ដើម្បីរស់បញ្ញាមនុស្សតើគេធ្វើដូចម្តេច?

### ចម្លើយ

1. និយមន័យបញ្ញាតាមអ្នកប្រាជ្ញមួយចំនួនដូចខាងក្រោម៖

- លោក ក្លាប៉ារ៉ែត ថាបញ្ញាគឺជាសម្បទាដែលអាចសម្រប ទៅនឹងស្ថានការណ៍ថ្មីៗ។
- លោក ដឺឡាក្រ័រ យល់ថា បញ្ញាជាសិល្បៈ សម្រាប់បង្កើតប្រព័ន្ធអរូបីកម្មនៅចំពោះមុខ ស្ថានភាពមួយ ហើយបញ្ចូលប្រព័ន្ធអរូបីទាំង នោះទៅក្នុងស្ថានភាពរូបីមួយ។
- លោក ហាតម៉ាន់ យល់ថាបញ្ញា ជាអនុគមន៍សម្របមធ្យោបាយនិងគោលដៅ។
- លោក ប៊ែរសុនយល់ថា បញ្ញាជាសតិសម្រាប់កសាងគ្រឿងប្រដាប់ផ្សេងៗ។

- លោក ដេកាត និងរ៉ូសូ ទេយល់ថា បញ្ញាជាឧបករណ៍សកលសម្រាប់ដោះស្រាយបញ្ហាថ្មីៗ ដែលស្របទៅនឹងលក្ខខណ្ឌនៃជីវិត។
- លោក កូល័រ យល់ថា បញ្ញាជាអត្តនុវញ្ញាណភ្លាមៗ។
- តាមទ្រឹស្តីព្រះពុទ្ធសាសនាបញ្ញាជាប្រទីបសម្រាប់បំភ្លឺសត្វលោកទៅរកសេចក្តីសុខ។ អ្នកមានបញ្ញាគឺអ្នកស្គាល់ហេតុនៃទុក្ខនិង ស្គាល់ផ្លូវរំលត់ទុក្ខ។

2. ប្រៀបធៀបបញ្ញា និងសភាវគតិគឺបញ្ញាមានលក្ខណៈល្អប្រសើរជាងសភាវគតិព្រោះបញ្ញា ធ្វើអោយមនុស្សចេះគិតពិចារណា បង្កើតអ្វីដែលថ្មីៗ និងសម្រាប់ដោះស្រាយបញ្ហាផ្សេងៗ ចំណែកឯសភាវគតិគឺជាការប្រព្រឹត្តដដែលៗពីកំណើតរបស់សត្វ តាមទម្លាប់ហើយមិនរីក ចម្រើនទេ។
3. ប្រៀបធៀបបញ្ញាមនុស្ស និងសត្វ គឺបញ្ញា មនុស្ស គ្មានព្រំដែននិងមានសម្បទាក្នុងការបង្កើតឧបករណ៍ ទំនើបៗតតឈប់ឈរ ។ រីបញ្ញាសត្វជាបញ្ញាបែប អត្តនុវញ្ញាណនិងរូបីមានព្រំដែន និងគ្មានសម្បទា ក្នុងការបង្កើតថ្មី។
4. ដើម្បីវាស់បញ្ញាមនុស្ស អ្នកប្រាជ្ញឈ្មោះ ប៊ីនេ និងស៊ីម៉ុងបានបង្កើតវិធីវាស់បញ្ញា"តេស"

$$\text{តាមរូបមន្ត} = \frac{\text{អាយុបញ្ញា}}{\text{អាយុពិត}}$$

លោកទាំងពីរបានបង្ហាញលទ្ធផលដូចតទៅ

- បើលទ្ធផល = 1 កំណត់ថាជាមនុស្សធម្មតា
- បើលទ្ធផល >1 កំណត់ថាជាមនុស្សឈ្លាសវៃ
- បើលទ្ធផល <1 កំណត់ថាជាមនុស្សបញ្ញាអន់
- បើលទ្ធផល < 0.7 កំណត់ថាជាមនុស្សខ្សោយបញ្ញា
- បើលទ្ធផល < 0.5 កំណត់ថាជាមនុស្សល្ងង់
- បើលទ្ធផល < 0.2 កំណត់ថាជាមនុស្សល្ងីល្ងើ។

---

## មេរៀនទី២ ការបង្កើតថ្មី

### សំណួរ

1. ចូរឱ្យនិយមន័យនៃការបង្កើតថ្មី? របកគំហើញ?
2. ចូររៀបរាប់ពីដើមកំណើតនៃការបង្កើតថ្មី?
3. ចូរបង្ហាញពីកត្តាដែលនាំឱ្យមានការបង្កើតថ្មី?
4. តើនៅក្នុងការបង្កើតថ្មីគេតែងជួបឧបសគ្គអ្វីខ្លះ?

### ចម្លើយ

1. **ការបង្កើតថ្មី** ជាផលិតផលសំយោគនៃរូបភាពថ្មីជាពិសេស ជាការផលិតអ្វីមួយថ្មី ដោយផ្អែកលើមធ្យោបាយចាស់ៗ ដើម្បីសម្រេចគោលដៅមួយថ្មីដែលមិនមានពីមុនមក។

❖ **របកគំហើញ** គឺជាអ្វីដែលមានស្រាប់រួចហើយត្រូវបានគេរកឃើញ។

2. ដើមកំណើតនៃការបង្កើតថ្មីមាន៖

- ឥន្ទ្រីយារម្មណ៍

- ➢ ដំណាក់រូបវិទ្យា
- ➢ ដំណាក់សរីរវិទ្យា
- ➢ ដំណាក់ចិត្តវិទ្យា

- រូបភាព
- រូបារម្មណ៍ ឬមនោគតិ
  - ➢ មនោគតិរំលើកឡើងវិញ
  - ➢ មនោគតិបង្កើត។

3. កត្តាដែលនាំឱ្យមានការបង្កើតថ្មីគឺ៖

- កត្តាថៃជន្យៈ ជាកត្តាដែលមិនអាចទាយទុក។
- កត្តាភាគនៃទេពកោសល្យៈ ជានិស្ស័យពីកំណើតរបស់មនុស្ស
- ចំណេះពីរបកគំហើញចុងក្រោយទាំងឡាយ របស់វិទ្យាសាស្ត្រៈ ជាការប្រើប្រាស់ឧបករណ៍ទំនើបដើម្បី ច្នៃប្រឌិត ឬបង្កើតអ្វីមួយ។
- ទំនោរផ្នែកជីវវិទ្យាៈបង្កើតថ្មីដើម្បីសម្របខ្លួននឹងមជ្ឈដ្ឋាន។
- តម្រូវការចាំបាច់របស់សម្ហភាពៈ សេចក្តីត្រូវការមនុស្សជាកម្លាំងជំរុញឱ្យអ្នកបង្កើតថ្មី ខិតខំប្រឹងប្រែង។

4. នៅក្នុងការបង្កើតថ្មីគេតែងជួបឧបសគ្គដូចជា៖

- ខ្វះដើមទុន
- ខ្វះធនធានមនុស្ស
- ខ្វះសម្ភារៈ បច្ចេកទេស

## មេរៀនទី៣ ឈ្មៀចទូទៅនៃគំនិត

### សំណួរ

I. ចូរគូសសញ្ញា✓ក្នុងប្រអប់ដែលមានចម្លើយ ត្រូវតែមួយគត់ ៖

1. ចំណេះដឹងដែលគ្មានលំដាប់ គ្មានទំនាក់ទំនងគ្មានការពិចារណាហៅថា

☑ក.សភាវគតិ ☐ខ.អព្ភន្តរញ្ញាណ

☐គ.ទម្លាប់ ☐ឃ.ពុទ្ធិសាមញ្ញ

2. ពុទ្ធិដំបូងកើតពីចំណាប់ផ្ទាល់ រហ័សគ្មានការពិចារណាគឺ

☑ក.ពុទ្ធិសាមញ្ញ ☐ខ.ពុទ្ធិស្បង់ ☐គ.អព្ភន្តរញ្ញាណ

3. ខ្ញុំដឹងថាផ្លែឈើទុំដោយសារខ្ញុំវិនិច្ឆ័យ តាមបំណាកស្រាយនៃញាណនេះគឺជា

☐ក.អព្ភន្តរញ្ញាណចិត្តវិទ្យា ☐ខ.អព្ភន្តរញ្ញាណឥន្ទ្រីយ៍

☐គ.អព្ភន្តរញ្ញាណបញ្ញា

☑ ឃ.អព្ភន្តរញ្ញាណអស្តិរូបវិជ្ជា

II. ចូរបំពេញឃ្លាខាងក្រោមឱ្យបានត្រឹមត្រូវ

1. ខ្ញុំដឹងថ្ងៃ ខែ ឆ្នាំកំណើតដោយសារម្តាយខ្ញុំ ប្រាប់នេះជាពុទ្ធិសាមញ្ញ។

2. ខ្ញុំដឹងថា ទឹកជ្រុំឡើងព័ះរុកស៊ីសែន និងអ៊ីដ្រូ សែន នេះជាពុទ្ធិសង្ស័យ។

3. ក្នុងករណីមានជម្ងឺសរសៃប្រសាទ វេជ្ជបណ្ឌិតធ្វើការវះកាត់សរសៃប្រសាទណាមួយ ដើម្បីព្យាបាលប្រភេទជម្ងឺនេះ នេះជាពុទ្ធិឧស្សនវិជ្ជា

4. សំយោគក្នុងគំនិតដែលផ្គុំនូវគោលគំនិតធំៗ ដើម្បីធ្វើសន្ទរកថាហៅថាសំយោគបញ្ញត្តិ។

III. ចូរផ្គូផ្គងផ្នែកA និងB ឱ្យបានត្រឹមត្រូវ

| A | B | ចម្លើយ |
|---|---|---|
| 1. អនុមានញែក<br>2. អនុមានរួម<br>3. អនុមានញែក គណិតវិទ្យា<br>4. អនុមានរួម សាររូប | ក.ចេញពីភាពដោយឡែកទៅរកភាពរួម<br>ខ.ចេញពីភាពរួមទៅរកភាពដោយឡែក<br>គ.វិពាកជាសំណើមួយកើតពីគោលការណ៍<br>ឃ.ចេញពីគោលការណ៍ ពិសេសៗជាច្រើនដែលគេស្គាល់រួចហើយ<br>ង.ធ្វើដំណើរពីពិសេសៗទៅភាពពិសេសៗ | 1. →ខ<br>2. →ក<br>3. →គ<br>4. →ឃ |

IV. សំណួរត្រិះរិះ

1. ដូចម្តេចហៅថា វិចារ? វិចារចែកជាប៉ុន្មាន? គឺអ្វីខ្លះ?
2. អំពើទាំងបីនៃគំនិតមានអ្វីខ្លះ? ចូររៀបរាប់។
3. ដូចម្តេចហៅថា អនុមានញែក? អនុមានរួម? ចូរបង្ហាញពីទំនាក់ទំនងនៃអនុមានញែក និង អនុមានរួម។
4. ដូចម្តេចហៅថា វិភាគ? សំយោគ?
5. ដូចម្តេចហៅថាអព្ភន្តរញ្ញាណ?អព្ភន្តរញ្ញាណ ចែកចេញជាអ្វីខ្លះ? ចូររៀបរាប់។

<u>ចម្លើយ</u>

1. ហៅថា វិចារជាគំណជាប់តគ្នាច់នៃគំនិតជាច្រើនដើម្បីឆ្ពោះទៅរកសេចក្តីសន្និដ្ឋានមួយ។

❖ វិចារចែកជា២ប្រភេទដូចខាងក្រោម៖

➢ វិចារត្រឹមត្រូវៈ គឺការរៀបចំគំនិតឱ្យមានទំនាក់ទំនងគ្នាពោលគឺគំនិតមួយ មិនត្រូវប្រឆាំងគំនិតមួយទៀតទេ។

➢ វិចារមិនត្រឹមត្រូវៈ គឺគំនិតប្រឆាំងគ្នា មិនបាននាំដល់ការសន្និដ្ឋានណាមួយ។

2. អំពើទាំងបីនៃគំនិតមាន បញ្ញត្តិ ការវិនិច្ឆ័យ និង វិចារ។
3. អនុមានញែក គឺជាវិចារមួយបែបដែលញែក សេចក្តីសន្និដ្ឋានចេញពីគោលការណ៍ទូទៅ ដើម្បីរកវិបាក ឬចេញពីភាពរួមទៅរកភាពដោយឡែក។

❖ អនុមានរួមជាវិចារដែលចេញពីគោលការណ៍ពិសេសៗជាច្រើនដើម្បីបង្រួមឱ្យបានជាច្បាប់ ទូទៅមួយ។

**ទំនាក់ទំនងនៃអនុមានញែកនិងអនុមានរួមៈ គឺអនុមានរួមផ្ត** ល់ឬសគល់ឱ្យអនុមានញែក ព្រោះ អនុមានរួមស្វែងរក ច្បាប់ទូទៅក្នុងវិទ្យាសាស្ត្រ ពិសោធន៍ និងរកគោលការណ៍ ឱ្យគណិតវិទ្យា។ អនុមានញែកមានលក្ខណៈ ត្រឹមត្រូវល្អិត ល្អន់ជាអ្នកដឹកនាំអនុមានរួម។

4. **វិភាគ** គឺជាការបំបែកអង្គធាតុមួយឱ្យទៅជាធាតុផ្សំ ផ្សេងៗ ឬការបំបែកអ្វីមួយដែលស្មុគស្មាញឱ្យទៅជាងាយ។

**សំយោគ** គឺជាការផ្សំឬរៀបចំវត្ថុមួយដោយយកធាតុ ផ្សេងៗគ្នាមកផ្តុំបង្កបង្កើតឱ្យចេញជាវត្ថុមួយ ឬជាអ្វីមួយឱ្យ មានរូបរាងឡើង។

5. អព្ភន្តរញ្ញាណ គឺជាពុទ្ធិដែលបានមកពីការចង់បានផ្ទាល់ និងភ្លាមៗដោយមានលក្ខណៈ ជាចំណេះដឹងផ្ទាល់ភ្លាមៗ ជាវិចារណភាពគ្មានតិចនិចគ្មានវិធីទាក់ទងទៅនឹងមនុស្ស ម្នាក់ៗដែលជាប្រធានវិស័យភាពនោះឡើយ។**អព្ភន្តរ ញ្ញាណចែកចេញជា៤ប្រភេទគឺ៖**

- អព្ភន្តរញ្ញាណចិត្តវិទ្យា
- អព្ភន្តរញ្ញាណឥន្ទ្រីយ៍
- អព្ភន្តរញ្ញាណបញ្ញា
- អព្ភន្តរញ្ញាណបរមត្ថវិជ្ជា ឬអស្តិរូបវិជ្ជា។

## សំណួរ

1. ដូចម្ដេចហៅថា ទំនោរ?
2. តើគេចែកទំនោរជាប៉ុន្មានប្រភេទ? អ្វីខ្លះ? ចូររៀបរាប់។
3. ចូរនិយាយពីគុណសម្បត្តិនៃទំនោររបស់បុគ្គល។
4. ចូរនិយាយពីការស្ដែងចេញសំខាន់ៗនៃទំនោរ ។

## ចម្លើយ

1. ហៅថា ទំនោរគឺជាផ្នែកមួយនៃចរិតលក្ខណៈ ដែលធ្វើឱ្យជនណាម្នាក់ចង់អភិវឌ្ឍ គិតឬប្រព្រឹត្តតាមរបៀបជាក់លាក់ណាមួយ។
2. គេចែកទំនោរជា៣ប្រភេទដូចជា៖

- **ទំនោរខាងសីលធម៌នយោបាយៈ** ទំនោរនេះប្រកាន់យកមនោគមន៍វិជ្ជានយោបាយ ស្ថិរភាពនយោបាយ ភាពស្មោះត្រង់ចំពោះមាតុភូមិ និងភក្ដីភាពចំពោះស្នាដៃកសាងសង្គមថ្មី។
- **ទំនោរខាងវិជ្ជាជីវៈ** ទំនោរនេះស្ដែងចេញឱ្យឃើញនូវភាពស្វាហាប់ ក្នុងការដក់ចិត្តជាប់នឹងមុខរបរណាមួយដែលបុគ្គលប្រាថ្នាចង់ធ្វើ និងចង់បាន។
- **ទំនោរខាងជីវិតបុគ្គលៈ** ទំនោរនេះផ្ដោតលើផ្នែកសម្ភារៈ វប្បធម៌ និងសីលធម៌។

3. គុណសម្បត្តិនៃទំនោររបស់បុគ្គល មានប្រយោជន៍ណាស់នៅក្នុងរចនាសម្ព័ន្ធនៃបុគ្គលិកលក្ខណៈរបស់មនុស្ស។ គុណសម្បត្តិបែបនេះកំណត់បាននូវខ្លឹមសារ និងទឹកមុខ ឬកាយវិការប្រកបដោយសីលធម៌ និងតម្លៃសង្គមរបស់បុគ្គលម្នាក់ៗ។

4. ការស្តែងចេញសំខាន់ៗនៃទំនោរមាន៖

- តម្រូវការៈ មានដូចជា ម្ហូបអាហារ ទីជម្រក សម្លៀកបំពាក់ ការសិក្សា ទំនាក់ទំនង។
- ចំណាប់ចំណូលចិត្តរបស់បុគ្គលៈ ការពេញចិត្តទៅលើវត្ថុអ្វីដែលល្អសម្រាប់ខ្លួនគេ។
- ឧត្តមគតិៈ មនសិការរបស់មនុស្សដែលឈានទៅរកការសម្រេចបំណងក្នុងរយៈពេលយូរ។
- លោកទស្សនៈរបស់បុគ្គលៈ ជាសំណុំនៃទស្សនៈរបស់បុគ្គលណាម្នាក់ទៅលើបាតុភូតធម្មជាតិសង្គម និងសកម្មភាពរបស់ខ្លួន។

**មេរៀនទី៩** **ឆន្ទៈ**

## សំណួរ

1. ដូចម្តេចហៅថា ឆន្ទៈ? អំពើឆន្ទៈ? អំពើ អឆន្ទៈ?
2. ចូរនិយាយពីកំណើននៃសេចក្តីប្រាថ្នារបស់មនុស្ស។
3. តើសេចក្តីប្រាថ្នារបស់មនុស្សមានប៉ុន្មានប្រភេទ? អ្វីខ្លះ? ចូររៀបរាប់។
4. ចូរបរិយាយពីការតស៊ូផ្ទៃកខាងក្នុងរបស់មនុស្ស។
5. ដូចម្តេចហៅថា ការសម្រេចចិត្ត?

## ចម្លើយ

1. ដែលហៅថា ឆន្ទៈគឺជាសមត្ថភាពគ្រប់គ្រងគំនិតនិងអំពើរបស់មនុស្សដើម្បីសម្រេចនូវអ្វីដែលគេចង់ធ្វើ ឬជាអារម្មណ៍នៃការប្តេជ្ញាចិត្តមុឺងម៉ាត់ ក្នុងការធ្វើអ្វីមួយដែលគេចង់ធ្វើ ។
   - **អំពើឆន្ទៈ:** គឺជាអំពើប្រកបដោយការដឹងខ្លួនឬការភ្ញាក់រលឹកជានិច្ច។
   - **អំពើអឆន្ទៈ:** គឺជារផ្លិចទាំងឡាយដូចជា ការក្អក ការកណ្តាស់ ការញ្ញាក់ត្របកភ្នែក ការកន្ត្រាក់ដៃចេញក្នុងពេលមុតម្ជុល ឬលោកភ្លើង។

2. និយាយពីកំណើននៃសេចក្តីប្រាថ្នារបស់មនុស្ស ៖

   សេចក្តីប្រាថ្នាកើតចេញពីសេចក្តីត្រូវការរបស់មនុស្ស។ សេចក្តីប្រាថ្នានេះសំដៅទៅរកវត្ថុបំណងមួយដ៏ជាក់លាក់លទ្ធភាពបំពេញសេចក្តីត្រូវការឬកម្មវត្ថុណាមួយដ៏ពិតប្រាកដ

ដែលមនុស្សស្វែងរកឬចង់បង្កើតឱ្យមានឡើង។សេចក្ដីប្រាថ្នារបស់មនុស្សមានច្រើនអនេក ច្រើនប្រភេទផ្សេងៗគ្នានិងមានលក្ខណៈស្មុគស្មាញណាស់។

3. គេចែកសេចក្ដីប្រាថ្នារបស់មនុស្សជាពីរប្រភេទគឺ **បំណងនិងចំណង់។**

- **បំណង**សំដៅលើអ្វីមួយដែលមននុស្សចង់បាន ឬមានគំរោងចង់ធ្វើ។ បំណង គឺជាសភាពផ្លូវចិត្តរបស់មនុស្សដែលមនុស្សដឹងខ្លួន នៅពេលគេប្រទះឃើញរបស់អ្វីមួយដែលហាក់ដូចជាមានប្រយោជន៍សំខាន់ចំពោះខ្លួនគេ។
- **ចំណង់** គឺជាសេចក្ដីប្រាថ្នា ឬអារម្មណ៍ខ្លាំងខ្លាក្នុងការចង់បាន ឬចង់ធ្វើអ្វីមួយដែលបង្ហាញឱ្យឃើញច្បាស់លាស់ជាបង្គរ។ មនុស្សដែលមានចំណង់គឺជាមនុស្សដែលស្គាល់ច្បាស់លាស់ពីវត្ថុបំណង និងគោលដៅនៃសេចក្ដីប្រាថ្នារបស់គេ ប៉ុន្តែគេមិនទាន់ស្គាល់ ឬស្ទាបស្ទង់ពីមធ្យោបាយ និងល្បិចដែលខ្លួនគេយកមកប្រើប្រាស់ ដើម្បីឈានទៅរកគោលបំណងដែលបានកំណត់ទុកនៅឡើយ។

4. បរិយាយពីការតស៊ូផ្ទៃកខាងក្នុងរបស់មនុស្ស ៖

លំនាំនៃសេចក្ដីជម្រើសនៃសេចក្ដីប្រាថ្នា គោលបំណង ល្បិច និងមធ្យោបាយ មានលក្ខណៈជាការតស៊ូផ្ទៃកខាងក្នុងរបស់មនុស្ស ។ ការតស៊ូផ្ទៃកខាងក្នុងរបស់មនុស្សនេះ គឺជាការតស៊ូរវាងការផុសចេញនូវអំពើផ្សេងៗរបស់មនុស្ស ឬនិយាយម៉្យាង

ទៀតថា ជាការតស៊ូរវាងការផុសចេញនូវបុព្វហេតុ ឬជាហេតុផលជំរុញនិងគំនិតផ្សេងៗជាច្រើនទៀត។

5. ការសម្រេចចិត្ត គឺជាការសម្រេចយកតាមគោលបំណងណាមួយ ល្បិចណាមួយ និងមធ្យោបាយណាមួយជាកំណត់ដើម្បីឈានទៅសម្រេចបានគោលដៅណាមួយ នោះមានន័យថាក្នុងចំណោមបុព្វហេតុទាំងឡាយដែលផុសចេញក្នុងខ្លួនរបស់មនុស្ស គឺមានបុព្វហេតុតែមួយប៉ុណ្ណោះដែលសំខាន់បំផុតនិងដើរ តួនាទីជាអ្នកកំណត់។

---

## មេរៀនទី៦ តម្លៃនិងសីលវិជ្ជា

### សំណួរ

1. ដូចម្ដេចហៅថាតម្លៃ? ចូរនិយាយពីស្ថានភាពនៃតម្លៃ និងប្រភេទផ្សេងៗនៃតម្លៃ។
2. ចូរបង្ហាញចំណាត់ថ្នាក់នៃតម្លៃរបស់មនុស្ស និងបរិយាយពីការណែនាំក្នុងការជ្រើសរើស តម្លៃ។
3. ដូចម្ដេចហៅថា សីលវិជ្ជា ឬទស្សនវិជ្ជាសីលធម៌?

### ចម្លើយ

1. តម្លៃ គឺជាជំនឿស្ថិតស្ថេរមួយ ដែលជាវិធីជាក់លាក់នៃការប្រព្រឹត្តដែលគួរឱ្យចូលចិត្ត ជាលក្ខណៈបុគ្គលនិងជាលក្ខណៈសង្គម ជាច្បាប់នៃការប្រព្រឹត្តដែលមានលក្ខណៈផ្ទុយពីនេះ។

❖ និយាយពីស្ថានភាពនៃតម្លៃ

បញ្ហានៅក្នុងទស្សនវិជ្ជា ដែលទស្សនវិទូទាំងឡាយបានពិភាក្សាយ៉ាងស្វិតស្វាញ តាំងអំពីបុរាណសម័យរហូតមកដល់សម័យទំនើប គឺចោតសួរអំពីស្ថានភាពតម្លៃ ។ តើតម្លៃមានលក្ខណៈអតនោម័ត ឬសត្យានុម័ត។ ទាក់ទិននឹងបញ្ហានេះ គេបានលើកនូវសំណួរថា តើតម្លៃនៃវត្ថុមួយកើតឡើងដោយសារតែគេសន្មត់ ឬក៏ដោយសារវត្ថុនោះមានតម្លៃពីធម្មជាតិ ឬក៏តម្លៃជាកម្មសិទ្ធិផ្ទាល់របស់វត្ថុនោះ?

❖ ប្រភេទផ្សេងៗ នៃតម្លៃមាន

- **តម្លៃសម្ភារៈ** ជាតម្លៃអ្វីមួយដែលកើតឡើងដោយសារតែទំនាក់ទំនងរបស់វាជាមួយនឹងអ្វីៗផ្សេងទៀត។
- **តម្លៃពីធម្មជាតិ** ជាតម្លៃដែលជាប់ទាក់ទងជាមួយគុណភាព ឬលក្ខណៈដែលវត្ថុអ្វីមួយមានស្រាប់។

2. ចំណាត់ថ្នាក់នៃតម្លៃរបស់មនុស្ស ៖

- **តម្លៃជីវសាស្ត្រ** ជាតម្លៃដែលទាក់ទងនឹងទិដ្ឋភាពនៃជីវិតនិងជាហេតុការណ៍ជីវសាស្ត្រ។
- **តម្លៃសេដ្ឋកិច្ច** ជាតម្លៃដែលទាក់ទងទៅនឹងសម្ភារៈដែលគេប្រើឬផ្លាស់ប្តូទំនិញនិងសេវាកម្ម។
- **តម្លៃឥទ្ធិពល** ជាតម្លៃដែលគេជួបប្រទះនៅក្នុងបទពិសោធន៍ផ្សេងៗដែលគួរជាទីពេញចិត្តខាងអារម្មណ៍។
- **តម្លៃសង្គម** ជាតម្លៃដែលគេជួបប្រទះនៅក្នុងទំនាក់ទំនងសង្គម សហប្រតិបត្តិការនិងការប្រគួតប្រជែង។

- **តម្លៃបញ្ញា** ជាតម្លៃដែលគេបានប្រទះនៅក្នុងការពេញចិត្ត និងការចង់ចេះ ចង់ដឹងប្រកបដោយសុភវិនិច្ឆ័យ និងការប្រើប្រាស់ស្មារតីប្រកបដោយបញ្ញា។
- **តម្លៃសោភ័ណ្ឌ** ជាតម្លៃដែលគេបានជួបប្រទះនៅក្នុងការអបអរ ឬការសរសើរដោយមិនលម្អៀងចំពោះសោភ័ណ្ឌភាពធម្មជាតិនិងសោភ័ណ្ឌសិល្បៈ។
- **សីលតម្លៃ** ជាតម្លៃដែលគេជួបប្រទះនៅក្នុងឥរិយាបថបុគ្គល ឬឥរិយាបថសង្គម ដែលគោរពចំពោះភាពត្រឹមត្រូវកុសលភាព ឬភាពរីកចម្រើននៃឧត្តមគតិរបស់សង្គម។
- **តម្លៃសាសនា** ជាតម្លៃមួយដែលគេបានជួបប្រទះ ឬប្រាថ្នានៅក្នុងភក្តីភាពនិងការគោរពសាសនា។

❖ ការណែនាំក្នុងការជ្រើសរើសតម្លៃមានដូចជា ៖

- តម្លៃពីធម្មជាតិ ឬតម្លៃដែលមានស្រាប់នៅក្នុងវត្ថុដែលគេចូលចិត្តជាងតម្លៃសម្ភារៈ។
- តម្លៃឱ្យផលនិងមានលក្ខណៈអចិន្ត្រៃយ៍ ជាតម្លៃដែលគេចូលចិត្តជាងតម្លៃដែលមិនឱ្យផលនិងគ្មានលក្ខណៈអចិន្ត្រៃយ៍។
- យើងគួរជ្រើសរើសតម្លៃរបស់យើង លើមូលដ្ឋាននៃឧត្តមគតិ ឬបំណងដែលយើងបានកំណត់ដោយខ្លួនឯង។
- រវាងតម្លៃពីរ ឬច្រើនយើងគួរជ្រើសរើសតម្លៃណាមួយដែលល្អជាងគេបំផុត។

3. សីលវិជ្ជា ឬទស្សនវិជ្ជាសីលធម៌ ជាការសិក្សាពីអ្វីមួយដែលត្រូវ ឬខុសនៅក្នុងទង្វើរបស់មនុស្ស និងជាការស្វែងរកជីវិត

ប្រកបដោយកុសល។ សីលវិជ្ជាជាការសិក្សាជាសំខាន់ទៅលើគោលការណ៍សីលធម៌ច្បាប់នៃការប្រព្រឹត្តឬប្រព័ន្ធផ្សេងៗដែលគេគួរតែប្រព្រឹត្តតាមយ៉ាងម៉ត់ចត់ ។ សីលវិជ្ជាកំណត់នូវអ្វីដែលដែលជាការប្រព្រឹត្តល្អ ឬការប្រព្រឹត្តមិនល្អ។

---

## មេរៀនទី៧ ចិត្តញាណនិងសីលញាណ

### សំណួរ

1. តើសីលញាណជាអ្វី? ចិត្តញាណជាអ្វី? ចូរនិយាយពីទំនាក់ទំនងនិងលើកឧទាហរណ៍។
2. តើគេចែកសីលញាណជាប៉ុន្មានផ្នែក?គឺអ្វីខ្លះ? ចូររៀបរាប់និងលើកឧទាហរណ៍បញ្ជាក់។

### ចម្លើយ

1. សីលញាណ គឺជាសញ្ចេតនានៃចិត្តប្រកបដោយនិយាមក្នុងការអប់រំ ហើយញ៉ាំងមនុស្សឱ្យប្រព្រឹត្តតែអំពើល្អនិងចេះដោះស្រាយបញ្ហាប្រកបដោយកុសល ជៀសវាងការប្រព្រឹត្តអំពើអកុសល។

- ចិត្តញាណគឺជាសញ្ចេតនា និងអំពើដែលស្វែងពីភាពពិតនៃចិត្តគឺជាប្រធានវិស័យនិងជាអ្នកវិភាគរាល់ហេតុការណ៍ដែលកើតមាន។ ចិត្តញាណជាអត្តន័យញាណដែលប្រាប់ពីភាពពិតនៃចិត្តឱ្យស្គាល់ ហើយនិងដឹងពីសញ្ចេតនានិងសកម្មភាពដែលយើងបានធ្វើ ។

★ សីលញ្ញាណនិងចិត្តញ្ញាណ មានទំនាក់ទំនងជាមួយគ្នាដោយមិនអាចខ្វះបាន ប្រសិនបើគ្មានចិត្តញ្ញាណទេ នោះនឹងមិនធ្វើឱ្យមនុស្សយើងកើតមាននូវសីលញ្ញាណបានឡើយ ព្រោះចិត្តញ្ញាណជាប្រធានសង្កេត ពិនិត្យហើយសីលញ្ញាណជាអ្នកវិភាគ ពិចារណា វិនិច្ឆ័យប្រកបដោយវិចារណញ្ញាណ។

2. គេចែកសីលញ្ញាណជាពីរផ្នែកគឺ

- **សីលវិនិច្ឆ័យ** ដែលមានទំនាក់ទំនងទៅនឹងបញ្ញាញាណដែលស្ថិតនៅក្នុងខ្លួនមនុស្ស និងជាហេតុដែលធ្វើឱ្យយើងអាចដឹងពីអំពើល្អ និងអំពើអាក្រក់។

  **ឧទាហរណ៍:**ពេលយើងធ្វើអ្វីខុស យើងដឹងថាខុស

- **សីលមនោសញ្ចេតនា** វាតែងតែកើតមានជានិច្ចជាមួយសីលវិនិច្ឆ័យគឺជាការគោរពអំពើជាកុសលហើយស្អប់ខ្ពើមអកុសលជាដើម។ឧទាហរណ៍មនុស្សខ្លះមិនចូល ចិត្តធ្វើអំពើអាក្រក់នោះទេ។

## មេរៀនទី៤

## ទំនួលខុសត្រូវនិងវិបាកវិនិច្ឆ័យ

### <u>សំណួរ</u>

I. ចូរគូសសញ្ញា✓ក្នុងប្រអប់ ដែលមានចម្លើយត្រូវតែមួយគត់៖

3. ជនដែលប្រព្រឹត្តអំពើអ្វីមួយទៅលើអ្នកដទៃបង្ករឱ្យមានរបួសស្នាមជននោះត្រូវជាប់ទោស៖

☐ក.ផ្នែកសីលវិជ្ជា ☐ខ.ផ្នែកសង្គម

☐គ.ផ្នែករដ្ឋប្បវេណី ☑ឃ.ផ្នែកព្រហ្មទណ្ឌ

2. ជនដែលប្រព្រឹត្តអំពើអ្វីមួយទៅលើអ្នកដទៃ ដោយបំផ្លាញទ្រព្យសម្បត្តិអ្នកដទៃ ជននោះត្រូវជាប់ទោស៖

☐ក.ផ្នែកសីលវិជ្ជា ☐ខ.ផ្នែកសង្គម

☑គ.ផ្នែករដ្ឋប្បវេណី ☐ឃ.ផ្នែកព្រហ្មទណ្ឌ

3. តម្លៃរបស់មនុស្សដែលអាស្រ័យទៅលើបញ្ហាកម្មផលគឺជាទ្រឹស្ដីរបស់ពួក ៖

☑ក.ប្រពៃណីនិយម ☐ខ.វិចារណញ្ញាណនិយម

☐គ.កំណត់និយម ☐ឃ.ពិសោធន៍និយម

4. ការលើកសរសើរ ឬដាក់ទណ្ឌកម្មអ្នកណាម្នាក់ដោយមានការត្រួតពិនិត្យ វិភាគ វិនិច្ឆ័យ រកហេតុផលច្បាស់លាស់ គឺជាវិបាកវិនិច្ឆ័យផ្នែក ៖

☐ក. សីលវិជ្ជា☐ខ. សង្គម ☐គ.ប្រពៃណី ☑ឃ.នីតិសាស្ត្រ

5. ការលើកសរសើរ ឬដាក់ទណ្ឌកម្មអ្នកណា ម្នាក់តាមរយៈ ការអប់រំផ្នែកក្រមសីលធម៌វិជ្ជាជីវៈ គឺជាវិបាកវិនិច្ឆ័យផ្នែក៖

☐ក.សីលសង្គម ☑ខ.បច្ចុប្បន្ន

☐គ.ប្រពៃណី ☐ឃ.នីតិសាស្ត្រ

6. ការវាយតម្លៃ ឬដាក់ទណ្ឌកម្មជនណាម្នាក់តាមរយៈការ បំភ័យនិងគំរាមដល់អ្នកដទៃកុំឱ្យធ្វើត្រាប់តាម ។ នេះគឺជា វិបាកវិនិច្ឆ័យផ្នែក៖

☐ក.សង្គម ☐ខ.បច្ចុប្បន្ន

☑គ.ប្រពៃណី ☐ឃ.នីតិសាស្ត្រ

II. ចូរបំពេញឃ្លាខាងក្រោមឱ្យបានត្រឹមត្រូវ៖

1. ទំនួលខុសត្រូវមួយដែលទាមទារឱ្យពិរុទ្ធជនសងថ្លៃការខូច ខាតដល់ជនរងគ្រោះគឺជាទំនួលខុសត្រូវផ្នែក*រដ្ឋប្បវេណី*។

2. ទំនួលខុសត្រូវមួយ ដែលមានការចេះយោគយល់អធ្យា ស្រ័យគ្នាទៅវិញទៅមកគឺជាទំនួលខុសត្រូវផ្នែក***សីលធម៌***។

3. រាល់អំពើដែលធ្វើឡើងក្នុងការបំភ័យ និងកំញើញដល់អ្នក ជំនាន់ក្រោយមិនឱ្យអនុវត្តតាម គឺជាវិបាកវិនិច្ឆ័យតាម *ប្រពៃណី*។

4. រាល់អំពើដែលធ្វើឡើងក្នុងការអប់រំក្រមសីល ធម៌និងសីល ធម៌វិជ្ជាជីវៈដល់ទណ្ឌិត គឺជាវិបាកវិនិច្ឆ័យតាមបែប *បច្ចុប្បន្ន*។

5. រាល់ការប្រព្រឹត្តអំពើលួចទ្រព្យសម្បត្តិវត្ថុបុរាណជាតិរបស់ ពិរុទ្ធជន គឺជាទំនួលខុសត្រូវដែល *រដ្ឋប្បវេណី*។

III. សំណួរត្រិះរិះ

1. តើទំនួលខុសត្រូវជាអ្វី? តើទំនួលខុសត្រូវចែកចេញជាប៉ុន្មានប្រភេទ? ចូររៀបរាប់និងលើកឧទាហរណ៍។
2. តើទំនាក់ទំនងរវាងទំនួលខុសត្រូវសង្គម និងទំនួលខុសត្រូវសីលវិជ្ជាមានលក្ខណៈខុសគ្នាដូចម្តេចខ្លះ? ចូរធ្វើការប្រៀបធៀបនិងលើក ឧទាហរណ៍។
3. តើទ្រឹស្តីផ្សេងៗរបស់ទំនួលខុសត្រូវមានអ្វីខ្លះ? ចូររៀបរាប់។
4. តើវិបាកវិនិច្ឆ័យជាអ្វី? បែបផ្សេងៗនៃវិបាកវិនិច្ឆ័យមានអ្វីខ្លះ? ចូររៀបរាប់និងលើកឧទាហរណ៍។

III. ចម្លើយ

1. ទំនួលខុសត្រូវ ជាកាតព្វកិច្ចដែលត្រូវបានភ្ជាប់រាល់អំពើទាំងឡាយដែលខ្លួនបានធ្វើ ដោយហ៊ានទទួលសារភាព និងហ៊ានទទួលនូវផលវិបាកនៅចំពោះខ្លួន ឯងផងនិងចំពោះមុខច្បាប់សង្គមផង។

❖ ទំនួលខុសត្រូវចែកជាពីរប្រភេទគឺ

• ទំនួលខុសត្រូវផ្នែកសីលធម៌ គឺជាទំនួលខុសត្រូវដែលអ្នកប្រព្រឹត្តហ៊ានទទួលសារភាពដោយស្មោះត្រង់ ដោយពុំមានការបង្ខិតបង្ខំ។

- **ទទួលខុសត្រូវផ្នែកសង្គម** គឺជាទំនួលខុសត្រូវដែលអ្នកប្រព្រឹត្តហ៊ានសារភាពទោសកំហុសរបស់ខ្លួន នៅចំពោះមុខច្បាប់សង្គម។

2. ទំនាក់ទំនងរវាងទំនួលខុសត្រូវសង្គម និងទំនួលខុសត្រូវសីលវិជ្ជាមានលក្ខណៈខុសគ្នាដូចជា៖

- ទំនួលខុសត្រូវសង្គមមានច្បាប់ តុលាការហើយពាក់ព័ន្ធនឹងរូបរាងកាយ
- ទំនួលខុសត្រូវសីលធម៌ គឺផ្នែកចិត្តគំនិត ។

3. ទ្រឹស្តីផ្សេងៗរបស់ទំនួលខុសត្រូវមាន
   - ទ្រឹស្តីប្រពៃណីនិយម
   - ទ្រឹស្តីវិចារញ្ញាណនិយមនៃទំនួលខុសត្រូវ។

4. វិបាកវិនិច្ឆ័យ ជារង្វាន់ ឬការដាក់ទណ្ឌកម្មដល់អ្នកដែលបានប្រព្រឹត្តទាក់ទងនឹងផ្នែកសីលធម៌។

- វិបាកវិនិច្ឆ័យផ្នែកសីលធម៌
- វិបាកវិនិច្ឆ័យផ្នែកសង្គម។

❖ ទ្រឹស្តីនៃវិបាកវិនិច្ឆ័យមានបីគឺ

- **វិបាកវិនិច្ឆ័យតាមបែបប្រពៃណី** ជាវិបាកវិនិច្ឆ័យតាមគំនិតបែបប្រពៃណីនិយម ផ្តេកទាំងស្រុងទៅលើសេរីអាជ្ញា ហើយជាចេតនារម្មណ៍នៃអ្នកធ្វើ ។ **ឧទាហរណ៍៖** សង្គមខ្មែរពី អតីតកាល គេធ្វើទណ្ឌកម្មលើស្ត្រីដែលគេជឿថាចេះធ្មប់អាបដោយចាប់យកទៅចងភ្លាងដុតទាំងរស់។

- វិបាកវិនិច្ឆ័យតាមបែបសង្គមវិវត្តន៍នីតិសាស្ត្រ ជាការវិនិច្ឆ័យទៅតាមច្បាប់សង្គមដែលមានការរីកចម្រើន ។ ឧទាហរណ៍ ប្រទេសកម្ពុជាយើងនាសម័យឧត្តុង្គ វិបាកវិនិច្ឆ័យត្រូវបានធ្វើឡើងដោយយកពិរុទ្ធជនទៅដាក់ខ្នោះឃ្នាង ដោយវាយឱ្យស្រែកអាក្រោស ដើម្បីឱ្យប្រជារាស្ត្របានដឹងគ្រប់គ្នា។
- វិបាកវិនិច្ឆ័យនាសម័យបច្ចុប្បន្ន ជាការវិនិច្ឆ័យមួយដែលគោរពតាមច្បាប់គោលការណ៍សិទ្ធិមនុស្សជាចំបង។ ឧទាហរណ៍ សម័យបច្ចុប្បន្នគេដាក់ទណ្ឌកម្មជនល្មើសទៅតាមបទល្មើសដែលជននោះបានប្រព្រឹត្ត ដោយឱ្យសងជាសំណង ឬជាក់គុកដើម្បីឱ្យជននោះមានការកែប្រែ។

---

**មេរៀនទី៩** **គុណធម៌**

**សំណួរ**

I. ចូរគូសសញ្ញា✓ក្នុងប្រអប់ដែលមានចម្លើយ ត្រូវតែមួយគត់ ៖

1. ជនដែលមានពុទ្ធិសកល សមត្ថភាពបរិបូរណ៍និងពោរពេញទៅដោយគុណធម៌ ហើយមានសុភវិនិច្ឆ័យច្បាស់លាស់ ជននោះគេចាត់ទុកជា

☐ក.សន្តបុគ្គល ☐ខ.វីរជន

☑គ.បណ្ឌិត ☐ឃ.បញ្ញាជន

2. សីលធម៌នឹងកើតមានកាលណាការរស់នៅជា ក្រុមចាប់ផ្តើមឡើង។ នេះជាសម្តីរបស់លោក:

☐ក.លោក អារីស្តូត ☑ខ.លោក ដូខឹម

☐គ.លោក ឡឺសែន ☐ឃ.លោក រ៉ែនូវៀ។

II. ចូរផ្គូផ្គងផ្នែកA និងB នៅក្នុងCឱ្យបានត្រឹមត្រូវ

| A | B | ចម្លើយ |
|---|---|---|
| 1.គុណធម៌កំណើត<br>2.គុណធម៌សាមញ្ញ<br>3.គុណធម៌បញ្ញា<br>4.សីលគុណធម៌ | ក.គុណធម៌ដែលមានសម្ពុះជំរុញវិចារណញ្ញាណ ឱ្យប្រព្រឹត្តអំពើកុសល<br>ខ.គុណធម៌ដែលធ្វើឱ្យមនុស្សយើងមានបញ្ញាវិះគិតក្នុងផ្លូវល្អ ដើម្បីសាងពុទ្ធិសច្ចៈ<br>គ.គុណធម៌ដែលបានមកពីការហ្វឹកហាត់និងការអប់រំ<br>ឃ.គុណធម៌ដែលមនុស្សបានទទួលមត៌កពីធម្មជាតិមក<br>ង.គុណធម៌ដែលមនុស្សបានទទួលមត៌កពីអាទិទេព | 1. →ឃ<br>2. →គ<br>3. →ខ<br>4. →ក |

III. សំណួរត្រិះរិះ

1. គុណធម៌ជាអ្វី? គុណធម៌ចែកចេញជាប៉ុន្មានបែប? អ្វីខ្លះ? ចូរពន្យល់និងផ្ដល់ឧទាហរណ៍។
2. តើលោក អារីស្តូត បានចែកថ្នាក់គុណធម៌ដូចម្ដេចខ្លះ? តើគុណធម៌ណាមួយ ដែលជាអ្នកសាងនូវពុទ្ធិខាងសច្ចៈ? ព្រោះអ្វី?

3. សញ្ញាណអ្វីខ្លះដែលមានន័យ ស្រដៀងនឹងគុណធម៌? ចូរ រៀបរាប់និងឱ្យឧទាហរណ៍បញ្ជាក់។
4. តើមនុស្សប្រភេទណាដែលគេចាត់ជាឧត្តមជនគំរូ? មាន លក្ខណៈខុសគ្នាដូចម្ដេចខ្លះ? រកឃើញនូវលក្ខណៈរួមដូច ម្ដេចខ្លះ?

## III. ចម្លើយ

1. គុណធម៌គឺជាសីលតម្លៃ ឬជាកម្លាំងដែលមានតម្លៃរបស់ បុគ្គលម្នាក់ៗពោរពេញទៅដោយមនោសញ្ចេតនា ប្រកប ដោយកុសលជាប់លាប់ ហើយច្បាស់លាស់ចំពោះសង្គម ដែលខ្លួនរស់នៅ។

❖ គុណធម៌ចែកចេញជាពីរបែបគឺ

- **គុណធម៌សាមញ្ញ** គឺជាគុណធម៌ដែលបានមកពីការហ្វឹក ហាត់និងអប់រំ។ ឧទាហរណ៍ ការទៀងពេល ការចេះប្រមាណ ភក្ដីភាព ភាពខ្ជាប់ខ្ជួន ការគួរសម។
- **គុណធម៌កំណើត** ជាគុណធម៌ដែលមនុស្សបានទទួលពី កំណើត។ ឧទាហរណ៍សណ្ដានចិត្តចិត្តសណ្ដោសចិត្តមេត្តា។

2. លោក អារីស្តូត បានចែកថ្នាក់គុណធម៌ ជាពីរក្រុមគឺ ៖

- **គុណធម៌បញ្ញា** ជាគុណធម៌ដែលធ្វើឱ្យមនុស្សយើងមានបញ្ញា ក្នុងការរិះគិតក្នុងផ្លូវល្អដើម្បីកសាងពុទ្ធិសច្ចៈ ដូចជាសិល្បៈ ស្បង់ បំរុងប្រយ័ត្ន គតិវិញ្ញូ បញ្ញាជាដើម ។
- **សីលគុណធម៌** ជាគុណធម៌ដែលមាននៅក្នុងទម្លាប់ដែលគ្រប សង្កត់លើសម្ទុះជំរុញវិចារណញ្ញាណ និងក្នុងទម្លាប់ប្រព្រឹត្តអំ

ពើល្អ ត្រឹមត្រូវ សមរម្យ ទោះជាស្ថិតនៅក្នុងកាលៈទេសៈណាក៏ដោយ ដូចជាសេចក្តីក្លាហានការចេះប្រមាណ យុត្តិធម៌ និងវិញ្ញ។

❖ គុណធម៌ដែលជាអ្នកសាងនូវពុទ្ធិខាងសច្ចៈ គឺគុណធម៌បញ្ញា ព្រោះជាគុណធម៌ ដែលធ្វើឱ្យមនុស្សយើងមានបញ្ញាក្នុងការរិះគិតក្នុងផ្លូវល្អ។

3. សញ្ញាណដែលមានន័យស្រដៀងនឹង គុណធម៌មាន ៖

- សុក្រឹតភាព តាមឫសគល់នៃសុក្រឹតភាពសំដៅដល់អ្វីដែលគេធ្វើបានដោយសព្វគ្រប់ ឬដែលគេពុំអាចបន្ថែមទៀតបាន។ សុក្រឹតភាព សំដៅលើលក្ខណៈនៃអ្វីដែលប្រជុំគ្រប់គុណសម្បត្តិដោយពុំមានលាយឡំនឹង គុណវិបត្តិ។
- គុណូបការៈ ជាគុណបំណាច់ដ៏វិសេសវិសាលមិនអាចកាត់ថ្លៃបាន។ ក្នុងន័យទូលំទូលាយ គុណូបការៈបានន័យថា ជាតម្លៃហើយជាពិសេសជាតម្លៃវិជ្ជាជីវៈនៃបុគ្គលនីមួយៗ ។

4. មនុស្សដែលគេចាត់ជាឧត្តមជនគំរូមាន

- បណ្ឌិត មនុស្សដែលមានពុទ្ធិសកល មានភាពឈ្លៀសវៃខាងបញ្ញាយ៉ាងធំ។
- វីរបុរស សំដៅលើជនណាដែលហ៊ានពលីជីវិតហ៊ានពុះពារឧបសគ្គធំៗ ហ៊ានទទួលការឈឺចាប់ខ្លាំងបំផុតទាំងផ្លូវកាយនិងផ្លូវចិត្ត។

- សន្តបុគ្គល មនុស្សដែលចាត់ទុកជាសន្តបុគ្គល គឺមនុស្សដែលមានចំណាង់ខាងជំនឿសាសនា មានរបៀបរស់នៅជាជនស្វែងរកសុក្រឹតភាពជានិច្ច។

❖ លក្ខណៈរួម ជាមនុស្សធ្វើប្រយោជន៍ដើម្បីឱ្យមនុស្សមានការគិតគូរដោយត្រឹមត្រូវ និងធ្វើឱ្យមនុស្សគួរយកធ្វើជាគំរូ។

---

## មេរៀនទី១០ សិទ្ធិនិងច្បាប់

### សំណួរ

1. ដូចម្តេចហៅថាសិទ្ធិ? ច្បាប់? តើសិទ្ធិនឹងច្បាប់ មានទំនាក់ទំនងនឹងគ្នាដូចម្តេចខ្លះ?
2. តើសិទ្ធិ និងករណីយកិច្ចមានទំនាក់ទំនងដូចម្តេចខ្លះ? ចូរលើកឧទាហរណ៍បញ្ជាក់។

### ចម្លើយ

1. សិទ្ធិគឺ ជាអ្វីៗទាំងអស់ដែលមនុស្សត្រូវការជាចាំបាច់សម្រាប់ឱ្យមនុស្សរស់នៅក្នុងសេចក្តីថ្លៃថ្នូរជាមនុស្ស។

❖ ច្បាប់ គឺជានិយាមឬជាកាតព្វកិច្ចចាំបាច់បំផុតរបស់មនុស្សសម្រាប់ការពារសិទ្ធិ និងសេរីភាពដែលធម្មជាតិបានសំអិតសំអាងឡើងដើម្បីជីវិតរស់នៅក្នុងសង្គម។

❖ សិទ្ធិនឹងច្បាប់ មានទំនាក់ទំនងនឹងគ្នា គឺច្បាប់ជាអ្នកកំណត់សិទ្ធិសេរីភាពមនុស្ស ឯសិទ្ធិគឺអនុវត្តតាមច្បាប់។ ច្បាប់បង្កើតឡើងដើម្បីការពារសិទ្ធិ និងកំណត់ព្រំដែននៃសិទ្ធិ។

2. សិទ្ធិ និងករណីយកិច្ចមានទំនាក់ទំនងគ្នាដូចជា យើងអាច សម្គាល់ឃើញថា ការទាក់ទងគ្នាទៅវិញទៅមករវាងសិទ្ធិនិង ករណីយកិច្ចមានលក្ខណៈជិតស្និទ្ធិជាចាំបាច់ណាស់ព្រោះថា កាតព្វកិច្ចរបស់អ្នកដ៏ទៃចំពោះខ្ញុំ គឺជាការឆ្លើយតបចំពោះ សិទ្ធិរបស់ខ្ញុំ ផ្ទុយទៅវិញកាតព្វកិច្ចរបស់ខ្ញុំចំពោះអ្នកដ៏ទៃជា ការឆ្លើយតបទៅនឹងសិទ្ធិអ្នកដ៏ទៃ។ Ex កម្មករមានសិទ្ធិទាម ទារពីនិយោជក របស់ខ្លួននូវប្រាក់ខែសមរម្យ ការឈប់ សម្រាកជាដើម ប៉ុន្តែនិយោជកក៏មានសិទ្ធិនិងតម្រូវឱ្យកម្មករ មកធ្វើការប្រចាំតាមម៉ោងជាកំណត់ ។

---

## មេរៀនទី១១ យុត្តិធម៌

### សំណួរ

1. តើយុត្តិធម៌ជាអ្វី?
2. តើធ្វើដូចម្តេចដើម្បីឱ្យមានសមភាពរវាង មនុស្សនៅក្នុង សង្គម?
3. ចូរប្រៀបធៀបយុត្តិធម៌ និងសប្បុរសធម៌។

### ចម្លើយ

1. យុត្តិធម៌ជាពាក្យសក្តិសិទ្ធិ ដោយហេតុថាពាក្យនេះឯង ធ្វើឱ្យ មនុស្សហ៊ានស្លាប់ ហ៊ានងើបឡើយតស៊ូដើម្បីទាមទារយុត្តិ ធម៌ក្នុងការកាត់សេចក្តីយុត្តិធម៌ក្នុងការបែងចែក យុត្តិធម៌ ក្នុងការប្រើប្រាស់និងយុត្តិធម៌ក្នុងការរស់នៅជាដើម។

2. ដើម្បីឱ្យមានសមភាពរវាង មនុស្សនៅក្នុងសង្គមគឺត្រូវតម្រូវឱ្យប្រជាពលរដ្ឋទាំងអស់ ត្រូវតែចូលរួមនៅក្នុងប្រព័ន្ធតែមួយនៃសិទ្ធិនិងករណីយកិច្ចដូចជា ៖

- លុបបំបាត់ភាពអយុត្តិធម៌សង្គមនិងបំបាត់វិសមភាព
- ត្រូវមានភាពយុត្តិធម៌នៅក្នុងសង្គម
- មនុស្សម្នាក់ៗត្រូវចូលរួមគ្រប់សកម្មភាពនៅក្នុងសង្គម
- អនុវត្តសិទ្ធិសេរីភាពរបស់ខ្លួនកុំឱ្យប៉ះពាល់ដល់អ្នកដទៃ។

3. ប្រៀបធៀបយុត្តិធម៌ និងសប្បុរសធម៌។

<u>យុត្តិធម៌</u>

- មានលក្ខណៈបញ្ញាដែលចូលរួមទៅក្នុងលំដាប់នៃវិចារណញ្ញាណ
- មានមុខងារការពាររបៀបរៀបរយក្នុងសង្គម
- បង្កើតជាច្បាប់ទូទៅមួយ
- មិនសំដៅទៅលើអ្វីដែលមានទំនាក់ទំនងទៅជនណាម្នាក់ឡើយ

<u>សប្បុរសធម៌</u>

- ជាគុណធម៌ពិសេសរបស់មនុស្សទាំងឡាយណា ដែលមានចិត្តល្អនិងមនុស្សធម៌
- មានឧត្តមគតិមនុស្សជាតិនិងចិត្តស្រលាញ់ប្រណីមេត្តា
- ជាសេចក្តីស្នេហាចំពោះអ្នកដទៃ រុញច្រានមនុស្សឱ្យធ្វើអំពើល្អចំពោះអ្នកដទៃ

• មានលក្ខណៈវេទនា លក្ខណៈសញ្ចេតនាដែលចូលទៅក្នុងលំដាប់ចិត្ត
• បំផុសគំនិតកក្តីភាពណាមួយចំពោះជនណាម្នាក់
• ទាក់ទងនឹងជនណាម្នាក់ផ្ទាល់ខ្លួនតែម្តងៗ

## សំណួររបញ្ចប់ជំពូកទី១

I. ចូរគូសសញ្ញា✓ក្នុងប្រអប់ ដែលមានចម្លើយត្រូវតែមួយគត់ ៖

1. បញ្ញាជាសម្បទាដែលអាចសម្រេចទៅនឹងស្ថានការណ៍ថ្មីៗ នេះជាទស្សនៈរបស់លោកណា?

☐ក.ដឺឡាក្រ័រ ☐ខ.ដេកាត
☐គ.បាគតម៉ាន់ ☑ឃ.ភ្លាប៉ារ៉ែត

2. មនុស្សដែលដឹងខុសត្រូវស្គាល់ល្អអាក្រក់ ហើយប្រព្រឹត្តតែអំពើល្អតែខ្លួនស្ថិតនៅក្រោមបង្គាប់គេ ។ ជននោះគេចាត់ទុកជាមនុស្សមាន ៖

☐ក.ញាណគ្រប់គ្រាន់ ☐ខ.ញាណមិនគ្រប់គ្រាន់
☐គ.សីលញាណ ☑ឃ.ទំនួលខុសត្រូវ

3. កាលណាខ្ញុំអើលផ្លូស ខ្ញុំទទួលបានភ្លោច ៖

☑ក.ដេកាទ៏ច ☐ខ.រូវើទ្យ ☐គ.គីមី

4. ជនដែលមានពុទ្ធិសក់ល មានសមត្ថភាពបរិបូរពោរពេញទៅដោយគុណធម៌ហើយមានសុភវិនិច្ឆ័យច្បាស់លាស់ៗ ជននោះគាត់ទុកជា៖

☐ក.សន្តបុគ្គល ☐ខ.វីរជន

☑គ.បណ្ឌិត ☐ឃ.បញ្ញាជន

5. ឥន្ទ្រីយារម្មណ៍ចាប់ផ្តើមឡើងដោយរំញោចនៅក្នុង ៖

☑ក.ដំណាក់រូបវិទ្យា ☐ខ.ដំណាក់សរីរវិទ្យា

☐គ.ដំណាក់ចិត្តវិទ្យា

6. ជនដែលប្រព្រឹត្តអំពើអ្វីមួយទៅលើអ្នកដទៃ ដោយបំផ្លាញទ្រព្យសម្បត្តិអ្នកដទៃ។ ជននោះត្រូវមានទោស ៖

☐ក.ផ្នែកសីលវិជ្ជា ☐ខ.ផ្នែកសង្គម

☑គ.ផ្នែករដ្ឋប្បវេណី ☐ឃ.ផ្នែកព្រហ្មទណ្ឌ

II. ចូរផ្គូផ្គងផ្នែកA និងផ្នែក B ឱ្យបានត្រឹមត្រូវ

| A | B | ចម្លើយ |
|---|---|---|
| 1. ឥន្ទ្រីយារម្មណ៍<br>2. រូបភាព<br>3. រូបារម្មណ៍<br>4. យល់សប្តិ<br>5. រវើរវាយ<br>6. ទេពកោសល្យ<br>7. កោសល្យ<br>8. សម្បទា<br>9. កំសោយបញ្ញា<br>10. ភ្លីភ្លើ<br>11. ល្ងីល្ងើ<br>12. ឆន្ទៈជាបញ្ញា<br>13. ឆន្ទៈជាការខំប្រឹង<br>14. មនុស្សមិនមែន ជាម្ចាស់នៃអំពើ របស់ខ្លួនទេ | ក.សំណង់រូបភាពបែប លក្ខណៈវត្ថុវិស័យភាព<br>ខ.រូបភាពអកម្មនៃចិត្ត<br>គ.សតិសម្រាប់នឹកគិតដោយរូបភាព<br>ឃ.ធាតុភូតចិត្តសរីរវិទ្យា<br>ង.លំនឹកគិតនៃចិត្តទៅ រកវត្ថុមួយក្នុងពេលវត្ថុ នោះអវត្តមាន<br>ច.បញ្ញាខ្ពស់<br>ឆ.បញ្ញាធម្មតា<br>ជ.លទ្ធផលបញ្ញាស្មើ០.៥<br>ឈ.លទ្ធផលបញ្ញាតិច ជាង ០.៥<br>ដ.បញ្ញាខ្ពស់បំផុត<br>ប.ទ្រឹស្តីកំណត់និយម | 1. →ឃ<br>2. →ង<br>3. →គ<br>4. →ក<br>5. →ខ<br>6. →ដ<br>7. →ច<br>8. →ឆ<br>9. →ជ<br>10. →ជ<br>11. →ឈ<br>12. →ត<br>13. →ណ<br>14. →ឱ |

| | | |
|---|---|---|
| 15. ឆន្ទៈជាចំណង់<br>16. ឆន្ទៈស្ថិតលើការ អប់រំ<br>17. ឆន្ទៈកើតមកពី សេរីភាព | ឌ.ទ្រឹស្តីវាសនានិយម<br>ធ.ទ្រឹស្តីសេរីអាជ្ញា<br>ណ.ទ្រឹស្តីពិសោធន៍និយម<br>ត.ទ្រឹស្តីបញ្ញានិយម | 15.→ឋ<br>16.→ណ<br>17.→ធ |

III. ចូរបំពេញឃ្លាខាងក្រោមឱ្យបានត្រឹមត្រូវ

1. ទំនោរបំប្លែងនូវភាព ឬជាការភូតកុហកហៅថា ***ទំនោរខាងសីលធម៌មិនយោបាយ*** ។
2. បញ្ញាទ្រឹស្តីកើតមានតែចំពោះ ***តែមនុស្សប៉ុណ្ណោះ*** ។
3. កត្តាដែលនាំឱ្យមានការបង្កើតថ្មីដែលជានិស្ស័យពីកំណើតហៅថា ***កត្តាភពនៃទេពកោសល*** ។
4. នៅពេលកើតភ្លាមមនុស្សស្ថិតក្នុងភាព ***ជាសភាវគតិ***ដូចសត្វដែរ ។
5. តក្កវិទ្យាជាវិចារដែលមានសំណើ បង្កើតឡើងដោយលោក ***អារីស្តូត*** ។
6. អំពើដែលកើតឡើងដោយមិនបានព្រាងទុកជាមុនហៅថា ***អំពើអឆន្ទៈ*** ។
7. នៅពេលប្រឡងប្រណាំងមនុស្សគ្រប់រូបតែង តែមានបំណងចង់ឈ្នះដាច់គេ ហើយទទួលបានលេខមួយនេះជាទំនោរ ***វិជ្ជាជីវៈ*** ។
8. សតិពិសេសមួយដែលអាចឱ្យយើងគិតជាគំនិតទូទៅ ឬជាបញ្ញត្តិអរូបីដោយមានភាសាជំនួយហៅថា ***បញ្ញាទ្រឹស្តី*** ។

9. សំយោគក្នុងគំនិតដែលភ្ជាប់មតិ និងបដិមតិ ដើម្បីបង្កើតច្រកចេញថ្មីមួយទៀតក្នុងដំណោះ ស្រាយបញ្ហាហៅថាសំយោគ*បដិសំយោគ*។

IV. សំណួរត្រិះរិះ

1. ចូរពន្យល់ពីទំនាក់ទំនងរវាងសប្បុរសធម៌ និង យុត្តិធម៌។
2. តើរូបភាពអាចត្រឡប់ចូលមកក្នុងញាណ របស់យើងតាមរបៀបណា? ចូរពន្យល់?
3. ហេតុអ្វីបានជាមនុស្សម្នាក់ៗចាប់យកវិជ្ជាជីវៈ ខុសៗគ្នា?
4. តើច្បាប់មានមុខងារអ្វីខ្លះនៅក្នុងសង្គម ? អំណាចដែលច្បាប់ឱ្យមកយើងមានទិដ្ឋភាពដូចម្ដេច ? ចូរឱ្យឧទាហរណ៍។
5. តើគុណធម៌មានលក្ខណៈដូចគ្នាឬទេ ? គេចែកគុណធម៌ជាអ្វីខ្លះ?
6. តើករណីយកិច្ចមានលក្ខណៈសំខាន់ដូចម្ដេចខ្លះ?
7. ដូចម្ដេចដែលហៅថា ឆន្ទៈ? ដើម្បីឱ្យឆន្ទៈមានសមត្ថភាពល្អត្រូវផ្អែកលើកត្តាអ្វីខ្លះ?
8. នៅអឺរ៉ុបពេលជួបគ្នាគេចាប់ដៃគ្នាគេថើបគ្នា នៅប្រទេសមួយចំនួននៅអាស៊ីពេលជួបគ្នាគេ សំពះគ្នាយ៉ាងទន់ភ្លន់។ ហេតុអ្វីបានជាមាន សីលនិយាមនិងសីលញាណខុសគ្នាបែបនេះ?

IV. បញ្ញាភ្លឺថ្លា និងឆន្ទៈមោះមុតស្ថិតតែក្នុងរាងកាយមាំមួន និងសុខភាពល្អ ចូរពន្យល់និង លើកឧទាហរណ៍បញ្ជាក់ផង។

## ចម្លើយបញ្ចប់ជំពូកទី1

1. ពន្យល់ពីទំនាក់ទំនងរវាងសប្បុរសធម៌ និង យុត្តិធម៌គឺ
យុត្តិធម៌និងសប្បុរសធម៌មានទំនាក់ទំនងគ្នានិងបង្គ្រប់ គ្នាទៅវិញទៅមក ។ នៅក្បែរយុត្តិធម៌ សប្បុរសធម៌ថែរក្សាទុកនូវតម្លៃរបស់ខ្លួនទាំងមូល ។ យុត្តិធម៌ឱ្យនិយមន័យទៅលើឧត្តមគតិចំនែកឯសប្បុរសធម៌គឺជាកម្លាំង ចលករនៃអំពើសីលធម៌ និងជាសំទុះដែលជំរុញយើងឱ្យសម្រេចយុត្តិធម៌ ។ យុត្តិធម៌នឹងមិនអាចនឹងឈោងទៅដល់សីលកុសលពិតប្រាកដបានឡើយប្រសិនបើគ្មានសប្បុរសធម៌ ឯសប្បុរសធម៌ប្រសិនបើគ្មានយុត្តិធម៌ ក៏នឹងអាចក្លាយទៅជាភាពសេរីនៃសព្វោតនាលម្អៀង ហើយសម្រេចបានយុត្តិធម៌តែភាគប៉ុណ្ណោះ។

2. រូបភាពអាចត្រឡប់ចូលមកក្នុងញាណ របស់យើងតាមរយៈលំនឹកឬជាការបណ្ដុំនៃគំនិត។កាលណាយើង ធ្វើលំនឹកគឺយើងនឹងចងចាំអ្វីមួយហើយនិងផ្ដិតយករូបភាពចូលក្នុងចិត្តរបស់យើង ។

3. មនុស្សម្នាក់ៗចាប់យកវិជ្ជាជីវៈ ខុសៗគ្នាដោយសារ ៖

- កត្តាវេទនា(ឧបនិស្ស័យ) ដែលទាក់ទងនឹងចំណង់នៃផ្លូវអារម្មណ៍ ឬជានិស្ស័យពីកំណើតដែលឱ្យគេមានចិត្ត ស្រលាញ់ឯកទេសអ្វីមួយ ។
- កត្តាផលប្រយោជន៍ ៖ ដោយគេសង្កេតឃើញការ ទទួលផលប្រយោជន៍ជាច្រើនពីឯកទេសណាមួយ សម្រាប់ផ្គត់ផ្គង់ខ្លួន និងក្រុមគ្រួសារឱ្យមានការអភិវឌ្ឍរីកចម្រើន ។

4. ក្នុងសង្គមច្បាប់មានមុខងារដូចជា
- កំណត់សិទ្ធិសេរីភាពរបស់មនុស្ស
- ធ្វើឱ្យសង្គមមានសណ្តាប់ធ្នាប់

❖ អំណាចដែលច្បាប់ឱ្យយើងពុំមែនជាអំណាចធម្មតាឡើយ តែជាសីលអំណាចមួយ ។ សីលអំណាចមានន័យថ្មុយពី អំណាចរូបដែលជាអំណាចនៃកម្លាំង ហើយក៏មិនមែនជាអំណាចខាងសម្ភារៈនោះទេតែជាអំណាចផ្លូវគំនិតដែលស្ថិតនៅបរិសុទ្ធជានិច្ចទោះ ជាគេមិនទទួលស្គាល់ឬក៏គេជាន់ឈ្លីអំណាចនោះយ៉ាងណាក៏ដោយ។ ឧទាហរណ៍យើងមានសិទ្ធិក្នុង ការនិយាយដែលជាអំណាចច្បាប់ឱ្យដល់យើង។

5. គុណធម៌មានលក្ខណៈមិនដូចគ្នាដូចគ្នាទេតែតម្លៃនៃគុណធម៌មានតែមួយគត់ ។

❖ គុណធម៌ចែកជាចេញជាពីរគឺ ៖

- គុណធម៌បញ្ញា ជាគុណធម៌ដែលធ្វើឱ្យមនុស្ស យើងមានបញ្ញារិះគិតក្នុងផ្លូវល្អដើម្បីកសាងសច្ចៈ ដូច សិល្បៈ ល្បែង បម្រង់ប្រយ័ត្ន គតិវិញ្ញូ បញ្ញាជាដើម
- សីលគុណធម៌ ជាគុណធម៌ដែលមាននៅក្នុងទំលាប់ដែលគ្រប់សង្កត់លើសម្ពុះជម្រុញវិចារណញ្ញាណនិងក្នុងទំលាប់ប្រព្រឹត្តអំពើល្អ ត្រឹមត្រូវ សមរម្យ ទោះជាស្ថិតនៅក្នុងកាលៈទេសៈណាក៏ ដោយក៏ដូចជាសេចក្តីក្លាហានចេះប្រមាណ យុត្តិធម៌និងវិញ្ញូគតិ ។

6. ករណីយកិច្ចមានលក្ខណៈ សំខាន់គឺធ្វើឱ្យមនុស្សមានការគោរពសិទ្ធិគ្នាទៅវិញទៅមក និងធ្វើឱ្យការងារបានជោគជ័យ។

7. ឆន្ទៈ គឺជាសមត្ថភាពដែលគ្រប់គ្រងគំនិតនិងអំពើរបស់មនុស្សដើម្បីសម្រេចនូវអ្វីដែលគេចង់ធ្វើឬជាអារម្មណ៍ នៃការប្តេជ្ញាចិត្តម៉ឹងម៉ាត់ក្នុងកាធ្វើអ្វីមួយដែលគេចង់ធ្វើ។

❖ ដើម្បីឆន្ទៈមានសមត្ថភាពល្អគេត្រូវផ្អែកលើកត្តា

- កត្តាគោលបំណង
- កត្តចំណង់
- កត្តាល្បិច
- មធ្យោបាយ
- ការតស៊ូផ្ទៃកខាងក្នុងរបស់មនុស្ស ។

8. នៅអឺរ៉ុបពេលជួបគ្នាគេចាប់ដៃគ្នា គេថើបគ្នា នៅប្រទេសមួយចំនួននៅអាស៊ីពេលជួបគ្នាគេ សំពះគ្នាយ៉ាងទន់ភ្លន់។ បានជាសីលនិយាមនិងសីលញាណខុសគ្នាបែបនេះព្រោះ ដោយសារមនុស្សរស់នៅទីកន្លែងផ្សេងៗគ្នា ហើយការទទួលនូវការបង្រៀនផ្សេងៗគ្នានិងមជ្ឈដ្ឋានដែលមនុស្សរស់នៅក៏ខុសគ្នាទៀត។ គេទទួលវប្បធម៌ប្រពៃណីពីឪពុកម្តាយរបស់ពួកគេតាំងពីកំណើតម្លេះ ។

9. បញ្ញាភ្លឺថ្លា និងឆន្ទៈមោះមុតស្ថិតតែក្នុងរាងកាយមាំមួន និងសុខភាពល្អ

- ទាល់តែមនុស្សមានសុខភាពល្អទើបមានឆន្ទៈក្នុងការធ្វើអ្វីមួយបាន

- បើយើងមិនឈឺគឺយើងមានការគិតបានល្អ
  - ❖ ឧទាហរណ៍ មនុស្សឈឺមានការគិតមិនបានល្អទេ ហើយឆន្ទៈក៏ថយចុះដែរ។

---

## ជំពូកទី២ វប្បធម៌សន្តិភាព

## មេរៀនទី១ មង្គល៣៨ប្រការ

### សំណួរ

1. ដូចម្ដេចហៅថា មង្គល? មង្គល៣៨ប្រការ? ចូរពន្យល់ដោយលើកឧទាហរណ៍បញ្ជាក់។
2. តើបុព្វហេតុអ្វីដែលនាំឱ្យកើតមានមង្គល៣៨ ប្រការនេះ?
3. តើមង្គល៣៨ប្រការ មង្គលណាប្រសើរជាង មង្គលណា? ហេតុអ្វី? ចូរពន្យល់។
4. ចូរសង្កេតពីសកម្មភាពរស់នៅ របស់អ្នកភូមិរបស់ប្អូន តើមានអ្នកភូមិប្រហែលប៉ុន្មានភាគរយ ដែលប្រតិបត្តិបានតាមមង្គលទាំង៣៨ ប្រការនេះ?
5. ដើម្បីឱ្យមង្គលទាំង៣៨ប្រការ បានជ្រាបដល់សហគមន៍តើអ្នកធ្វើដូចម្ដេច?
6. តើមង្គល៣៨ប្រការមានសារៈសំខាន់អ្វីខ្លះ ដល់អ្នកគ្រួសារ និងសហគមន៍របស់អ្នក?

### ចម្លើយ

1. មង្គល គឺជាសេចក្តីចម្រើនប្រកបដោយសេចក្តីសុខសួស្តី ដែលមនុស្សទាំងអស់ក្នុងលោកចង់បាន។

❖ មង្គល៣៨ប្រការគឺជាសេចក្តីចម្រើនប្រកបដោយសុខ ដែលកើតឡើងពីការប្រតិបត្តិតាមទ្រឹស្តីរបស់ព្រះពុទ្ធសាសនា។

★ ១. **គឺកិរិយាមិនសេពគប់បុគ្គលពាលទាំងឡាយ** មានន័យថា យើងនឹងបានមង្គលដ៏ឧត្តម បើយើងមិនទៅសេពគប់នឹងបុគ្គលពាល។**ឧទាហរណ៍** យើងមានមិត្តល្អគឺមិត្តល្អនេះហើយដែលជាមង្គលដ៏ប្រសើរសម្រាប់យើង។

2. បុព្វហេតុដែលនាំឱ្យកើតមានមង្គល៣៨ ប្រការគឺកាលពីដើមឡើយមានអាចារ្យមួយក្រុមបានជជែក គ្នាពីរឿងមង្គលដោយអាចារ្យខ្លះប្រកាន់ថា ការឃើញដោយភ្នែកគឺជាមង្គល ខ្លះទៀតប្រកាន់ថាការឮដោយត្រចៀកគឺជាមង្គល និងខ្លះទៀតប្រកាន់ថាកាដឹងរស់ ជាតិគឺជាមង្គល ។ ការជជែកគ្នាពុំមានការយល់ស្របគ្នា ឡើយ។អស់រយ:ពេល12ឆ្នាំក្រុមនីមួយៗស្វែងរកមង្គលមិនឃើញ។ ទេវតាទាំងឡាយក៏នាំគ្នាសួរព្រះឥន្ទ្រាធិរាជដើម្បីរកមង្គល ។ បន្ទាប់ពីសាកសួរបុព្វហេតុនិងដឹងពីហេតុផលចប់សព្វគ្រប់ហើយ ព្រះឥន្ទ្រប្រាប់ទេវតាទាំងនោះរឿងនេះថាកើតឡើងនៅឋានមនុស្ស ដូច្នេះអ្នកទាំងឡាយចូរនាំគ្នាទៅក្រាបបង្គំទូលសួរមង្គលនេះ ក្នុងសំណាក់ព្រះពុទ្ធជាម្ចាស់នៅវត្តជេតពនចុះ ព្រះអង្គនឹងសម្តែងប្រាប់ហើយ ។ ដូចនេះហើយ ទើបមានមង្គល38ប្រការ ។

3. មង្គល៣៨ប្រការ មង្គលដែលប្រសើរជាងគឺវិន័យដែលបុគ្គលសិក្សាដោយប្រពៃហើយ ព្រោះថាកាលណាមនុស្សមានវិន័យទាំងនេះគឺមានន័យថាមនុស្សនោះបានប្រកាន់នូវ សីលប្រាំ។ ការប្រកាន់នូវសីលប្រាំគឺជាការប្រពៃបំផុត។

4. ដើម្បីឱ្យមង្គលទាំង៣៨ប្រការបានជ្រាបដល់ សហគមន៍យើងត្រូវ៖

- ផ្សព្វផ្សាយដល់សារៀន
- ប្រឹងប្រែងអនុវត្តន៍តាមដោយខ្លាប់ខ្លួន
- និមន្តព្រះសង្ឃឱ្យទេសនាប្រាប់
- ចុះណែនាំដល់សហគមន៍អំពីមង្គល38 ប្រការ

5. មង្គល៣៨ប្រការមានសារៈសំខាន់ដល់ខ្ញុំ គ្រួសារ និងសហគមន៍របស់ខ្ញុំដូចជា៖

- រស់នៅក្នុងសេចក្ដីថ្លៃថ្នូរ
- មានការតស៊ូប្រឹងប្រែងរៀនសូត្រ
- ចេះចែករំលែក

❖ គ្រួសារ

- រស់នៅចេះស្រលាញ់គ្នា គ្រួសារមានសុភមង្គល
- ប្រឹងប្រែងកសាងគ្រួសារ
- អប់រំណែនាំកូនចៅបានល្អ

❖ សង្គម

- ប្រទេសសន្តិភាព
- សង្គមមានការរីកចម្រើន

- លប់បំបាត់ជម្លោះ សង្គ្រាម និងបញ្ហាជាច្រើនទៀត ។

## មេរៀនទី២ ភាពចុះសម្រុងរវាងសាសនាទាំងឡាយ

### សំណួរ

I. ចូរគូសសញ្ញា✓ក្នុងប្រអប់ ដែលមានចម្លើយត្រូវតែមួយគត់ ៖

1. សាសនាដែលដឹកនាំមនុស្ស ឱ្យមានជំនឿលើខ្លួនឯង ហើយចៀសវាងកុំឱ្យមានជំនឿលើអរូបី គឺ

☑ក.សាសនាព្រះពុទ្ធ ☐ខ.សាសនាគ្រិស្ត

☐គ.សាសនាឥស្លាម ☐ឃ.សាសនាហិណ្ឌូ។

2. សាសនាដែលដឹកនាំមនុស្ស ឱ្យមានជំនឿលើអទិទេព ហើយរាល់កំហុស ដែលមនុស្សបានធ្វើគឺព្រះព្រមទទួលយកទាំងអស់គឺ

☐ក.សាសនាព្រះពុទ្ធ ☑ខ.សាសនាគ្រិស្ត

☐គ.សាសនាឥស្លាម ☐ឃ.សាសនាហិណ្ឌូ។

3. សាសនាព្រះពុទ្ធបាននាំចូលមកប្រទេសកម្ពុជាយើងនៅ

☐ក.ស.វទី១ មុនគ.ស. ☐ខ.ស.វទី១ នៃគ.ស.

☐គ.ស.វទី២ មុនគ.ស. ☑ឃ.ស.វទី២ នៃគ.ស.

II. សំណួរត្រិះរិះ

1. នៅលើពិភពលោក តើមានសាសនាធំៗទាំងអស់ចំនួនប៉ុន្មាន ? តើប្រជាជនកម្ពុជាភាគច្រើនគោរពសាសនាអ្វី ?

2. តើសាសនាទាំងអស់នៅលើពិភពលោក តែងតែអប់រំមនុស្សដូចម្តេចខ្លះ ?
3. តើរាល់ការអប់រំរបស់សាសនា គេតែងតែសង្កត់ធ្ងន់ទៅលើអ្វី?
4. តើគោលការណ៍ចំបង ក្នុងការអប់រំរបស់សាសនាទាំងអស់មានគោលបំណងដូចម្តេចខ្លះ ?
5. ក្នុងនាមអ្នកជាអ្នកកាន់សាសនាមួយរូប តើអ្នកយល់យ៉ាងណាដែរក្នុងការប្រកាន់ជំនឿសាសនារបស់ខ្លួន ?
6. តើការចេះអព្យាស្រ័យខាងសាសនា នាំមកនូវគុណសម្បត្តិនិងគុណវិបត្តិដូចម្តេចខ្លះចំពោះ អ្នកនិងសង្គម ?

## II. ចម្លើយ

1. នៅលើពិភពលោក សាសនាធំៗទាំងអស់មានចំនួន 5 គឺ

- ព្រះពុទ្ធសាសនា
- គ្រិស្តសាសនា
- អ៊ីស្លាមសាសនា
- សាសនាតៅ និង
- សាសនាអ័រត្វដុក ។

❖ ប្រជាជនកម្ពុជាភាគច្រើនគោរពសាសនាព្រះពុទ្ធ ។

2. សាសនាទាំងអស់នៅលើពិភពលោក តែងតែអប់រំមនុស្សឱ្យប្រព្រឹត្តអំពើល្អ ចៀសវាងការប្រព្រឹត្តអំពើអាក្រក់ ។

3. រាល់ការអប់រំរបស់សាសនា គេតែងតែសង្កត់ធ្ងន់ទៅលើតម្លៃសីលធម៌ ចរិយាធម៌ កិច្ចសហការនិងរួបរួមគ្នាឱ្យកាន់តែខ្លាំងក្លា ។

4. គោលការណ៍ចំបង ក្នុងការអប់រំរបស់សាសនាទាំងអស់មានគោលបំណងរកដំណោះស្រាយតាមរយៈ សាសនា និងអភិវឌ្ឍន៍ផ្លូវចិត្តរបស់មនុស្ស ដោយប្រើគោលការសាសនាដើម្បីស្វែងរកសន្តិភាព ។

5. ក្នុងនាមខ្ញុំជាអ្នកកាន់សាសនាមួយរូប ខ្ញុំយល់ថាសាសនាមានសារៈសំខាន់ណាស់ក្នុងការធ្វើឱ្យខ្ញុំមានការរស់នៅ។ ពេលដែលខ្ញុំមានការអស់សង្ឃឹម សាសនាតែងតែធ្វើឱ្យខ្ញុំមានការទុកចិត្តនិងសទ្ធានិងលះបង់នូវភាពលោភលន់មិនគិតពីអ្នកដទៃ។ សម្រាប់សាសនាផ្សេងៗដែលអ្នកដទៃកាន់ខ្ញុំយល់ថា វាជាការល្អសម្រាប់គេ ហើយខ្ញុំដឹងថាសាសនាមានការទូន្មានអប់រំឱ្យធ្វើអំពើល្អជានិច្ច គឺមិនត្រូវរើសអើងគ្នានោះទេ ត្រូវចេះអធ្យាស្រ័យគ្នា នោះនឹងបានសុខសន្តិភាពក្នុងនាមយើងជាប្រជាពលរដ្ឋមួយរូបរស់នៅលើផែនដីនេះ។

6. ការចេះអធ្យាស្រ័យខាងសាសនា នាំមកនូវគុណសម្បត្តិនិងគុណវិបត្តិដូចម្តេចខ្លះចំពោះ អ្នកនិងសង្គមដូចជា ៖

## ❖ គុណសម្បត្តិ

- ធ្វើឱ្យមនុស្សចេះគោរពស្រលាញ់គ្នា

- រកដំណោះស្រាយចំពោះបញ្ហាដែលកើតមាននៅក្នុងសង្គម

❖ **គុណវិបត្តិ**

- ការហូចូលនៃវប្បធម៌សាសនាផ្សេងៗដែលធ្វើឱ្យបាត់ បង់សាសនារបស់រដ្ឋ
  - ជនខិលខូចយកសាសនាធ្វើជាបង្អែកក្នុងការប្រព្រឹត្តអំពើផ្សេងៗ

---

## មេរៀនទី៣ សីលធម៌សកល

### <u>សំណួរ</u>

1. ចូរពណ៌នាពីប្រវត្តិនិងនិយមន័យនៃសីលធម៌ សកល។
2. ចូរពណ៌នាពីខ្លឹមសារមូលដ្ឋាននៃសីលធម៌ សកល។
3. ចូរពណ៌នាពីភាពចាំបាច់នៃសីលធម៌សកល ក្នុងការកសាងសណ្តាប់ធ្នាប់សកល។
4. តើយើងត្រូវធ្វើអ្វីខ្លះដើម្បីទទួលបានសីលធម៌ សកល?

### <u>ចម្លើយ</u>

1. ពណ៌នាពីប្រវត្តិ

   នៅក្នុងគំនិតស្តីពីដំណើរនៃសកលភាវូបនីយកម្ម សាសនវិទូរ៉ូម៉ាំងកាតូលិក និងជាសាស្ត្រាចារ្យនិងទស្សនៈវិទូដ៏ល្បីល្បាញឈ្មោះ**ហាន្ស គុង** កំណត់ថា សីលធម៌របស់មនុស្សជាតិជាសីលធម៌សកលលោក ។សីលធម៌សកល ត្រូវបាន

គេទទួលយក ចាប់តាំងពីមានសេចក្ដីប្រកាសអំពីសីលធម៌សកលដោយ សភានៃសាសនាពិភពលោកកាលពីថ្ងៃទី 4 ខែកញ្ញា ឆ្នាំ 1993 ។

❖ សីលធម៌សកល សំដៅលើតម្លៃសីលធម៌រួមនិងគំរូសីលធម៌ដែលផ្សំឡើងពីវប្បធម៌ និងជំនឿផ្សេងៗនៅលើភពផែនដីនេះ។តម្លៃសីលធម៌រួមនិងគំរូសីលធម៌ ទាំងនេះបង្កើតបានជាសីលធម៌របស់មនុស្សជាតិ ។

2. ពណ៌នាពីខ្លឹមសារមូលដ្ឋាននៃសីលធម៌សកល

តាមពិតឫសគល់នៃការយល់ស្របជាមូលដ្ឋាន គឺតម្លៃគំរូនិងឥរិយាបថ ដែលមានលក្ខណៈសាមញ្ញ ប៉ុន្តែសំខាន់បំផុត "ចូរអ្នកប្រព្រឹត្តចំពោះអ្នកដទៃដូចដែលអ្នក ចង់ឱ្យគេប្រព្រឹត្តមកលើអ្នក" ។ នេះជាច្បាប់មាសនៃជីវិត គឺជានាមសីលធម៌រួមដ៏សំខាន់បំផុតរបស់ប្រព័ន្ធជំនឿ សាសនា និងប្រព័ន្ធមិនមែនសាសនាទាំងអស់នៅលើ ផែនដីយើងនេះ។ វាជាច្បាប់មូលដ្ឋាននៃការរស់នៅរបស់មនុស្សប្រកបដោយសន្តិភាពដូចនេះគេអាចចាត់ទុកថាជាមាតានៃសសីលធម៌មនុស្សជាតិ ។

3. ពណ៌នាពីភាពចាំបាច់នៃសីលធម៌សកល ក្នុងការកសាងសណ្ដាប់ធ្នាប់សកល

- យើងទាំងអស់គ្នា មានទំនួលខុសត្រូវចំពោះសណ្ដាប់ធ្នាប់សកលមួយដ៏ប្រសើរ
- ការចូលរួមរបស់យើង គឺជាភារៈចាំបាច់បំផុតដើម្បីស្វែ

4. ដើម្បីទទួលបានសីលធម៌ សកលយើងត្រូវ ៖

- ពឹងពាក់គ្នាទៅវិញទៅមក
- ទទួសខុសត្រូវរៀងៗខ្លួននូវរាល់អ្វីដែលយើងបានធ្វើ
- ត្រូវប្រព្រឹត្តចំពោះគ្នាដូចបងប្អូន
- ប្តេជ្ញាគោរពជីវិតនិងសេចក្តីថ្លៃថ្នូរមនុស្សជាតិ
- សន្សាបង្កើនការយល់ដឹងរបស់យើង តាមរយៈការគ្រប់គ្រងសតិរបស់យើង ការធ្វើសមាធិ
- ការយោគយល់គ្នា លើកកម្ពស់សន្តិភាព។

## មេរៀនទី៩ កំណើតសិទ្ធិមនុស្ស

### សំណួរ

1. ដូចម្តេចហៅថា សិទ្ធិមនុស្ស?
2. តើសិទ្ធិមនុស្សត្រូវបានទទួលស្គាល់ដោយ អង្គការសហប្រជាជាតិចាប់ពីពេលណាមក?
3. តើសិទ្ធិ និងសេរីភាពសំខាន់ៗរបស់មនុស្សទូទៅមានអ្វីខ្លះ?
4. ចូរនិយាយពីមនុស្សទាំងអស់មានសិទ្ធិស្មើគ្នា ចំពោះច្បាប់សីលធម៌។
5. តើសិទ្ធិចែកចេញជាប៉ុន្មាន? អ្វីខ្លះ?
6. ដូចម្តេចហៅថា ច្បាប់? ច្បាប់ធម្មជាតិ? ច្បាប់ អមតៈ? ច្បាប់វិជ្ជមាន?

### ចម្លើយ

1. សិទ្ធិមនុស្សគឺ [redacted] ជា អំណាចដែលមិនត្រូវគេរំលោភបានក្នុងការកាន់កាប់ការធ្វើ ឬការទាមទារអ្វីមួយពីនរណាម្នាក់។
2. សិទ្ធិមនុស្ស ត្រូវបានទទួលស្គាល់ដោយអង្គការសហប្រជាជាតិចាប់ពីពេលថ្ងៃទី 10ធ្នូ 1948។

3. សិទ្ធិ និងសេរីភាពសំខាន់ៗ របស់មនុស្សទូទៅមាន

❖ **សិទ្ធិ** សំខាន់ៗមាន សិទ្ធិមានជីវិតរស់នៅ សិទ្ធិចិញ្ចឹមជីវិត សិទ្ធិទទួលការអប់រំ។

❖ **សេរីភាព** មានសេរីភាពក្នុងការដើរហើដោយសេរី សេរីភាពក្នុងការនិយាយស្តី សេរីភាពក្នុងការទទួលពត៌មាន សេរីភាពក្នុងការជួបប្រជុំ សេរីភាពក្នុងការបោះឆ្នោត...។

4. និយាយពីមនុស្សទាំងអស់មានសិទ្ធិស្មើគ្នា ចំពោះច្បាប់សីលធម៌៖

មនុស្សទាំងអស់មានសិទ្ធិស្មើគ្នា ចំពោះមុខច្បាប់សីលធម៌ ។ មនុស្សមានសិទ្ធិក្នុងការធ្វើអ្វីៗទាំង អស់ដែលខ្លួនចង់ធ្វើ ប៉ុន្តែមិនត្រូវឱ្យប៉ះពាល់ដល់សិទ្ធិ របស់អ្នកដ៏ទៃនោះទេ ព្រោះគេក៏មានសិទ្ធិដូចគ្នាដែរ ។ ការប្រព្រឹត្តរបស់មនុស្សគឺស្ថិតនៅក្រោមច្បាប់រដ្ឋ ។

5. សិទ្ធិចែកចេញជាពីរគឺ

- សិទ្ធិស្របច្បាប់នៃ[redacted]
- សិទ្ធិធម្មជាតិរបស់មនុស្ស ។

6. ច្បាប់ គឺជាបទបញ្ញត្តិដែលកំណត់សេរីភាពរបស់មនុស្សវាត្រូវបានបង្កើតដោយមនុស្សដើម្បីការពារនិងដាក់ទោសមនុស្ស។

- **ច្បាប់ធម្មជាតិ** គឺជាច្បាប់មួយប្រភេទដែលគេប្រកាសឱ្យប្រើប្រាស់តាមរយៈពន្លឺនៃវាចារណញ្ញាណ។
- **ច្បាប់អមតៈ** ជាច្បាប់ដែលគេប្រកាសឱ្យប្រើប្រាស់ជាអមតៈ

• ច្បាប់វិជ្ជមាន ជាបញ្ញត្តិមួយយ៉ាងសំខាន់នៅក្នុងទស្សនៈ វិជ្ជាសីលធម៌។

---

## មេរៀនទី៥ ច្បាប់អន្តរជាតិអំពីសិទ្ធិមនុស្ស

### សំណួរ

1. ដូចម្តេចហៅថា សិទ្ធិមនុស្ស? តើហេតុអ្វីបានជាកើតមានសិទ្ធិមនុស្ស?
2. តើការអនុវត្តសិទ្ធិមនុស្សមានសារប្រយោជន៍ អ្វីខ្លះ?
3. ចូររៀបរាប់ពីសិទ្ធិក្នុងការអភិវឌ្ឍរបស់មនុស្ស។

### ចម្លើយ

1. សិទ្ធិមនុស្សគឺជាអំណាចខាងសីលធម៌ និងជាអំណាចដែលមិនត្រូវគេរំលោភបានក្នុងការកាន់កាប់ការធ្វើ ឬការទាមទារអ្វីមួយពីនរណាម្នាក់។

❖ បានជាកើតមានសិទ្ធិមនុស្សព្រោះដោយសារ ៖

- មានមហន្តរាយនៃសង្គ្រាមកន្លងមក
- ការប្រកាន់ពូជសាសន៍
- ការគ្មានកិច្ចសហការរវាងប្រជាជាតិនានា
- ការប្រើសេរីភាពហួសព្រំដែនច្បាប់រំលោភសិទ្ធិមនុស្ស ។

2. ការអនុវត្តសិទ្ធិមនុស្សមានសារប្រយោជន៍ដូចជា ៖

- នាំឱ្យប្រជាជាតិនានាមានសន្តិភាព សេរីភាព
- កាត់បន្ថយនិងរំសាយសព្វាវុធ
- លប់បំបាត់ការគេងប្រវ័ញ្ច ការប្រកាន់ពូជសាសន៍

- បង្កើនកិច្ចសហប្រតិបត្តិការណ៍អន្តរជាតិ
- លប់បំបាត់សង្គ្រាម ។

3. សិទ្ធិក្នុងការអភិវឌ្ឍរបស់មនុស្សមាន ៖

❖ សិទ្ធិដើម្បីមានចំណេះដឹង

❖ សិទ្ធិនយោបាយ

- សិទ្ធិបញ្ចេញមតិដោយសេរី
- សិទ្ធិប្រជុំដោយសេរី
- សិទ្ធិបង្កើតសមាគមដោយសេរី
- សិទ្ធិបោះឆ្នោត
- សិទ្ធិចូលរួមក្នុងឆាកនយោបាយ
- សិទ្ធិបោះឆ្នោតដោយសេរីនិងទៀងទាត់
- សិទ្ធិមានលទ្ធភាពស្មើគ្នាចំពោះសេវាកម្មសាធារណៈ

❖ សិទ្ធិសេដ្ឋកិច្ចសង្គមនិងវប្បធម៌

- សិទ្ធិមានការងារធ្វើ
- សិទ្ធិជ្រើសរើសការងារធ្វើ
- សិទ្ធិមានទ្រព្យសម្បត្តិជាកម្មសិទ្ធិ
- សិទ្ធិមានកម្រិតជីវភាពរស់នៅសមរម្យ
- សិទ្ធិមានលទ្ធភាពក្នុងការសិក្សា
- សិទ្ធិបង្កើតគ្រួសារ
- សិទ្ធិមានសន្តិសុខសង្គម
- សិទ្ធិមានការធានារ៉ាប់រង ។

# មេរៀនទី៦

## ទំនាក់ទំនងសេដ្ឋកិច្ចនិងសកលភាវូបនីយកម្ម

### សំណួរ

1. ដូចម្តេចហៅថា ទំនាក់ទំនងសេដ្ឋកិច្ច?
2. ចូរនិយាយពីសកលភាវូបនីយកម្ម និងតួនាទីរបស់វា។
3. ចូរបរិយាយពីធនាគារពិភពលោក និងតួនាទី របស់វា។

### ចម្លើយ

1. ទំនាក់ទំនងសេដ្ឋកិច្ច គឺជាដំណើរការនៃការទាក់ទងផ្នែកសេដ្ឋកិច្ចជាតិជាមួយសេដ្ឋកិច្ចអន្តរជាតិ ជាពិសេសជាមួយប្រទេសជិតខាង ប្រទេសក្នុងតំបន់ប្រទេសនានានៅលើពិភពលោក និងអង្គការអន្តរជាតិផ្សេងៗទៀត ។
2. និយាយពីសកលភាវូបនីយកម្ម

សកលភាវូបនីយកម្ម គឺជាដំណើរមួយដែលសេដ្ឋកិច្ចសង្គមនិងវប្បធម៌ តំបន់និងពិភពលោកបានរលាយចូលគ្នាតាមរយៈបណ្តាញទំនាក់ទំនងនិងពាណិជ្ជកម្ម។ជួនកាលគេសំដៅយកសកលភាវូបនីយកម្ម សេដ្ឋកិច្ច ដែលមានន័យថាការបញ្ចូលសេដ្ឋកិច្ចជាតិទៅក្នុងសេដ្ឋកិច្ចអន្តរជាតិតាមរយៈពាណិជ្ជកម្ម ការវិនិយោគ ពីបរទេស ការហូចូលនូវមូលធនអន្តោប្រវេសន៍និង ការរាលដាលនៃបច្ចេកវិទ្យា។ វាក្យស័ព្ទនេះក៏គ្របដណ្តប់ផងដែរទៅលើការផ្សព្វផ្សាយនូវ គំនិត

ភាសា ឬវប្បធម៌ពេញនិយមពីប្រទេសមួយទៅប្រទេសមួយតាមរយៈការយកលំនាំតាម។

❖ តួនាទីរបស់សកលភាវូបនីយកម្ម

- បង្កើនទំហំសេដ្ឋកិច្ច
- ថែរក្សាបរិស្ថាន
- ទប់ស្កាត់ភេរវកម្ម ឧក្រិដ្ឋកម្ម អំពើហិង្សា
- កាត់បន្ថយភាពក្រីក្រ
- ផ្សព្វផ្សាយអំពីចំនេះដឹងអភិវឌ្ឍន៍ វប្បធម៌ ។

3. បរិយាយពីធនាគារពិភពលោក

ធនាគារពិភពលោក ជាពាក្យស័ព្ទមួយដែលគេប្រើដើម្បីរៀបរាប់ពីស្ថាប័នហិរញ្ញវត្ថុអន្តរជាតិមួយដែលផ្តល់ប្រាក់កម្ចីឬផ្តល់ឥណទានដល់ប្រទេសកំពុងអភិវឌ្ឍន៍សម្រាប់កម្មវិធីសំខាន់ៗ ។ធនាគារពិភពលោកមាន គោលដៅច្បាស់លាស់លើការកាត់បន្ថយភាពក្រីក្រ។ ធនាគារពិភពលោកខុសពីក្រុមធនាគារពិភពលោកត្រង់ ថា ធនាគាពិភពលោកមានស្ថាប័នតែពីរ គឺ ធនាគារអន្តរជាតិ សម្រាប់ការស្តារឡើងវិញនិងការអភិវឌ្ឍ និងសមាគមអភិវឌ្ឍន៍អន្តរជាតិ ទីភ្នាក់ងារធានារ៉ាប់រងវិនិយោគទុនពហុភាគីនិងមជ្ឈមណ្ឌលអន្តរជាតិ សម្រាប់ការដោះស្រាយវិវាទវិនិយោគទុន។

❖ តួនាទី របស់ធនាគារពិភពលោក

- ផ្តល់ប្រាក់កម្ចី ឬឥណទានដល់ប្រទេសនានាសម្រាប់គំរោងសំខាន់ៗដើម្បីអភិវឌ្ឍសេដ្ឋកិច្ចនៃប្រទេសជាសមាជិក
- ផ្តល់ប្រាក់ជំនួយ សម្រាប់គម្រោងជំនួយដល់ប្រទេសកំពុងអភិវឌ្ឍន៍និងប្រទេសអន្តរកាល
- ជួយផ្នែកបច្ចេកទេសក្នុងករណីដែលប្រទេស និងផ្នែកឯកជនធ្វើឡើង ដើម្បីកាត់បន្ថយភាពក្រីក្រនៅក្នុងប្រទេសកំពង់អភិវឌ្ឍន៍និងប្រទេសអន្តរកាល។

---

## មេរៀនទី៧

# សេចក្តីប្រកាសអំពីសិទ្ធិក្នុងការ អភិវឌ្ឍរបស់អង្គការសហប្រជាជាតិ

## សំណួរ

1. អ្វីជាកតិកាសញ្ញាអន្តរជាតិ ស្តីពីសិទ្ធិ សេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌?
2. ហេតុអ្វីបានជាកើតមានកតិកាសញ្ញាអន្តរជាតិ?
3. កតិកាសញ្ញាអន្តរជាតិ ស្តីពីសិទ្ធិ សេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ មានសារៈសំខាន់អ្វីខ្លះ?
4. ចូរពន្យល់ដោយសង្ខេបអំពីខ្លឹមសារមាត្រា នៃកតិកាសញ្ញាអន្តរជាតិស្តីពីសេដ្ឋកិច្ច សង្គម កិច្ច និងវប្បធម៌។

5. ចូរពន្យល់ពីទំនាក់ទំនងរវាងកតិកាសញ្ញាអន្តរ ជាតិជាមួយនឹងទស្សនវិស័យពុទ្ធសាសនាស្តីពី សិទ្ធិសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌។

## ចម្លើយ

1. កតិកាសញ្ញាអន្តរជាតិ ស្តីពីសិទ្ធិ សេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ គឺជាស្ថាប័នមួយដែលបង្កើតឡើងដើម្បីធានាសន្តិភាព ប្រឆាំងនឹងការរើសអើង ការប្រកាន់ពូជសាសន៍។

2. បានជាកើតមានកតិកាសញ្ញាអន្តរជាតិ

- មានការរើសអើង
- ការប្រកាន់ពូជសាសន៍
- អតុល្យភាពនៃកម្រិតសុខភាពប្រជាពលរដ្ឋក្នុងពិភពលោក
- អតុល្យភាពនៃការអប់រំ
- ការមិនទទួលបានសិទ្ធិសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌
- ប្រទេសនានាមិនបានអនុវត្តន៍ធ្វើឱ្យមានការប្រសើរ

3. កតិកាសញ្ញាអន្តរជាតិ ស្តីពីសិទ្ធិ សេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ មានសារៈសំខាន់ដូចជា ៖

- ចូលរួមក្នុងជីវភាពវប្បធម៌
- ទទួលអត្ថប្រយោជន៍ពីវឌ្ឍនភាពនិងការអនុវត្តចិត្តសាស្ត្រ

- ទទួលអត្ថប្រយោជន៍ពីការការពារ ផលប្រយោជន៍ខាង សីលធម៌និងខាងសម្ភារៈ ដែលកើតពីផលិតកម្មខាងវិទ្យាសាស្ត្រ អក្សរសាស្ត្រឬសិល្បៈដែលខ្លួនជាអ្នកបង្កើត។

4. ពន្យល់ដោយសង្ខេបអំពីខ្លឹមសារមាត្រានៃ កតិកាសញ្ញាអន្តរជាតិស្តីពីសេដ្ឋកិច្ច សង្គម កិច្ច និងវប្បធម៌

- មាត្រា1 ប្រជាជាតិទាំងអស់មានសិទ្ធិស្វ័យសម្រេច។
- មាត្រា2 ប្រើប្រាស់ជាអតិបរមានូវធនធានដែលខ្លួនមាន។
- មាត្រា3 សិទ្ធិស្មើគ្នារវាងបុរសនិងស្ត្រី ។
- មាត្រា4 ក្នុងការទទួលនូវសិទ្ធិទាំងឡាយដែលធានាដោយរដ្ឋស្របតាមកតិការសញ្ញានេះ រដ្ឋអាចដាក់សិទ្ធិទាំងនេះឱ្យមានព្រំដែនកំណត់ដោយច្បាប់ប៉ុណ្ណោះ ។
- មាត្រា5 គ្មានបទបញ្ញត្តិណាមួយនៃកតិការសញ្ញានេះ ត្រូវបានបកស្រាយឱ្យខុសឡើយ ។
- មាត្រា6 សិទ្ធិធ្វើការងារ ។
- មាត្រា7 សិទ្ធិទទួលបានលក្ខខណ្ឌការងារត្រឹមត្រូវ ។
- មាត្រា8 សិទ្ធិទទួលបានសន្តិសុខសង្គម ព្រមទាំងការធានារ៉ាប់រងសង្គម ។
- មាត្រា9 កិច្ចគាំពារនិងជំនួយដ៏ទូលំទូលាយដែលអាចធ្វើទៅបាន ត្រូវផ្តល់ឱ្យដល់គ្រួសារ។
- មាត្រា10 ទទួលស្គាល់សិទ្ធិរបស់មនុស្សគ្រប់រូបក្នុងការទទួលបានជីវភាពគ្រប់គ្រាន់ ។

- មាត្រា11 ទទួលស្គាល់សិទ្ធិរបស់បុគ្គលគ្រប់រូបមានកម្រិតសុខភាពល្អ ។
- មាត្រា12 ទទួលសិទ្ធិបុគ្គលគ្រប់រូបដើម្បីទទួលការអប់រំ ។
- មាត្រា13 រដ្ឋភាគីទទួលស្គាលសិទ្ធិនៃបុគ្គល ។

5. ពន្យល់ពីទំនាក់ទំនងរវាងកតិកាសញ្ញាអន្តរជាតិ ជាមួយនឹងទស្សនវិស័យពុទ្ធសាសនាស្តីពី សិទ្ធិសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌

❖ ទស្សនៈវិស័យសេដ្ឋកិច្ច

ក. **សេដ្ឋកិច្ចជាន់ទាប**

- ការតាំងខ្លួននៅក្នុងឋានៈមាំទាំតាមផ្លូវសេដ្ឋកិច្ចប្រកបដោយអង្គ4 ប្រការ
    a) ការសំភីសង្វាតស្វែងរកទ្រព្យ
    b) ចេះសន្សំសំចៃ
    c) ចេះសេពគប់មិត្តល្អ
    d) ចេះចាយវាយដោយសមរម្យ
- ការវៀរចាកអបាយមុខ4 ប្រការដែលនាំឱ្យសូនទ្រព្យ
    a) ជាអ្នកប្រព្រឹត្តល្បែងស្រី
    b) ជាអ្នកប្រព្រឹត្តល្បែងស្រា
    c) ជាអ្នកប្រព្រឹត្តល្បែងស៊ីសង
    d) ជាអ្នកសេពគបមិត្តអាក្រក់
- ប្រកាន់យកនូវសុខ4 ប្រការ

a) សុខកើតអំពីទ្រព្យដែលបានដោយកម្លាំងធ្វើការផ្ទាល់ខ្លួន

b) សុខកើតពីការចាយវាយទ្រព្យសម្បត្តិផ្ទាល់ខ្លួន

c) សុខកើតពីការមិនជំពាក់បំណុលគេ

d) សុខកើតពីការប្រកបអាជីវកម្មដែលគ្មានទោស

ខ.សេដ្ឋកិច្ចជាន់ខ្ពស់

ដំបូងបង្អស់ មនុស្សត្រូវខំធ្វើសេដ្ឋកិច្ចគ្រប់យ៉ាងឱ្យមានវឌ្ឍនភាពនៅក្នុងកម្រិតមធ្យមរហូតដល់កម្រិតខ្ពស់ ដើម្បីសេចក្តីសុខស្រួលដល់ជីវិតរបស់ខ្លួន ។ យើងម្នាក់ៗត្រូវតែព្យាយាមធ្វើជាចៅហ្វាយនៃសេចក្តីត្រូវ ការមានន័យថាព្យាយាមលុះបានសម្រេច ។

❖ ទស្សនៈសង្គមកិច្ច

យកចិត្តទុកដាក់លើបញ្ចសីល។

❖ ទស្សនៈវប្បធម៌

តាមទស្សនៈរបស់ពុទ្ធសាសនា ជីវិតមនុស្សតែងប្រព្រឹត្តទៅតាមទ្វារបីយ៉ាងគឺ ចិត្ត កាយ និងវាចា។ រស់នៅជាបងប្អូនតែមួយ ។

មេរៀនទី៨

# សិទ្ធិមនុស្សតាមទស្សនវិស័យពុទ្ធសាសនា

## សំណួរ

I. ចូរគូសភ្ជាប់ចំណុច A ទៅនឹងចំណុច B ឱ្យបាន ត្រឹមត្រូវ

| ចំណុច A | ចំណុច B |
|---|---|
| ក.កុំសម្លាប់ជីវិតមនុស្សសត្វ (បាណា)<br>ខ.កុំលួចទ្រព្យសម្បត្តិ អ្នកដទៃ(អទិន្នា)<br>គ.កុំប្រព្រឹត្តខុសឆ្គងក្នុង ផ្លូវកាម(កាមេ)<br>ឃ.កុំភូតកុហកអ្នកដទៃ (មុសា)<br>ង.កុំសេពគ្រឿងញៀន និងគ្រឿងស្រវឹង(សុរា) | គ.ច្បាប់ពាំងមិនឱ្យមានការរំលោភបំពានលើ រូបរាងកាយបុគ្គលណាមួយ<br>ក.សិទ្ធិដើម្បីមានជីវិតរស់នៅមានសេរីភាពនិង សន្តិភាពផ្ទាល់ខ្លួន<br>ឃ.សិទ្ធិមានសេរីភាពក្នុងការនិយាយស្តីឬបញ្ចេញមតិ និងទទួលព័ត៌មានត្រឹមត្រូវ និងច្បាស់លាស់<br>ខ.សិទ្ធិមានទ្រព្យសម្បត្តិស្រប ច្បាប់ជាកម្មសិទ្ធិ<br>ង.សិទ្ធិការពារមិនឱ្យគេយក ទៅធ្វើជាទាសករ |

II. ចូរបំពេញឃ្លាខាងក្រោមឱ្យបានត្រឹមត្រូវៈ

1. សិទ្ធិមនុស្សបានណែនាំមនុស្សឱ្យរស់នៅ ក្នុងសេចក្តីស្រឡាញ់ជាបងប្អូនគឺ *មេត្តា*។
2. សិទ្ធិមនុស្សណែនាំមនុស្សឱ្យចេះអាណិតអាសូរគ្នាគឺ *ករុណា*។

3. សិទ្ធិមនុស្សណែនាំឱ្យមនុស្សមានឆន្ទៈគោរពច្បាប់របស់ប្រទេសគឺ *មុទិតា*។
4. សិទ្ធិមនុស្សណែនាំមនុស្ស ឱ្យមានចិត្តមោះមុតខាងសីលធម៌ និងមនុស្សធម៌គឺ *ឧបេក្ខា*។

III. សំណួរត្រិះរិះ

1. តើពុទ្ធសាសនា និងសិទ្ធិមនុស្សបានចូលរួមចំណែកក្នុងការរៀបចំសង្គមដូចម្ដេចខ្លះ?
2. តើព្រហ្មវិហារធម៌ទាំងបួនក្នុងពុទ្ធសាសនា ត្រូវគ្នានឹងទស្សនៈសិទ្ធិមនុស្សត្រង់ចំណុចណាខ្លះ?
3. តើយើងត្រូវចូលរួមលើកកម្ពស់ ផ្នែកសិទ្ធិមនុស្សដូចម្ដេចខ្លះ?

III. <u>ចម្លើយ</u>

1. ពុទ្ធសាសនា និងសិទ្ធិមនុស្សបានចូលរួមចំណែកក្នុងការរៀបចំសង្គមដូចជា ៖

- ឱ្យមនុស្សចេះស្រលាញ់គ្នាជាបងប្អូននៅលើផែនដីតែមួយ
- ចេះគោរពនិងចេះជួយគ្នាទៅវិញទៅមក
- លប់បំបាត់សង្គ្រាម លប់បំបាត់ការរើសអើង
- សង្គមមានសន្តិភាព
- រួមរស់ដោយសន្តិភាព និងចេះអភិវឌ្ឍន៍ឱ្យកាន់តែប្រសើរ

2. ព្រហ្មវិហារធម៌ទាំងបួនក្នុងពុទ្ធសាសនាត្រូវ គ្នានឹងទស្សនៈសិទ្ធិមនុស្ស ៖

- សិទ្ធិមនុស្សបានណែនាំមនុស្សឱ្យរស់នៅក្នុង សេចក្តីស្រឡាញ់ជាបងប្អូនគឺមេត្តា។
- សិទ្ធិមនុស្ស ណែនាំមនុស្សឱ្យចេះអាណិតអាសូរគ្នាគឺករុណា។
- សិទ្ធិមនុស្ស ណែនាំឱ្យមនុស្សមានឆន្ទៈគោរពច្បាប់របស់ប្រទេសគឺមុទិតា។
- សិទ្ធិមនុស្សណែនាំមនុស្សឱ្យមានចិត្តមោះមុត ខាងសីលធម៌ និងមនុស្សធម៌គឺឧបេក្ខា។

3. ដើម្បីចូលរួមលើកកម្ពស់ផ្នែកសិទ្ធិមនុស្សយើងត្រូវ

- ប្រកាន់នូវសីលប្រាំឱ្យបានខ្ជាប់ខ្ជួន
- ខិតខំធ្វើអំពើល្អចំពោះគ្នានិងគ្នា

# មេរៀនទី៩ សិទ្ធិជនជាតិផ្សេងៗនៅកម្ពុជា

## សំណួរ

1. តើនៅកម្ពុជាមានជនជាតិភាគតិចអ្វីខ្លះ? តើ ពួកគេរស់នៅ និងប្រកបរបរចិញ្ចឹមជីវិតដូចម្ដេច?
2. តើជនជាតិភាគតិចមានសិទ្ធិដូចម្ដេចខ្លះ?
3. តើរដ្ឋាភិបាលធ្វើដូចម្ដេចដើម្បីឆ្លើយតបទៅ នឹងតម្រូវការរបស់ជនជាតិភាគតិច?
4. តើអ្នកមានអារម្មណ៍បែបណានៅពេលដែលឃើញជនជាតិផ្សេងៗរស់នៅលើទឹកដីរបស់ អ្នក?
5. វត្តមាននៃជនជាតិផ្សេងៗនៅលើទឹកដីនៃប្រទេសណាមួយផ្តល់នូវគុណសម្បត្តិនិងគុណ វិបត្តិដូចម្ដេចខ្លះ?

## ចម្លើយ

1. នៅកម្ពុជាមានជនជាតិភាគតិចដូចជា

- **ជនជាតិចាម** រស់នៅតាមភូមិនានាខាងជើង និងខាងលិចរាជធានីភ្នំពេញជាពិសេសខេត្តកំពង់ចាម។ ជនជាតិចាមមានមុខរបរជាអ្នកជួញដូរ នេសាទត្រី សត្វយោត (គោ ក្របី) ឯស្ត្រីជាអ្នកតម្បាញនិងធ្វើឧបករណ៍នេសាទ ដូចជាចាកសំណាញ់ធ្វើមងអួនជាដើម។
- **ជនជាតិភាគតិចអំបូរខ្មែរមេន** រស់នៅតាមបណ្ដាខេត្តមួយចំនួននៃប្រទេសកម្ពុជា ដូចជា ខេត្តព្រះវិហារ ស្ទឹង ត្រែង រតនគិរី មណ្ឌលគិរី ក្រចេះ កំពង់ធំ សៀមរាប ពោធិ៍សាត់។

ពួកគេនិយាយភាសាផ្សេងៗគ្នា ហើយប្រកបរបរកសិកម្ម បេះផ្លែឈើ បរបាញ់សត្វ រកអនុផលព្រៃឈើ។

- ជនជាតិចិន ជនជាតិចិនបានភៀសខ្លួនមកនៅស្រុកខ្មែរតាំងពីសម័យមុនអង្គរម្លេះ។ជនជាតិកិនភាគច្រើន រស់នៅទីក្រុង ហើយរួមគ្នាបង្កើតជាសហាគមន៍ជនជាតិដ៏ធំ ។ ជនជាតិចិនភាគច្រើនជា ម្ចាស់សណ្ឋាគារ ភោជនីយដ្ឋាន ហាងលក់ទំនិញ ពាណិជ្ជករ។
- **ជនជាតិវៀតណាម** សហាគមន៍ជនជាតិវៀតណាម បានមករស់នៅកម្ពុជាច្រើនស.វមកហើយតាំងពីចុងស.វ16ៗពួកគេធ្វើការស្ទើរគ្រប់ផ្នែកក្នុងសង្គម ដូចជាសំណង់ ជាងម៉ាស៊ីន នេសាទត្រី។

2. ជនជាតិភាគតិចមានសិទ្ធិដូចដូចជា ៖

- អនុវត្តន៍គោរពសសនារបស់ខ្លួន ប្រើប្រាស់ភាសារបស់ខ្លួនដោយសេរី។
- ចូលរួមយ៉ាងសកម្មក្នុងជីវភាពវប្បធម៌ សាសនា សេដ្ឋកិច្ចនិងកិច្ចការសាធារណៈ។
- ចូលរួមធ្វើសេចក្ដីសម្រេចថ្នាក់ជាតិ ថ្នាក់តំបន់ស្ដីពីបញ្ហាដែលទាក់ទងនឹងជនជាតិភាគតិច ឱ្យស្របទៅតាមច្បាប់ប្រទេស។
- បង្កើតនិងថែរក្សាសហាគមន៍របស់ខ្លួនហើយមានទំនាក់ ទំនងដោយសេរី ដោយសន្តិវិធីជាមួយសមាជិកនៅក្នុងក្រុមរបស់ខ្លួននិងជាមួយក្រុមដ៏ទៃទៀត។

- អាចប្រើប្រាស់ដោយពេញលេញ និងដោយមានប្រសិទ្ធភាពនូវសិទ្ធិមនុស្សដោយគ្មានការបែងចែកហេតុ និងដោយស្មើភាពគ្នាចំពោះមុខច្បាប់។
- ទទួលចំណេះដឹងប្រវត្តិសាស្ត្រ ប្រពៃណី ភាសា និងវប្បធម៌ដែលមាននៅក្នុងដែនដីរបស់គេ។
- មានឱកាសគ្រប់គ្រាន់ក្នុងការរៀនសូត្រ ព្រោះបញ្ជក់យកចំណេះដឹងអំពីសង្គមទាំងមូល។

3. ដើម្បីឆ្លើយតបទៅ នឹងតម្រូវការរបស់ជនជាតិភាគតិចរដ្ឋាភិបាលបានរៀបចំ និងអនុម័តគោលនយោបាយស្តីពីជនជាតិដូចជា៖

- លប់បំបាត់ភាពរើសអើង និងបង្កើនការចូលរួមពីសំណាក់ជនជាតិភាគតិចក្នុងការធ្វើផែនការអភិវឌ្ឍនៅ មូលដ្ឋាននិងថ្នាក់ជាតិ ។
- ជំរុញឱ្យមានការចូលរួមពេញលេញ និងមានប្រសិទ្ធិភាពពីសំណាក់ជនជាតិភាគតិច ក្នុងការធ្វើសេចក្តីសម្រេចចិត្ត ។
- កំណត់គោលនយោបាយអភិវឌ្ឍន៍ស្របតាមវប្បធម៌ ប្រពៃណី ជំនឿនិងភាសារបស់ជនជាតិភាគតិច ។
- លើកទឹកចិត្តឱ្យមានអ្នកបកប្រែភាសាជនជាតិភាគតិច នៅពេលមានការជម្រះក្តីក្នុងតុលាការ ។
- ជំរុញការអប់រំដល់ជនជាតិភាគតិច ថែរក្សាសុខភាពនិងអនាម័យ ចូលរួមថែរក្សាការពារហេដ្ឋារចនាសម្ព័ន្ធ ដែលមានក្នុង

សហគមន៍ជនជាតិភាគតិច បង្កើនការយល់ដឹងអំពីច្បាប់និង គោលនយោបាយនានារបស់រាជរដ្ឋាភិបាល។

- ទទួលស្គាល់ការប្រើប្រាស់ដីជាលក្ខណៈសមូហភាព លើកទឹកចិត្តអាជ្ញាធរប្រពៃណីនៅនឹងកន្លែង ដើម្បីដោះស្រាយបញ្ហាឬទំនាស់នានាកក្នុងសហគមន៍របស់បងប្អូនជនជាតិភាគតិច ។
- ជំរុញឱ្យមានសេវាទេសចរណ៍ ក្នុងសហគមន៍របស់ជនជាតិភាគតិច ។
- ខិតខំរកជំនួយពីគ្រប់ដៃគូដើម្បីអភិវឌ្ឍជនជាតិភាគតិច ជាពិសេសស្ត្រីនិងកុមារដើម្បីលើកកម្ពស់កម្រិតជីវភាពគ្រួសារ ។
- បង្កើតសេវាកម្មផ្នែកសុខាភិបាល ចំពោះជនជាតិភាគតិចដែលនៅតំបន់ឆ្ងាយដាច់ស្រយាល ពិនិត្យការប្រើប្រាស់ថ្នាំសង្កូវបែបបុរាណរបស់ពួកគេ ។
- ជំរុញការអប់រំការថែរក្សាសុខភាពអម័យផ្ដត់ផ្គង់ទឹកស្អាត ការអប់រំ ការផ្លាស់ប្ដូរទម្លាប់ជាបណ្ដើរៗលើផ្នែក កសិកម្មឱ្យមានលក្ខណៈកាន់តែប្រសើរឡើង ។

4. នៅពេលដែល ឃើញជនជាតិផ្សេងៗរស់នៅលើទឹកដីរបស់ខ្ញុំៗយល់ថា នៅពេលដែលពួកគេរស់នៅដោយស្របច្បាប់ មិនបង្ករបញ្ហាផ្សេងៗដល់រដ្ឋាភិបាល គឺពួកគេខិតខំកសាងជីវភាពដោយសុចរិត ជួយបង់ពន្ធជូនរដ្ឋ កសាងប្រទេស គោរពច្បាប់ប្រទេសគឺជាការ ល្អប្រសើបំផុតគឺដូចជាពលរដ្ឋរស់នៅស្របច្បាប់ដែរ។ហើយម្យ៉ាងទៀតខ្ញុំយល់ថា

ប្រទេសរបស់ខ្ញុំមានវប្បធម៌សំបូរបែប ដែលជាកត្តាធ្វើឱ្យមានការអភិវឌ្ឍប្រទេស។ ប៉ុន្តែបើជនទាំងនោះរស់នៅដោយបង្ករបញ្ហា មិនគោរពច្បាប់នៅលើទឹកដីរបស់ខ្ញុំៗគិតថាពួកគេមិនគួរមានអត្ថិភាពលើទឹកដីរបស់ខ្ញុំទៀតទេ ហើយរដ្ឋាភិបាល ប្រជាពលរដ្ឋរបស់ខ្ញុំក៏មិនគាំទ្រនោះដែរ។

5. វត្តមាននៃជនជាតិផ្សេងៗនៅលើទឹកដីនៃប្រទេសណាមួយផ្តល់នូវគុណសម្បត្តិនិងគុណវិបត្តិដូចជា ៖

❖ គុណសម្បត្តិ

- ធ្វើឱ្យប្រទេសនោះមានវប្បធម៌រីកចម្រើន
- ទាក់ទាញអ្នកវិនិយោគ
- ជាទេសចរណ៍ជនជាតិដ៏ល្អ

❖ គុណវិបត្តិ

- បាត់បង់ប្រពៃណី វប្បធម៌ដើមរបស់អ្នកស្រុក
- មានការរើសអើង
- ធ្វើការបំបែករដ្ឋឯកភាព
- ធ្វើឧក្រិដ្ឋកម្មផ្សេងៗ...។

មេរៀនទី១០ សិទ្ធិនារី

## សំណួរ

1. តើសិទ្ធិជាអ្វី? សិទ្ធិនារីមានន័យដូចម្តេច?
2. ចូររៀបរាប់សិទ្ធិមនុស្សអន្តរជាតិទាក់ទងនឹង នារី។
3. ហេតុអ្វី បានជាមានកិច្ចព្រមព្រៀងរបស់អង្គការសហប្រជាជាតិ លើអនុសញ្ញាស្តីពីការ បំបាត់រាល់ទម្រង់នៃការរើសអើងប្រឆាំងនារីភេទ?ចូររៀបរាប់អត្ថន័យនៃមាត្រានីមួយៗទាក់ទងនឹងនារីភេទ។

## ចម្លើយ

1. សិទ្ធិជាគឺជាអំណាចរបស់មនុស្សម្នាក់ៗដែលមានតាំងពីកំណើតមក។

❖ សិទ្ធិនារីមានន័យ គឺជាអំណាចរបស់នារីដែលមានដូចមនុស្សទូទៅដែរ។

2. រៀបរាប់សិទ្ធិមនុស្សអន្តរជាតិទាក់ទងនឹងនារី

- មាត្រា1. មនុស្សទាំងអស់កើតមកមានសេរីភាព និងសមត្ថភាពក្នុងផ្នែកសេចក្តីថ្លៃថ្នូនិងសិទ្ធិ។
- មាត្រា3 បុគ្គលម្នាក់ៗមានសិទ្ធិរស់រានមានជីវិតសេរីភាព និងសន្តិសុខផ្ទាល់ខ្លួន។
- មាត្រា7 ជនគ្រប់រូបមានសិទ្ធិស្មើគ្នាចំពោះមុខច្បាប់និងមានទទួលការការពារពីច្បាប់ស្មើៗគ្នា ដោយគ្មានការរើសអើង

- មាត្រា16 មនុស្សប្រុសស្រីដល់អាយុគ្រប់ការមានសិទ្ធិរៀបអាពាហ៍ពិពាហ៍និងកសាងគ្រួសារដោយមិនប្រកាន់ពូជសាសន៍សញ្ជាតិ ឬសាសនាណាឡើយ។
- មាត្រា21មនុស្សគ្រប់រូបមានសិទ្ធិចូលរួមក្នុងការដឹកនាំកិច្ចការសាធារណៈនៃប្រទេសរបស់ខ្លួនដោយផ្ទាល់ឬតាមរយៈតំណាងដែលបានជ្រើសរើសដោយសេរី។ មនុស្សគ្រប់រូបមានសិទ្ធិចូលបំរើមុខងារសាធារណៈនៃប្រទេសរបស់ខ្លួនក្នុងលក្ខខណ្ឌ សមភាព។
- មាត្រា23 មនុស្សគ្រប់រូបមានសិទ្ធិមានការងារធ្វើ ជ្រើសរើសការងារដោកយសេរី ទទួលលក្ខខណ្ឌការងារស្រមស្រប និងពេញចិត្តនិងមានការការពារប្រឆាំងនឹងភាពអត់ការងារធ្វើ។មនុស្សគ្រប់រូប មានសិទ្ធិទទួលប្រាក់បៀវត្សស្មើគ្នាចំពោះការងារដូចគ្នាដោយគ្មានការរើសអើង។
- មាត្រា25 មនុស្សគ្រប់រូបមានសិទ្ធិទទួលកម្រិតជីវភាពគ្រប់គ្រាន់ដើម្បីធានាសុខភាព និងសុខុមាលភាពរបស់ខ្លួននិងគ្រួសារ។
- មាត្រា26 មនុស្សគ្រប់រូបមានសិទ្ធិទទួលការអប់រំ។
- មាត្រា45 ការរើសអើងប្រឆាំងនារីភេទត្រូវលប់បំបាត់ចោល។
- មាត្រា46 អំពើលក់ដូរមនុស្ស អំពើអាជីវកម្មផ្នែកពេស្យាកម្មនិងអំពើអាសអាភាស ដែលប៉ះពាល់ដលសេចក្តីថ្លៃថ្នូររបស់នារីត្រូវច្បាប់ហាមឃាត់។ ត្រូវហាមឃាត់មិនឱ្យ

មានការបញ្ឈប់នារីពីការងារ ដោយមូលហេតុមានគភ៌។ នារីមានសិទ្ធិឈប់សម្រាក នៅពេលសម្រាលកូនដោយទទួលប្រាក់ បៀវត្សនិងដោយមានការធានារក្សាសិទ្ធិអតីតភាពការងារនិងអត្ថប្រយោជន៍សង្គមផ្សេងៗទៀត។

- មាត្រា47 មាតាបិតាមានកាតព្វកិច្ចចិញ្ចឹមថែរក្សា និងអប់រំកូនចៅជាពលរដ្ឋល្អ។

3. បានជាមានកិច្ចព្រមព្រៀងរបស់អង្គការសហប្រជាជាតិលើអនុសញ្ញាស្តីពីការ បំបាត់រាល់ទម្រង់នៃការរើសអើងប្រឆាំងនារីភេទព្រោះដោយសារ៖

- នារីនៅតែមានការរើសអើងដដែល
- ការទាមទាររបស់ស្ត្រី។

❖ អត្ថន័យនៃមាត្រានីមួយៗ ទាក់ទងនឹងនារីភេទមាន

➢ មាត្រា1 ឈរលើមូលដ្ឋាននៃសិទ្ធិនិងសេរីភាពនារីន និងបុរសត្រូវមានភាពស្មើគ្នានៅក្នុងសង្គមគ្រួសារលើគ្រប់វិស័យនយោបាយ ពលរដ្ឋ សេដ្ឋកិច្ច សង្គមកិច្ច វប្បធម៌ និងវិស័យផ្សេងៗទៀត។

➢ មាត្រ2 រាល់ការរើសអើងនិងអំពើហិង្សាលើនារីត្រូវ បានការពារតាមផ្លូវច្បាប់។ត្រូវបានធានាសេវាសម ស្របដែលទាក់ទិននឹងការពពោះ ការសម្រាលកូន។

➢ មាត្រា3 នារីមានសិទ្ធិដូចបុរសក្នុងការចូលរួមការងារ លើគ្រប់វិស័យក្នុងសង្គម តាមសមត្ថភាពនិងជំនាញរបស់ខ្លួន។

- មាត្រា4 រាល់អំពើបង្ខិតបង្ខំ ឬបញ្ឈប់ការងារនារីភេទមិនត្រូវធ្វើតាមទំនើងចិត្តឡើយ។
- មាត្រា5 កិច្ចការក្នុងគ្រួសារនិងការអប់រំចិញ្ចឹមបីបាច់ថែរក្សាកូន ជាភារកិច្ចបុរសនារី។
- មាត្រា6 ការលក់ដូរនិងអាជីវកម្មផ្នែកពេស្យាចារលើនារីភេទជាអំពើរំលោភសិទ្ធិមនុស្សប្រឆាំងនឹងច្បាប់ ជាតិនិងច្បាប់អន្តរជាតិ។
- មាត្រា7នារីគ្រប់រូបមានសិទ្ធិបោះឆ្នោតជ្រើសរើសតំណាងខ្លួនដោយសេរី និងមានសិទ្ធិឈរឈ្មោះឱ្យគេបោះឆ្នោតដូចបុរសដែរ។
- មាត្រា8 នារីនិងបុរសមានសិទ្ធិស្មើគ្នាចូលរួមសកម្មភាពការងារក្នុងរដ្ឋាភិបាលអង្គការក្រៅរដ្ឋាភិបាលជាតិ និងអន្តរជាតិតាមសមត្ថភាពរបស់ខ្លួន.
- មាត្រា9 នារីនិងបុរសមានសិទ្ធិស្មើគ្នាក្នុងការផ្លាស់ប្តូរឬរក្សាទុកសញ្ជាតិរបស់ខ្លួន។
- មាត្រា10 នារីនិងបុរសមានសិទ្ធិស្មើគ្នាក្នុងការទទួលអាហារូបករណ៍ សម្រាប់ការសិក្សានិងកាទទួលយកសញ្ញាបត្រនៅក្នុងគ្រឹះស្ថានសិក្សាគ្រប់ផ្នែកទាំងក្នុងប្រទេសនិងក្រៅប្រទេស។
- មាត្រា11 នារីគ្រប់រូបមានសិទ្ធិរើបម្រាស់ដើម្បីទាមទារសិទ្ធិរបស់ខ្លួនលើរាល់ការងារ ដែលប្រព្រឹត្តផ្ទុយនឹងសេចក្តីថ្លៃថ្នូររបស់នារីភេទ។

- មាត្រា12 នារីគួរមានការលើកទឹកចិត្តដើម្បីធានាសុខភាពរបស់ម្តាយនិងទារកព្រមទាំងជួយកាត់បន្ថយនូវ កង្វះខាតក្នុងគ្រួសារ ជាពិសេសត្រូវធានាសេវាសមស្របដែលទាក់ទិននឹងការពពោះ ការសម្រាលកូន។
- មាត្រា13 នារីគ្រប់រូបមានសិទ្ធិក្នុងសកម្មភាពកំសាន្ត កីឡានិងរាល់ទិដ្ឋភាពនៃជីភាពវប្បធម៌ទាំងឡាយ។
- មាត្រា14 រដ្ឋត្រូវគិតគូរដល់ស្ត្រីនៅជនបទឱ្យទទួលនូវអត្ថប្រយោជន៍ពីកិច្ចអភិវឌ្ឍន៍ដូចជាការឧបត្ថម្ភផ្នែក សុខាភិបាល សន្តិសុខអប់រំ និងទទួលបាននូវឥណទានផ្នែកកសិកម្ម។
- មាត្រា15 នារីមានសិទ្ធិស្មើបុរសចំពោះមុខច្បាប់ ហើយនៅគ្រប់ផ្នែករដ្ឋប្បវេណី ដូចជាការចុះកិច្ចសន្យា ការគ្រប់គ្រងកម្មសិទ្ធិនិងនៅគ្រប់ដំណាក់នៃ នីតិវិធីនៃការជំនុំជម្រះក្នុងតុលាការ។
- មាត្រា16 នារីគ្រប់រូបមានសិទ្ធិទទួលយក ឬបដិសេធ ក្នុងការជ្រើសរើសគូរស្រករ ដោយគ្មានការបង្ខិតពី ក្រុមគ្រួសារ ឬអាណាព្យាបាលបានឡើយ។

មេរៀនទី១១ **សិទ្ធិកុមារ**

## សំណួរ

1. តើមនុស្សដូចម្ដេចដែលគេចាត់ទុកជាកុមារ?
2. តើបុព្វហេតុអ្វីខ្លះ ដែលនាំឱ្យកើតមានអនុសញ្ញាស្ដីពីសិទ្ធិកុមារ?
3. តើសិទ្ធិកុមារជារួមមានប៉ុន្មានមាត្រា? តើសិទ្ធិធំៗរបស់កុមារមានអ្វីខ្លះ? ចូររៀបរាប់។
4. ដើម្បីឱ្យកុមារមានការអភិវឌ្ឍន៍ពេញលេញ និងសមស្របតាមបុគ្គលិកលក្ខណៈតើគ្រួសារ សាលារៀន និងសមត្ថកិច្ចសាធារណៈត្រូវយកចិត្តទុកដាក់ និងទទួលខុសត្រូវដូចម្ដេចខ្លះ?

## ចម្លើយ

1. កុមារ សំដៅទៅលើមនុស្សគ្រប់រូបដែលមានអាយុ ស្ថិតនៅក្រោម 18 ឆ្នាំលើកលែងតែអាយុពេញវ័យ ត្រូវបានកំណត់រហ័សជាងនេះ នៅក្នុងច្បាប់នៃប្រទេសនីមួយៗ។
2. មូលហេតុហេតុដែលនាំឱ្យកើតមានអនុសញ្ញាស្ដីពីសិទ្ធិកុមារគឺ ៖

- នៅក្នុងជាច្រើនពុំទាន់មានច្បាប់ ឬរចនាសម្ព័ន្ធសង្គមជាក់លាក់សម្រាប់ធានាដល់សិទ្ធិរបស់កុមារនៅឡើយ
- ការអភិឌ្ឍកុមារ ជាផ្នែកមួយដ៏សំខាន់បំផុតនៃអនាគតរបស់សង្គមនីមួយៗ

- តម្រូវការជាចាំបាច់របស់កុមារ ពុំទាន់មានចែងនៅក្នុងឧបសម្ព័ន្ធសិទ្ធិមនុស្សដែលមានស្រាប់នៅឡើយ
- ផលប្រយោជន៍របស់កុមារមិនដូចគ្នានឹងផលប្រយោជន៍របស់អ្នកដែលជាអាណាព្យាបាលលើកុមារ ឡើយ
- កុមារងាយរងគ្រោះជាងមនុស្សចាស់នៅក្រោមលក្ខខណ្ឌនៃការរស់នៅរបស់ខ្លួននិងការរំលោភបំពានគ្រប់យ៉ាង
- កុមារពុំមានសមត្ថភាពគ្រប់គ្រាន់ក្នុងការការពារខ្លួននៅចំពោះមុខច្បាប់
- កុមារងាយនឹងទទួលផលប៉ះពាល់ ជាងក្រុមអាយុផ្សេងៗទៀតចំពោះសកម្មភាព ឬអសកម្មភាពរបស់រដ្ឋាភិបាល
- កុមារគ្មានសិទ្ធិបោះឆ្នោត ឬឥទ្ធិពលនយោបាយ ហើយមានកម្លាំងផ្នែកសេដ្ឋកិច្ចតិចតួចណាស់ ដែលជាញឹកញាប់សំលេងរបស់ពួកគេ ពុំត្រូវបានយកចិត្តទុកដាក់ស្តាប់ឡើយ
- នៅក្នុងសង្គមជាច្រើនតែងតែគិតថា កុមារគឺជាសម្បត្តិឬជាកម្មសិទ្ធិរបស់មាតាបិតា។ សង្គមខ្លះយល់ថាកុមារ អាចធ្វើការងារបានដូចមនុស្សធំដែរ ហើយខ្លះទៀតគិត ថាកុមារមិនអាចជួយសង្គមបានឡើយ
- សង្គមជាតិនីមួយៗ ត្រូវមានភារកិច្ចបំពេញរាល់សេចក្តីត្រូវការចាំបាច់របស់កុមារទាំងបុគ្គលភាព ប្រាជ្ញា ស្មារតីនិងសុវត្ថិភាព។

3. សិទ្ធិកុមារចែកជាបីផ្នែកនិងមាន54មាត្រា។

❖ សិទ្ធិធំៗរបស់កុមារមាន4គឺ

- សិទ្ធិរស់រានមានជីវិត
- សិទ្ធិក្នុងការអភិវឌ្ឍ
- សិទ្ធិទទួលការការពារ និង
- សិទ្ធិក្នុងការចូលរួម។

4. ដើម្បីឱ្យកុមារមានការអភិវឌ្ឍន៍ពេញលេញ និងសមស្រប តាមបុគ្គលិកលក្ខណៈគ្រួសារ សាលារៀន និងសមត្ថកិច្ចសាធារណៈត្រូវយកចិត្តទុកដាក់ និងទទួលខុសត្រូវដូចជា ៖

❖ **គ្រួសារត្រូវ**

- ស្រលាញ់ថ្នាក់ថ្នម យកចិត្តទុកដាក់
- ថែទាំ អប់រំ
- ផ្តល់សម្ភារៈផ្សេងៗ
- ផ្តល់អាហារគ្រប់គ្រាន់ឱ្យកូន
- បញ្ជូនកូនឱ្យទៅសាលារៀន

❖ **សាលារៀនត្រូវ**

- បណ្តុះបណ្តាលកុមារ
- អប់រំផ្នែកសីលធម៌
- អប់រំចំណេះដឹងទូទៅ
- អប់រំពីសង្គម វិជ្ជាជីវៈ សិទ្ធិ ច្បាប់
- ផ្តល់ការកម្សាន្ត និងលេងបែបអប់រំ

❖ **សង្គមត្រូវ**

- គាំពារកុមារតាមច្បាប់
- ផ្តល់សេវាសុខភាពដល់មាតានិងទារក

- លើកស្ទួយសិទ្ធិកុមារ
- ប្រឆាំងនឹកការរើសអើងពូជសាសន៍ សាសនា ឬទម្រង់នៃការរើសអើងទូទៅផ្សេងៗទៀតដូចជា ការបោះបង់ការប្រើភាពឃោរឃៅនិងជិះជាន់ជា ដើម
- ផ្តល់ការអប់រំឱ្យស្មើរៗគ្នា។

# មេរៀនទី១២

## ការផ្តន្ទាទោសលើបទឧក្រិដ្ឋប្រល័យពូជសាសន៍

### សំណួរ

1. ដូចម្តេចហៅថា អំពើប្រល័យពូជសាសន៍?
2. ចូរនិយាយពីផលអាក្រក់នៃអំពើប្រល័យពូជ សាសន៍។
3. ចូរពន្យល់ពីការផ្តន្ទាទោសចំពោះបទឧក្រិដ្ឋ ប្រល័យពូជសាសន៍?

### ចម្លើយ

1. អំពើប្រល័យពូជសាសន៍ ជាអំពើមួយដែលប៉ុនប៉ងកម្ទេចដោយចេតនា និងជាប្រព័ន្ធនូវផ្នែកណាមួយ ឬទាំងស្រុងទៅលើក្រុមប្រជាជាតិ ក្រុមជាតិពន្ធុ ក្រុម អំបូរ ក្រុមនយោបាយ ក្រុមសាសនា ឬក្រុមវប្បធម៌ ណាមួយ។

2. ផលអាក្រក់នៃអំពើប្រល័យពូជសាសន៍រួមមាន៖

- បំផ្លាញទ្រព្យសម្បត្តិ សម្ភារៈ ហេដ្ឋារចនាសម្ព័ន្ធ វប្បធម៌ សាសនា
- ការសំលាប់មនុស្សរាប់លាននាក់
- ការធ្វើទារុណ្ណកម្មយ៉ាងព្រៃផ្សៃទៅលើកុមារ អ្នកទោស ឬក្រុមមនុស្សដែលជាកម្មវត្ថុនៃការសម្លាប់រង្គាល
- ការរើសអើងជាតិពន្ធុ អំបូរ និងសាសនា
- ការរំលោភផ្លូវភេទទៅលើនារីដែលជាអ្នកទោស
- ការបង្អត់អាហារ
- ការបង្ខំឱ្យធ្វើការហួសកម្លាំង
- ការរំលោភសិទ្ធិមនុស្ស
- ការបំបិទសេរីភាព
- ការមិនគោរពច្បាប់អន្តរជាតិ និងការប្រព្រឹត្តអំពើអមនុស្សធម៌ជាដើម។

❖ អំពើប្រល័យពូជសាសន៍បានបន្សល់នូវបញ្ហាដូចជា៖

- ភាពក្រីក្រ
- ភាពអវិជ្ជា
- កុមារកំព្រា ស្ត្រីមេម៉ាយ ជនពិការ
- ភាពបាក់ស្បាត
- ការមិនមានការទុកចិត្តគ្នា ឬការគ្មានជំនឿលើគ្នា
- ការបាត់បង់សមត្ថភាពពលកម្ម ។

3. ការផ្តន្ទាទោសចំពោះបទឧក្រិដ្ឋប្រល័យពូជសាសន៍៖

ការវិនិច្ឆ័យទោសបានប្រព្រឹត្តទៅ ចំពោះករណីឧក្រិដ្ឋកម្មប្រល័យពូជសាសន៍មួយចំនួនតូច ដែលជាលទ្ធផលនៃការបង្កើតតុលាការឧក្រិដ្ឋកម្មអន្តរជាតិ ចំពោះកិច្ចនៅក្នុងទសវត្សរ៍ឆ្នាំ 1990។ ខណៈនៃការមកដល់របស់ តុលាការឧក្រិដ្ឋកម្មអន្តរជាតិក្នុងឆ្នាំ 2002 ពិភពលោក មានមូលដ្ឋាននិងសក្តានុពលក្នុងការនាំឧក្រិដ្ឋជនប្រល័យពូជសាសន៍កាន់តែច្រើនទៅកាន់ប្រព័ន្ធយុត្តិធម៌។ជាក់ស្តែង **សាដាម ហ៊ូសេន** ជាមេដឹកនាំអ៊ីរ៉ាក់ពីឆ្នាំ 1979-2003 **ស្លូបូដាម មីឡូស៊ីវិក** អតីតមេដឹកនាំស៊ែប និងមេដឹកនាំជាន់ខ្ពស់នៃរបបកម្ពុជាប្រជាធិបតេយ្យមួយចំនួន ដែលបានដឹកនាំប្រទេសកម្ពុជាពីឆ្នាំ1975-1978ដែលត្រូវបាននិងកំពុងកាត់ទោសជាបន្តបន្ទាប់ ពីបទឧក្រិដ្ឋកម្មសង្គ្រាម ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិនិងអំពើប្រល័យពូជសាសន៍។ សម្រាប់នៅកម្ពុជាអ្នកប្រព្រឹត្តបទឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ត្រូវផ្តន្ទា ទោសដាក់ពន្ធនាគារអស់មួយជីវិត។

## មេរៀនទី១៣ បញ្ហាចិត្ត-សង្គម

### សំណួរ

1. ដូចម្ដេចហៅថា បញ្ហាចិត្ត-សង្គម?
2. ហេតុអ្វីបានជាយើងសិក្សាពីបញ្ហាចិត្ត-សង្គម ? តើបញ្ហាចិត្ត-សង្គមមានអ្វីខ្លះ? ចូររៀបរាប់?
3. ចូរពន្យល់ពីការថប់អារម្មណ៍និងជម្ងឺចិត្តកាយ វិបល្លាស។
4. ចូរប្រៀបធៀបការធ្លាក់ទឹកចិត្ត និងការបាក់ ស្បាត។
5. តើមានវិធី និងអន្តរាគមន៍អ្វីខ្លះដល់អ្នកដែលមានបញ្ហាចិត្តសង្គម? ចូរពន្យល់។
6. ចូរសិក្សាទៅលើអ្នកដែលមានបញ្ហាចិត្តសង្គម នៅក្នុងសហគមន៍របស់អ្នកឱ្យបានបីនាក់។

### ចម្លើយ

1. បញ្ហាចិត្ត-សង្គមគឺ ជាការប៉ះទង្គិចផ្លូវចិត្តរបស់មនុស្សទៅនឹងព្រឹត្តិការណ៍សង្គម ។
2. បានជាយើងសិក្សាពីបញ្ហាចិត្ត-សង្គមព្រោះ

- ប្រជាពលរដ្ឋ បានទទួលនូវការឈឺចាប់ដោយសារសង្គ្រាមកន្លងមក
- ដើម្បីរកដំណោះស្រាយជូនពួកគេ
- ផ្ដល់កម្លាំងចិត្តដល់ប្រជាពលរដ្ឋឱ្យមានការតស៊ូ។

❖ បញ្ហាចិត្ត-សង្គមមាន សេចក្តីវន្ទត់ ភាពគ្មានទីពំនឹង ការគ្រោះថ្នាក់រងរបួសធ្ងន់ធ្ងរ ការគំរាមកំហែងដែលបង្ករឱ្យរបួសធ្ងន់ធ្ងរ ឬមរណភាព អស្ថិរភាពនយោបាយ បទពិសោធន៍ផ្ទាល់ខ្លួនរបស់ប្រជាពលរដ្ឋម្នាក់ៗ ទាកទងនឹងអំពើពុករលួយ បញ្ហាឆក់ប្លន់ដីធ្លី គ្រាប់មីន ការចាប់រំលោភសេពសន្ថវៈ អំពើហិង្សាក្នុងគ្រួសារ អយុត្តិធម៌សង្គម និទ្ទណ្ឌភាព ។

3. ពន្យល់ពីការថប់អារម្មណ៍

ការថប់អារម្មណ៍ជាកត្តាដំបូងដែលបានលេចឡើង នៅពេលដែលបុគ្គលម្នាក់ព្យាយាមទប់ជំងឺភ័យព្រួយ ដូចជាការបារម្ភនឹងកង្វះខាតចំណីអាហារ ជំរកមិនសមរម្យ ភាពគ្មានការងារធ្វើ គ្រោះថ្នាក់បណ្តាលមក ពីហេតុការណ៍ផ្សេងៗ ជម្លោះក្នុងគ្រួសារ ជំងឺតម្កាត់ ឬការទទួលបន្ទុកការងារច្រើនហួសជាដើម។

ការថប់អារម្មណ៍ ជាជំងឺផ្លូវចិត្តកម្រិតស្រាលទាក់ ទងនឹងការភ័យខ្លាចនិងការព្រួយបារម្ភ។

• ជម្ងឺចិត្តកាយវិបល្លាស

ជម្ងឺចិត្តកាយវិបល្លាស គឺជាការត្អូញត្អែររបស់អ្នកជំងឺពីបញ្ហាផ្លូវកាយដែលបណ្តាលមកពីផ្លូវចិត្ត ។ អ្នកជំងឺមានការត្អូញត្អែររៀបរាប់ពីបញ្ហាដែលកើត លើរូបកាយរបស់គេដូចជាឈឺក្បាល វិលមុខ ណែនដើមទ្រូង និង ឈឺចាប់ក្នុងខ្លួនម្តងត្រង់នេះម្តងត្រង់នោះ។ ភ្នាក់ងារសុខភាពតែងតែពិបាកព្យាបាល ពិបាកសន្និដ្ឋានជំងឺបែបនេះ ថាជាប្រភេទជំងឺអ្វីមួយឱ្យ

ពិតប្រាកដ ទោះជា អ្នកព្យាបាលខិតខំរិះរកមធ្យោបាយផ្សេងៗដើម្បីវិភាគ ជំងឺក៏ដោយ។ មានពេលខ្លះការត្អូញត្អែររបស់អ្នកជំងឺ បានបាត់ ឬធូស្រាលមួយរយៈដែរ តែមិនយូរប៉ុន្មានទេ គេនឹងចាប់ផ្តើមត្អូញត្អែរដូចមុន។

4. ប្រៀបធៀបការធ្លាក់ទឹកចិត្ត និងការបាក់ ស្បាត។

ចំណុចខុសគ្នា

<u>ការធ្លាក់ទឹកចិត្ត</u>

- បណ្តាលមកពីការបាត់បង់អ្វីមួយ
- ជាជំងឺនៃការធ្លាក់ចុះនៃអារម្មណ៍ដែលនាំឱ្យក្រៀមក្រំ បាត់បង់ភាពសប្បាយ
- អាការៈ ក្រៀមក្រំ សភាពសោកសៅ អស់សង្ឃឹម ស្រកទម្ងន់ គ្មានរីករាយ

❖ <u>ការបាក់ស្បាត</u>

- ប៉ះទង្គិចផ្លូវចិត្តក្នុងព្រឹត្តិការណ៍ពោរពេញដោយក្តីរន្ធត់
- បណ្តាលមកពីការជួបប្រទះក្តីរន្ធត់ដូចជាសង្គ្រាម គ្រោះថ្នាក់....
- អាការៈ មានការប្រុងប្រយ័ត្នហួសហេតុ ឬឆាប់មួរម៉ៅ និងរក់រឺចិត្តគំនិត...។

5. វិធី និងអន្តរាគមន៍ដល់អ្នកដែលមានបញ្ហាចិត្ត-សង្គមដូចជា ៖

- រៀបចំក្រុមមនុស្សដែលមានបញ្ហាស្រដៀងគ្នាឱ្យធ្វើការ គាំទ្រគ្នាទៅវិញទៅមកដើម្បីរំលែកទុក្ខសោកសោកនៅរវាងគ្នានិង គ្នា
- គ្រួសារនិងសហគមន៍ត្រូវធ្វើគំរោងព្យាបាលរយៈពេល យូរ ដើម្បីជួយដល់អ្នកជំងឺ ដូចជា
  - ប្រសិនបើអ្នកមិនទាន់បានទទួលការពិនិត្យលើជំងឺ ផ្លូវកាយ ត្រូវបញ្ជូនអ្នកជំងឺទៅកាន់មន្ទីរពេទ្យ ដើម្បី ឱ្យគ្រូពេទ្យធ្វើការពិនិត្យទៅលើសុខភាពអ្នកជំងឺ
  - ត្រូវធ្វើឱ្យអ្នកជំងឺមានការជឿទុកចិត្តថា រោគសញ្ញា នេះមិនមែនជាការចាប់ផ្តើមនៃជំងឺធ្ងន់ធ្ងរទេ ដោយពន្យល់ឱ្យអ្នកជំងឺទទួលស្គាល់ថានេះជាបញ្ហាផ្លូវចិត្តបន្តិចបន្តួច
  - បង្ការអ្នកជំងឺកុំឱ្យធ្លាក់ទៅក្នុងជំងឺចិត្តវិកលធ្ងន់ធ្ងរ ដោយផ្តល់ការព្យាបាលជាប្រចាំ
  - ការព្យាបាលអាចធ្វើឡើយតាមរយៈបុគ្គលិកសុខភាពក្នុងសហគមន៍
  - គប្បីព្យាយាមបំផុសអ្នកជំងឺឱ្យស្ម័គ្រចិត្តវិលត្រឡប់ ទៅធ្វើការជាធម្មតាវិញ ហើយធ្វើយ៉ាងណាឱ្យគេ គិតថាខ្លួនគេជាចំណែកមួយនៃសហគមន៍
  - សកម្មភាពហាត់ប្រាណ ការសម្រាកចិត្តឱ្យបានគ្រប់គ្រាន់ និងការកំសាន្តសប្បាយផ្តល់ផលប្រយោជន៍យ៉ាងខ្លាំងខ្លាដល់អ្នកដែលមានការប៉ះទង្គិច។

## សំណួរបញ្ចប់ជំពូកទី២

I. ចូរគូសសញ្ញា✓ក្នុងប្រអប់ដែលមានចម្លើយ ត្រូវតែមួយគត់៖

1. សាសនាដែលដឹកនាំមនុស្សឱ្យមានជំនឿលើ ខ្លួនឯង ហើយចៀសវាងកុំឱ្យមានជំនឿលើ អរូបីគឺ
   ☑ក.សាសនាព្រះពុទ្ធ ☐ខ.សាសនាគ្រិស្ត
   ☐គ.សាសនាឥស្លាម ☐ឃ.សាសនាហិណ្ឌូ។
2. សាសនាដែលដឹកនាំមនុស្សឱ្យមានជំនឿលើ អទិទេព ហើយរាល់កំហុសដែលមនុស្សបាន ធ្វើគឺព្រះព្រមទទួលយកគឺ
   ☐ក.សាសនាព្រះពុទ្ធ ☑ខ.សាសនាគ្រិស្ត
   ☐គ.សាសនាឥស្លាម ☐ឃ.សាសនាហិណ្ឌូ។
3. សាសនាព្រះពុទ្ធបាននាំចូលមកប្រទេសកម្ពុជា យើងនៅក្នុង
   ☐ក.ស.វទី១ មុនគ.ស. ☐ខ.ស.វទី១ នៃគ.ស.
   ☐គ.ស.វទី២ មុនគ.ស. ☑ឃ.ស.វទី២ នៃគ.ស.
4. ព្រះពុទ្ធសាសនាមានដើមកំណើតមកពី
   ☐ក.អាទិទេព ☐ខ.ព្រះវិស្ណុ
   ☐គ.ព្រះនរាយណ៍ ☑ឃ.មនុស្ស។
5. សាសនាដែលលើកយកការផ្សំធាតុដី ធាតុទឹក ធាតុភ្លើង និងធាតុខ្យល់មកពន្យល់ពីកំណើត ភាវៈគឺ

☑ក.សាសនាព្រះពុទ្ធ ☐ខ.សាសនាគ្រិស្ត
☐គ.សាសនាឥស្លាម ☐ឃ.សាសនាហិណ្ឌូ។

6. ទ្រឹស្តីព្រះពុទ្ធដែលបានថែងថាការមិនបៀត បៀនការមិនប្រទូសរ៉ាយដល់អ្នកដទៃគឺជាការ ធ្វើ
☑ក.អំពើល្អតាមផ្លូវចិត្ត ☐ខ.អំពើល្អតាមផ្លូវកាយ
☐គ.អំពើល្អតាមផ្លូវបញ្ញា ☐ឃ.អំពើល្អតាមផ្លូវវាចា

7. ព្រះពុទ្ធសាសនាហីនយានមានឥទ្ធិពលតែក្នុងប្រទេស
☐ក.ជប៉ុន ☐ខ.ថៃ ☐គ.ចិន ☐ឃ.វៀតណាម ☑ង.កម្ពុជា។

8. បញ្ញត្តិស្តីពីសីលធម៌របស់សាស្ត្រាចារ្យហាន្សគុងកើតឡើងក្នុងឆ្នាំ
☐ក.១៩៩២ ☑ខ.១៩៩៣
☐គ.១៨៩៣ ☐ឃ.១៨៩២។

9. មហាសន្និបាតអង្គការសហប្រជាជាតិបាន ប្រកាសសេចក្តីថ្លែងការណ៍ជាសកលស្តីពី សិទ្ធិមនុស្សនៅ
☑ក.១០ធ្នូ១៩៤៨ ☐ខ.០៨មិនា១៩១០ ☐គ.១៥កក្កដា១៩៦២ ☐ឃ.១៧មេសា១៩៧៥។

10. តើជនជាតិណាមួយដែលស្ថិតនៅក្នុងជនជាតិ ភាគតិចអំបូរមនខ្មែរ?
☑ក.គ្រឹង ☐ខ.ចាម
☐គ.ចិន ☐ឃ.វៀតណាម

11. របបកម្ពុជាប្រជាធិបតេយ្យ គ្រប់គ្រងប្រទេសកម្ពុជាក្នុងអំឡុងឆ្នាំ

☐ក.១៩៦៥-១៩៧០ ☐ខ.១៩៦៥-១៩៧៥ ☑គ.១៩៧៥-១៩៧៩ ☐ឃ.១៩៧៥-១៩៨០។

12.ប្រទេសកម្ពុជា បានផ្តល់សច្ចាប័នលើអនុសញ្ញាស្តីពីសិទ្ធិកុមារនៅថ្ងៃ ខែ ឆ្នាំ

☐ក.២០វិច្ឆិកា១៩៨៩ ☐ខ.២០កញ្ញា១៩៩០ ☐គ.១៥កញ្ញា១៩៩០ ☑ឃ.១៥តុលា១៩៩២។

13.អង្គការសហប្រជាជាតិបានបង្កើតឡើងនៅថ្ងៃ ខែ ឆ្នាំ

☐ក.២០មិថុនា១៨៤៥ ☐ខ.២៦មិថុនា១៨៤៥ ☑គ.២៦មិថុនា១៩៤៥ ☐ឃ.៣០មិថុនា១៩៤៥

14.សេចក្តីថ្លែងការណ៍ជាសាកលស្តីពីសិទ្ធិមនុស្ស ត្រូវបានប្រកាសឡើងនៅថ្ងៃ ខែ ឆ្នាំ

☐ក.២០ធ្នូ១៩៤៣ ☐ខ.១០វិច្ឆកា១៩៤៨ ☐គ.១០វិច្ឆិកា១៩៤៥ ☑ឃ.១០ធ្នូ១៩៤៨។

II. ចូរបំពេញឃ្លាខាងក្រោមឱ្យបានត្រឹមត្រូវ

1. ការពន្យារកំណើតជាបាតុភូតសង្គមមួយ ដែលពាក់ព័ន្ធទៅនឹងសិទ្ធិកុមារនិងសិទ្ធិ*ស្ត្រី*។
2. ព្រះពុទ្ធសាសនាបានកើតឡើង នៅពេលដែលព្រះសាមណគោតមទ្រង់*ចូលនិព្វាន*។
3. ជាតិផ្សេងៗ ដែលស្នាក់អាស្រ័យប្រកបមុខរបរក្នុងប្រទេសណាមួយថាជា*អាណិកជន*។

4. ក្នុងចំណោមព្រហ្មវិហារធម៌ទាំងបួន របស់ព្រះពុទ្ធដែលអប់រំមនុស្សឱ្យចេះស្រឡាញ់រាប់អានស្មើភាពគ្មានការរើសអើងគឺ *មេត្តា*។
5. សេចក្តីសុខដែលកើតចេញពីការប្រព្រឹត្តតាមគន្លងធម៌ដូចជាការប្រកបមុខរបរសុចរិតក្នុងការរកទ្រព្យសម្បត្តិព្រះពុទ្ធហៅថា *សម្មាអាជីវោ*។
6. ពេលចូលព្រះវស្សាសម្រាប់ព្រះសង្ឃ ក្នុងព្រះពុទ្ធសាសនាមានរយៈពេល *3ខែ* ។
7. សិទ្ធិក្នុងការបន្តពូជ បានត្រូវគេទទួលស្គាល់ថាជាសិទ្ធិមនុស្សនៅក្នុងឆ្នាំ 1968។
8. សភាអន្តរសាសនាបង្កើតឡើងក្នុងឆ្នាំ *1948*ក្នុងគោលបំណងដើម្បី *តម្លៃសីលធម៌*។
9. ចាប់តាំងពីឆ្នាំ១៩៤៨មក អង្គការសហប្រជាជាតិបានកំណត់និយមន័យអំពើ *ប្រល័យពូជសាសន៍*ថាជាអំពើមួយដែលប៉ុនប៉ងកម្ទេចដោយចេតនា និងជាប្រព័ន្ធនៃផ្នែកណាមួយ ឬទាំងស្រុងទៅ លើក្រុមប្រជាជាតិក្រុមជាតិពន្ធុ ក្រុមអំបូរ ក្រុមនយោបាយ សាសនា ឬវប្បធម៌ណាមួយ។
10. ដំណើរការមួយដែលសេដ្ឋកិច្ចសង្គមវប្បធម៌តំបន់និងពិភពលោកត្រូវបានរំលាយចូលគ្នា តាមរយៈបណ្តាញសកលនៃទំនាក់ទំនងនិងពាណិជ្ជកម្មហៅថា *សកលភាវូបនីយកម្ម*។
11. មុខងារសំខាន់របស់ធនាគារពិភពលោកគឺផ្តល់ *ឥណទាន* ដល់គម្រោងសំខាន់ៗដើម្បីបង្កើនការអភិវឌ្ឍសេដ្ឋកិច្ចជាតិ

12. ជនជាតិចិនបានភៀសខ្លួនមករស់នៅស្រុកខ្មែរតាំងពីសម័យ*មុនអង្គរ*សកម្លេះ។

13. ការរើសអើងប្រឆាំងចំពោះនារីភេទគឺជាការរំលោភទៅលើគោលការណ៍នៃ*សិទ្ធិមនុស្ស*។

14. កុមារសំដៅលើមនុស្សគ្រប់រូបដែលមានអាយុ*ក្រោម18ឆ្នាំ*

15. អនុសញ្ញាស្តីពីសិទ្ធិកុមារ ជាកិច្ចព្រមព្រៀងមួយរបស់អង្គការ*សហប្រជាជាតិ*ដែលបានកំណត់ពី សិទ្ធិនានារបស់កុមារ។

16. កុមារមានសិទ្ធិធំៗចំនួនបួនគឺ *1សិទ្ធិរស់រានមានជីវិត 2សិទ្ធិក្នុងការអភិវឌ្ឍ 3សិទ្ធិទទួលការការពារនិង 4សិទ្ធិក្នុងការចូលរួម*។

17. របបកម្ពុជាប្រជាធិបតេយ្យបានសម្លាប់*មនុស្ស*យ៉ាងរង្គាល

18. សាលាក្តីកាត់ទោសមេដឹកនាំខ្មែរក្រហម បង្កើតឡើងនៅ*ខែមិថុនា*ក្នុងឆ្នាំ*2007*។

19. គេកំណត់របបកម្ពុជាប្រជាធិបតេយ្យថាជារបប*ប្រល័យពូជសាសន៍*។

20. រណសិរ្សរំដោះប្រជាជនកម្ពុជា ចេញពីរបបកម្ពុជាប្រជា ធិបតេយ្យមានឈ្មោះថា*រណសិរ្សសាមគ្គីសង្គ្រោះជាតិកម្ពុជា*។

21. ប្រជាជនកម្ពុជាមានសិទ្ធិសេរីភាពពេញលេញ ក្រោយថ្ងៃ*រំដោះ*ពីរបបកម្ពុជាប្រជាធិប តេយ្យ។

III ចូរផ្គូផ្គងផ្នែកA និងផ្នែក B ឱ្យបានត្រឹមត្រូវ

| A | B | ចម្លើយ |
|---|---|---|
| 1. កុមារកើតពីម្តាយ ឪពុកឥតខាន់ស្លា និងមានខាន់ស្លា<br>2. ក្រុមមនុស្សដែលងាយទទួលរងគ្រោះថ្នាក់ បំផុតនៅក្នុងប្រទេសកំពុងអភិវឌ្ឍ<br>3. មាតាបិតាបញ្ឈប់កូនមិនឱ្យរៀនតទៅទៀត<br>4. កុមារត្រូវទទួលការ ស្រឡាញ់ថ្នាក់ថ្នមនិង បីបាច់ថែរក្សាឱ្យបានជិតដល់<br>5. កុមារមានសិទ្ធិពិសេសដូចមនុស្សចាស់ និងស្ត្រីមានផ្ទៃពោះដែរ<br>6. ឥទ្ធិពលនៃសង្គ្រាមបានបង្កើតផលវិបាកច្រើនដល់សង្គម | ក.ពីឪពុកម្តាយអាណាព្យាបាលនិងរដ្ឋ<br>ខ.រំលោភសិទ្ធិរៀន សូត្ររបស់កុមារ<br>គ.កុមារដែលគ្មានទីជម្រក<br>ឃ.ស្ត្រីមេម៉ាយជនអនាថានិងកុមារកំព្រា<br>ង.សិទ្ធិរួចផុតពីការកាត់ទោសប្រហារជីវិត<br>ច.មានសិទ្ធិដូចគ្នា | 1. → ច<br>2. → គ<br>3. → ខ<br>4. → ក<br>5. → ង<br>6. → ឃ |

## ជំពូកទី៣ ការចូលរួមអភិវឌ្ឍសង្គម

## មេរៀនទី១ រដ្ឋាភិបាល

### សំណួរ

I. ចូរគូសសញ្ញា✓ក្នុងប្រអប់ដែលមានចម្លើយ ត្រូវតែមួយគត់៖

1. រដ្ឋាភិបាលក្នុងលទ្ធិប្រជាធិបតេយ្យកើតឡើង ដោយ
   ☐ក.ការចាត់តាំង ☐ខ.ការបន្តតំណែង
   ☐គ.ការធ្វើរដ្ឋប្រហារ ☑ឃ.ការបោះឆ្នោត
2. ភារកិច្ចចម្បងរបស់រដ្ឋាភិបាលគឺការពារឱ្យ បាននូវ
   ☐ក.សមាសភាពនៃសមាជិករបស់ខ្លួន☐ខ.ការរំលោភសិទ្ធិ ☑គ.រដ្ឋធម្មនុញ្ញ
3. ផ្នែកដែលកាន់កិច្ចការផ្ទាល់របស់រដ្ឋមន្ត្រី ឬរដ្ឋ លេខាធិការគឺ
   ☑ក.ផ្នែករដ្ឋបាល ☐ខ.ផ្នែកអធិការកិច្ច ☐គ.ផ្នែកទីប្រឹក្សា
4. ស្ថាប័នដែលមានតួនាទីក្នុងការចរចាធ្វើទំនាក់ទំនងពាណិជ្ជកម្ម និងសហប្រតិបត្តិការសេដ្ឋកិច្ចគឺ
   ☐ក.ព្រឹទ្ធសភា ☐ខ.រដ្ឋសភា ☐គ.តុលាការ ☑ឃ.រដ្ឋាភិបាល

II. សំណួរត្រិះរិះ

1 ចូរឱ្យនិយមន័យរដ្ឋាភិបាល។

2. ចូរឱ្យនិយមន័យ និងរៀបរាប់ដោយបញ្ជាក់អំពីគុណសម្បត្តិ និងគុណវិបត្តិនៃរដ្ឋបាលកណ្តាល។
3. ចូរបកស្រាយអំពីការធ្វើកំណែទម្រង់រដ្ឋបាល។
4. តើគោលបំណងនៃការបង្កើតរដ្ឋាភិបាលមាន អ្វីខ្លះ?

## ចម្លើយ

## II. ចម្លើយ

1. រដ្ឋាភិបាល ក្រសោបទាំងស្ថាប័នកំពូលបីរបស់រដ្ឋគឺស្ថាប័ននីតិប្បញ្ញត្តិ នីតិប្រតិបត្តិ និងតុលាការ។ស្ថាប័នទាំងបីនេះហើយដែលមានភារៈគ្រប់គ្រងដឹកនាំរដ្ឋ ឱ្យមានសណ្តាប់ធ្នាប់ និងធានាសន្តិសុខផ្នែក សង្គមនិងផ្នែកសេដ្ឋកិច្ចជូនប្រជាពលរដ្ឋ។នៅក្នុងន័យចង្អៀត រដ្ឋាភិបាល សំដៅត្រឹមស្ថាប័ននីតិប្រតិបត្តិដែលមានតួនាទីជាអ្នកអនុវត្តច្បាប់ និងធ្វើឱ្យប្រជាពលរដ្ឋមានសុវត្ថិភាព ជាអ្នកផ្តល់សេវានានាជូនសង្គម។
2. រដ្ឋបាលកណ្តាល មានតួនាទីបំពេញមុខងាររដ្ឋបាលក្នុងលំដាប់ថ្នាក់លើនិងស្ថិតក្នុងក្របខ័ណ្ឌជាតិទាំងមូលនិងមានភាតព្វកិច្ចរៀបចំកិច្ចការប្រទេសជាតិទូទៅ។

❖ គុណសម្បត្តិនៃរដ្ឋបាលកណ្តាល

- ធ្វើឱ្យមានឯកភាពគ្នាក្នុងការអថនុវត្តន៍ការងាររដ្ឋចគ្នា
- ប្រជាពលរដ្ឋទាំងមូលមានសិទ្ធិស្មើគ្នាក្នុងការចូលរួមវិភាគទានអនុវត្តការងារដែលតម្រូវឱ្យធ្វើ។

❖ គុណវិបត្តិនៃរដ្ឋបាលកណ្តាល

- ការប្រមូលអំណាចរដ្ឋបាលកណ្ដាលឱ្យនៅតែមួយកន្លែងនឹងធ្វើឱ្យដំណើរការរដ្ឋបាលកណ្ដាលមានបន្ទុកកាន់តែធ្ងន់ធ្ងរ។
- ក្នុងការរៀបចំផែនការនានា រដ្ឋាបាលកណ្ដាលយកទៅធ្វើតែម្នាក់ឯង នោះផែនការនឹងមានការលំបាកក្នុងការអនុវត្តន៍ ហើយថ្នាក់ក្រោមមិនបានយល់ពីអ្វីដែលថ្នាក់លើប្រគល់ឱ្យអនុវត្ត ដែលជាហេតុនាំឱ្យផែនការបរាជ័យ។
- ពុំមានការទទួលខុសត្រូវច្បាស់លាស់។

3. ការធ្វើកំណែទម្រង់រដ្ឋបាល

កំណែទម្រង់រដ្ឋភិបាលបានចាប់ផ្ដើមនៅចុងស.វទី20 ដែលជាកិច្ចខំប្រឹងប្រែងដើម្បីឆ្លើយតបនិងការរិះគន់ចំពោះវិធីសាស្ត្រនៃការគ្រប់គ្រងសាធារណៈតាមបែបប្រពៃណី។ ជាគោលការណ៍ មានគំនិតមួយមាន លក្ខណៈប្រហាក់ប្រហែលគ្នានិងកំណែទម្រង់រដ្ឋបាលដែរដូចជា ឯកជនភាវូបនីយកម្មសេវាកម្មរបស់រដ្ឋ ការយកចិត្តទុកដាក់លើក្រមសីលធម៌របស់មន្ត្រី សាធារណៈ ការប្រឆាំងនឹងអំពោះពុករលួយ ការបង្កើនការទទួលខុសត្រូវនិងអភិបាលកិច្ចល្អនៅគ្រប់លំដាប់ថ្នាក់។

<u>មូលហេតុនៃកំណែទម្រង់</u>

- ប្រជាពលរដ្ឋមានលទ្ធភាពចូលរួមយ៉ាងសកម្មក្នុងការធ្វើសេចក្ដីសម្រេចចិត្តនៅមូលដ្ឋាន ដែលជាការពង្រឹងនូវការចូលរួមជាសាធារណៈក្នុងការអភិវឌ្ឍប្រទេស

- ការផ្តល់សេវាសាធារណៈរបស់ក្រសួង ស្ថាប័ន នៅថ្នាក់ជាតិកាន់តែរហ័សនិងមានប្រសិទ្ធិភាព ព្រោះអ្នកដែលទទួលខុសត្រូវទាំងនោះត្រូវបាន ផ្ទេរអំណាចទៅជិតប្រជាពលរដ្ឋ
- បង្កើននូវលទ្ធភាពនៃការរកប្រភពធនធាននៅមូលដ្ឋានសម្រាប់ផ្តល់សេវានិងការអភិវឌ្ឍបន្ថែមទៀត។

**ទិសដៅនៃកំណែទម្រង់**

- ដើម្បីលើកកម្ពស់ការអភិវឌ្ឍតាមបែបលទ្ធិ ប្រជាធិបតេយ្យ
- កាត់បន្ថយភាពក្រីក្រ តាមរយៈការបង្ករលក្ខណៈ ឱ្យប្រជាពលរដ្ឋចូលរួមក្នុងការធ្វើសេចក្តីសម្រេច ទាក់ទងនឹងតម្រូវការចាំបាច់នានានៅក្នុងមូលដ្ឋាន
- ធ្វើឱ្យមានការអភិវឌ្ឍប្រកបដោយនវន្តភាពទូលំទូលាយ
- ធានាឱ្យប្រជាពលរដ្ឋគ្រប់រូបមានឱកាសស្មើគ្នាក្នុងការចូលរួមរៀបចំផែនការអភិវឌ្ឍមូលដ្ឋានរបស់ខ្លួន។

4. គោលបំណងនៃការបង្កើតរដ្ឋាភិបាលមាន

- ដើម្បីការពាផលប្រយោជន៍ប្រជាជន រដ្ឋាភិបាលរិះរកគ្រប់វិធីពង្រឹងច្បាប់ឱ្យមានប្រសិទ្ធិភាព ក្នុងគោលបំណងការពារផលប្រយោជន៍ប្រជាជនទូទៅ។

- លើកស្ទួយសុខុមាលភាពប្រជាជន រដ្ឋាភិបាលអនុវត្តនិងពង្រឹងច្បាប់ផ្សេងៗ ព្រមទាំងចាត់វិធានការនានា នាក្នុងការចូលរួមវិភាគទានបម្រើសុខុមាលភាព របស់ប្រជាជន។
- ដើម្បីថែរក្សាទំនៀមទម្លាប់ប្រពៃណីវប្បធម៌និង អត្តសញ្ញាណជាតិ រដ្ឋាភិបាលត្រូវតែលើកស្ទួយទស្សនៈជាតិ និងធ្វើឱ្យប្រជាពលរដ្ឋចេះស្រលាញ់ និងការពារប្រពៃណីទំនៀមទម្លាប់និងវប្បធម៌ជាតិ និងសហគមន៍ខ្លួន។

មេរៀនទី២

# ស្ថាប័ននីតិប្រតិបត្តិនៃព្រះរាជាណាចក្រកម្ពុជា

## សំណួរ

I. ចូរផ្គូផ្គងផ្នែកA និង B ឱ្យបានត្រឹមត្រូវ

| A | B | ចម្លើយ |
|---|---|---|
| 1. វិស័យរដ្ឋបាល<br>2.វិស័យសេដ្ឋកិច្ច<br>3.វិស័យសង្គមកិច្ច | ក.ក្រសួងមហាផ្ទៃ<br>ខ.ក្រសួងព័ត៌មាន<br>គ.ក្រសួងទេសចរណ៍<br>ឃ.ក្រសួងសង្គមកិច្ច<br>ង.ក្រសួងអប់រំ<br>ច.ក្រសួងសុខាភិបាល | 1. →ក<br>2. →គ<br>3. →ឃ |

II. សំណួរត្រិះរិះ

1. ចូររៀបរាប់ពីការបង្កើតរដ្ឋាភិបាលក្នុងលទ្ធិប្រជាធិបតេយ្យ។
2. តើរដ្ឋាភិបាលកម្ពុជាកើតឡើងដោយរបៀបណា?
3. ចូររៀបរាប់ពីតួនាទី និងភារកិច្ចរបស់នាយករដ្ឋមន្ត្រី។
4. ចូររៀបរាប់ពីសមាសភាពរដ្ឋាភិបាលកម្ពុជា ព្រមទាំងពន្យល់ពីមុខតំណែងនីមួយៗផង។
5. តើខុទ្ទកាល័យទីស្តីការគណៈរដ្ឋមន្ត្រីមានភារ កិច្ចដូចម្តេចខ្លះ?
6. តើក្រសួង និងរដ្ឋលេខាធិការដ្ឋានត្រូវរៀបចំតាមវិស័យដូចម្តេចខ្លះ? លើកឧទាហរណ៍ បញ្ជាក់ផង។

## ចម្លើយ

## II. ចម្លើយ

1. រៀបរាប់ពីការបង្កើតរដ្ឋាភិបាល ក្នុងលទ្ធិប្រជាធិបតេយ្យ កើតឡើងការបោះឆ្នោតពីប្រជារាស្ត្រ រីឯរបប មានបី គឺ របបប្រធានាធិបតីនិយម របបសភានិយម និងសភានិយម។ការបង្កើតរដ្ឋាភបាល គឺអាស្រ័យលើប្រទេសនីមួយៗប្រកាន់យក និងស្ថានការណ៍នយោបាយរបស់ប្រទេសនោះ។
2. រដ្ឋាភិបាលកម្ពុជាកើតឡើងដោយ៖

❖ មាត្រា51 ថ្មីនៃរដ្ឋធម្មនុញ្ញព្រះរាជាណាចក្រកម្ពុជាចែងថាកម្ពុជាអនុវត្តនយោបាយប្រជាធិបតេយ្យសេរីពហុបក្ស ។ប្រជា

ពលរដ្ឋខ្មែរជាម្ចាស់វាសនានៃប្រទេសរបស់ខ្លួន។ ប្រជាពលរដ្ឋជាអ្នកជ្រើសរើសមេដឹកនាំរបស់ខ្លួន តាមរយៈការបោះឆ្នោត។ក្រោយការបោះឆ្នោតជ្រើស រើសតំណាងរាស្ត្រ រដ្ឋាភិបាលមួយបានកើតឡើងតាម ការទទួលសេចក្តីទុកចិត្តពីសភា(រដ្ឋសភា)។មាត្រា119 ថ្មីនៃរដ្ឋធម្មនុញ្ញចែងថាតាមសេចក្តីស្នើពីប្រធានដោយមានមតិភាគច្រើនពីអនុប្រធានទាំងពីនៃរដ្ឋសភា ព្រះមហាក្សត្រទ្រង់ចាត់តាំងរូបជនមួយរូបក្នុងចំណោម តំណាងរាស្ត្រនៃគណៈបក្សដែលឈ្នះឆ្នោតឱ្យបង្កើត រដ្ឋាភិបាល។ រូបជននោះ នាំសហការីដែលជាតំណាងរាស្ត្រ ឬជាសមាជិកបក្សតំណាងនៅក្នុងរដ្ឋសភាដែលផ្តល់ឱ្យកាន់តំណែងផ្សេងៗក្នុងរដ្ឋាភិបាល ទៅសុំសេចក្តីទុកចិត្តពីរដ្ឋសភា ។ កាលបើរដ្ឋសភាបានបោះឆ្នោតទុកចិត្តហើយនោះ ព្រះមហាក្សត្រទ្រង់ចេញព្រះរាជក្រឹតតែងតាំងគណៈរដ្ឋមន្ត្រីទាំងមូល។

3. តួនាទី និងភារកិច្ចរបស់នាយករដ្ឋមន្ត្រី

- ទទួលខុសត្រូវរួមជាមួយសមាជិកទាំងឡាយនៃរាជរដ្ឋាភិបាលចំពោះមុខរដ្ឋសភា អំពីនយោបាយទូទៅ និងសកម្មភាពរបស់រដ្ឋាភិបាល
- ដឹកនាំការចរចា និងចុះហត្ថលេខាលើកិច្ចព្រមព្រៀងពាណិជ្ជកម្ម សហប្រតិបត្តិការ សេដ្ឋកិច្ច វប្បធម៌ វិទ្យាសាស្ត្រ បច្ចេកទេស និងការពារប្រទេស

• លើកសំណើដល់គណកម្មាធិការអចិន្ត្រៃន៍នៃរដ្ឋសភា ដើម្បីកោះប្រជុំរដ្ឋសភាជាវិសាមញ្ញ
• លើកសំណើអំពីសេចក្ដីព្រាងច្បាប់ និងសំណើតែងតាំង ផ្លាស់ប្ដូរបញ្ចប់ភារកិច្ចរបស់សមាជិករដ្ឋាភិបាល ជូនរដ្ឋសភាអនុម័ត
• ត្រួតពិនិត្យការងារ សកម្មភាព អំពើប្រព្រឹត្តទំនួលខុសត្រូវរបស់រដ្ឋភិបាលហើយមានសិទ្ធិផ្លាស់ប្ដូរសមាជិករដ្ឋាភិបាលតាមនីតិវិធី។
• លើកសំណើថ្វាយព្រះមហាក្សត្រតែងតាំង ផ្លាស់ប្ដូរ បញ្ចប់ភារកិច្ចមន្ត្រីជាន់ខ្ពស់ស៊ីវិល និងយោធាដោយព្រះរាជក្រឹត្យ ដូចជា ទេសាភិបាល ទេសាភិបាលរងធនាគារជាតិនៃកម្ពុជា ទីប្រឹក្សារាជរដ្ឋាភិបាល ទីប្រឹក្សានាយករដ្ឋមន្ត្រី អគ្គលេខាធិការក្រសួង អគ្គនាយកក្រសួង ប្រតិភូរាជរដ្ឋាភិបាល អភិបាលរាជធានីខេត្ត ឯកអគ្គរាជទូត ប្រេសិតវិសាមញ្ញនិងពេញសមត្ថភាព នាយអគ្គសេនាធិការ នាយអគ្គសសេនាធិការរងចាប់ពីឧត្តម សេនីយ៍ឡើងទៅ។

4. សមាសភាពរដ្ឋាភិបាលកម្ពុជា ព្រមទាំងពន្យល់ពីមុខតំណែងនីមួយៗ

• នាយករដ្ឋមន្ត្រីជាសមាជិករដ្ឋសភា ជាអ្នកដឹកនាំការងារគណៈរដ្ឋមន្ត្រី និងចាត់ចែងបញ្ជារាល់សកម្មភាពរបស់រដ្ឋាភិបាលលើគ្រប់វិស័យ។

- **គណៈរដ្ឋមន្ត្រី** ដឹកនាំដោយនាយករដ្ឋមន្ត្រីមួយរូបអមដោយឧបនាយករដ្ឋមន្ត្រី ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីនិង រដ្ឋលេខាធិការជាសមាជិក គណៈរដ្ឋមន្ត្រីត្រូវប្រជុំរៀងរាល់សប្តាហ៍
- **ឧបនាយករដ្ឋមន្ត្រី** ជាសមាជិករដ្ឋាភិបាលដែលមាន អាសនានុក្រមលើសមាជិករដ្ឋាភិបាលដ៏ទៃទៀត។
- **ទេសរដ្ឋមន្ត្រី** សំដៅលើរដ្ឋមន្ត្រីដែលមានអតីតភាពយូរ
- **រដ្ឋមន្ត្រី** ជាប្រធានស្ថាប័នក្នុងករណីដែលមានរដ្ឋលេខា ធិការជាអនុប្រធានស្ថាប័ន
- **រដ្ឋលេខាធិការ** ជាប្រធានស្ថាប័ននៃរដ្ឋលេខាធិការស្វយ័ត(រដ្ឋលេខាធិការដ្ឋានអាកាសចរណ៍ស៊ីវិលនិង រដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ) ប៉ុន្តែរដ្ឋលេខាធិការដ្ឋានទាំងពីរនេះចំណុះទីស្តីការគណៈរដ្ឋមន្ត្រី។

5. ខុទ្ទកាល័យទីស្តីការគណៈរដ្ឋមន្ត្រីមានភារកិច្ចដូចៈ

- រៀបចំជូននាយករដ្ឋមន្ត្រី ដើម្បីសម្រេចលើសំណុំរឿងទាំងឡាយដែលក្រសួងផ្សេងៗស្នើមក
- ជូនយោបល់ដល់នាយករដ្ឋមន្ត្រី ក្នុងការរៀបចំគោលដៅនៃសកម្មភាពរបស់រដ្ឋាភិបាល
- រាយការណ៍អំពីការវិវត្ត និងការអនុវត្តន៍កិច្ចការទាំងឡាយដែលក្រសួងនានាបានចាត់ចែង
- ទទួលរៀបចំទំនាក់ទំនងជាមួយស្ថាប័នខាងក្រៅ ដូចជាអង្គការ សហជិព អង្គការអន្តរជាតិ

- ពិនិត្យនិងពិគ្រោះលើសេចក្តីព្រាងច្បាប់ ក្រឹត អនុក្រឹត ដែលរៀបចំឡើងដោយក្រសួងផ្សេងៗ មុនដាក់ជូនសម័យប្រជុំពេញអង្គរបស់គណៈរដ្ឋមន្ត្រីពិនិត្យនិង អនុម័ត។

6. ក្រសួង និងរដ្ឋលេខាធិការដ្ឋានត្រូវរៀបចំតាមវិស័យដែលមានទៅតាមជំនាញ។ឧទាហរណ៍ ក្រសួងអប់រំយុវជន និងកីឡា ធ្វើការលើវិស័យអប់រំ។រដ្ឋលេខាធិកាដ្ឋានមុខងារសាធារណៈ។

---

## មេរៀនទី៣ រដ្ឋបាលមូលដ្ឋាន

I. ចូរផ្គូផ្គងផ្នែកA និង B ឱ្យបានត្រឹមត្រូវ

| A | B | ចម្លើយ |
|---|---|---|
| 1. វិមជ្ឈការ<br>2.មជ្ឈការ<br>3.វិសហមជ្ឈការ | ក.ប្រព័ន្ធគ្រប់គ្រងអំណាចស្ថិតនៅលើរដ្ឋបាលថ្នាក់ កណ្តាល<br>ខ.ប្រព័ន្ធគ្រប់គ្រងអំណាចស្ថិតនៅលើរដ្ឋបាលថ្នាក់ក្រោម<br>គ.ស្ថាប័ននានាធ្វើប្រតិភូកម្មលើមុខងារសិទ្ធិអំណាច និងធនធាន<br>ឃ.រដ្ឋបាលកណ្តាលត្រូវរំ លែកអំណាចរបស់ខ្លួនឱ្យ ទៅថ្នាក់ក្រោម | 1. →ឃ<br>2. →ខ<br>3. →គ |

II. ចូរបំពេញល្បះខាងក្រោមឱ្យបានត្រឹមត្រូវ

1. រដ្ឋបាលថ្នាក់កណ្ដាលចូលរួមជួយពិនិត្យលើ ផ្លូវច្បាប់ជូនដល់រដ្ឋបាលថ្នាក់ក្រោម ក្នុងនាម ជា*អាណាព្យាបាល*។
2. ក្នុងលទ្ធិប្រជាធិបតេយ្យ ការធ្វើបញ្ញើអត្រានុកូលដ្ឋានជូនដល់ប្រជារាស្ត្រ គឺជាភារកិច្ចរបស់*ក្រសួងមហាផ្ទៃ*។
3. ការទទួលខុសត្រូវ និងការឆ្លើយតបនឹងតម្រូវ ការប្រជាពលរដ្ឋក្នុងការជួយជំរុញឱ្យមានការ អភិវឌ្ឍឃុំ-សង្កាត់ គឺជាភារកិច្ចរបស់*ក្រុមប្រឹក្សាឃុំ-សង្កាត់*។

## III. សំណួរត្រិះរិះ

1. តើពាក្យមជ្ឈការមានន័យដូចម្ដេច? តើគុណសម្បត្តិ និងគុណវិបត្តិរបស់មជ្ឈការ នាំមកនូវផលប្រយោជន៍និងផលវិបាកអ្វីខ្លះក្នុងការគ្រប់ គ្រងការងារមូលដ្ឋាន ?
2. តើពាក្យវិមជ្ឈការមានន័យដូចម្ដេចខ្លះ ? តើមជ្ឈការ និងវិមជ្ឈការមានលក្ខណៈខុសគ្នាត្រង់ ណាខ្លះ ?
3. តើពាក្យវិសហមជ្ឈការមានន័យដូចម្ដេចខ្លះ ?
4. តើទំហំនៃកម្រិតវិមជ្ឈការរបស់ក្រុមប្រឹក្សាឃុំ- សង្កាត់មានអ្វីខ្លះ ? តើវិមជ្ឈការឃុំ-សង្កាត់ មានអំណាចលើវិស័យអ្វីខ្លះ ?
5. ដើម្បីសម្របសម្រួល និងគាំទ្រដល់ដំណើរការនៃកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ ឱ្យមានប្រសិទ្ធិភាព តើរាជរដ្ឋាភិបាលត្រូវមានវិធានការណ៍ដូចម្ដេចខ្លះ ?

## III. ចម្លើយ

1. មជ្ឈការមាន គឺជាការប្រមូលផ្តុំអំណាច ឬជាប្រព័ន្ធ គ្រប់គ្រងដែលប្រមូលផ្តុំអំណាចនៅតែក្នុងដៃរបស់ រដ្ឋបាលកណ្តាល គឺមានន័យថាអំណាចទាំងអស់នៅតែក្នុងដៃបុគ្គល ឬក្រុមដែលមានអំណាចគ្រប់គ្រង ប្រទេស។

❖ គុណសម្បត្តិ និងគុណវិបត្តិរបស់មជ្ឈការនាំមកនូវផលប្រយោជន៍និងផលវិបាកក្នុងការគ្រប់គ្រងការងារសង្គមមូលដ្ឋាន

- **ផលប្រយោជន៍**

★រដ្ឋអំណាចថ្នាក់ក្រោមអនុវត្តតាមកម្មវិធីរបស់រដ្ឋតែមួយ ដែលជាការពង្រឹងបាននូវឯកភាពជាតិ និងផ្តល់ភាពងាយស្រួលដល់ថ្នាក់កណ្តាលក្នុងការត្រួតពិនិត្យ វាយតម្លៃសកម្មភាពអនុវត្តរបស់ថ្នាក់ក្រោមសម្រួលថ្នាក់កណ្តាលក្នុងការគ្រោងនិងត្រួតពិនិត្យចំណាយចំណូល ថវិកា។

- គុណវិបត្តិ

★រដ្ឋបាលសាធារណៈមិនអាចស្ថិតនៅជិតជាប់នឹងប្រជាពលរដ្ឋ

★មិនបានដឹងពីតម្រូវការរបស់ប្រជាពលរដ្ឋ ក៏ដូចជាតម្រូវការរបស់មូលដ្ឋានឱ្យពិតប្រាកដ ជូនកាលគម្រោងកម្មវិធីដែលថ្នាក់កណ្តាលបានដាក់ចុះ នាំឱ្យខូចប្រយោជន៍ប្រជាពលរដ្ឋក្នុងមូលដ្ឋានណាមួយក៏សឹងមាន។

* រដ្ឋបាលបែបមជ្ឈការជារដ្ឋបាលមានលក្ខណៈបិទជិត
* ប្រជាពលរដ្ឋមិនអាចចូលរួមក្នុងការសម្រេចចិត្តអ្វីមួយ ឬក្នុងការរៀបចំនិងក្នុងការអនុវត្តគម្រោងកម្មវិធីជាតិបានឡើយ
* ធ្វើឱ្យមន្ត្រីរដ្ឋបាលសាធារណៈ យល់ថាខ្លួនឯងជាអ្នកគ្រប់គ្រងប្រជាពលរដ្ឋ ហើយប្រជាពលរដ្ឋក៏យល់ថា ខ្លួនមិនមែនជាម្ចាស់ប្រទេសម្ចាស់វាសនាខ្លួនផ្ទាល់ ហើយផ្ញើវាសនាទៅលើអ្នកដឹកនាំទាំងស្រុង ទោះជាអ្នកដឹកនាំនោះនាំពួកគេឆ្ពោះទៅរកភាពអន្តរាយក៏ដោយ។

2. ពាក្យវិមជ្ឈការមានន័យថា ជាការគ្រប់គ្រងបុគ្គលភាពគតិយុត្តិរបស់រដ្ឋឱ្យទៅសមូហភាព ដែនដីទាំងឡាយណាដែលស្ថិតនៅក្រៅសមូហភាពរដ្ឋ ដើម្បីឱ្យសមូហភពដែនដីនោះមានស្វ័យភាពក្នុងការរៀប ចំប្រជាជននៅក្នុងមូលដ្ឋានរបស់ខ្លួន ឱ្យមានការរីកចម្រើនទាំងផ្នែកខាងស្មារតីនិងទាំងផ្នែកសម្ភារៈ។

❖ មជ្ឈការនិងវិមជ្ឈការមានលក្ខណៈខុសគ្នាត្រង់ថា មជ្ឈការគឺអំណាចប្រមូលផ្តុំនៅក្នុងកំណាប់ដៃរបស់រដ្ឋបាលកណ្តាល។ ហើយភាគច្រើនគឺអនុវត្តនយោបាយផ្តាច់ការ។ឯវិមជ្ឈការវិញគឺការទទួលយកនូវការផ្តល់ស្វ័យភាពពីរដ្ឋបាលកណ្តាល។ មានការដឹកនាំតាមបែបប្រ ជាធិបតេយ្យ។

3. វិសហមជ្ឈការ មានន័យថា រាជរដ្ឋាភិបាល ឬក្រសួង ស្ថាប័នធ្វើប្រតិភូកម្មលើមុខងារ សិទ្ធិអំណាចនិងធន ធាន (ហិរញ្ញវត្ថុ ទ្រព្យសម្បត្តិនិងបុគ្គលិក) ទៅអង្គភាពក្រោម

បង្គាប់ ឬទៅក្រុមប្រឹក្សាប្រភេទណាមួយ ដើម្បីអនុវត្តមុខងារនោះក្នុងនាមរាជរដ្ឋាភិបាល ក្រសួង ស្ថាប័ននោះ។

4. ទំហំនៃកម្រិតវិមជ្ឈការរបស់ក្រុមប្រឹក្សាឃុំ-សង្កាត់ មានគឺៈ
   - ពង្រីកលទ្ធិប្រជាធិបតេយ្យនៅមូលដ្ឋាន
   - ពង្រីកស្វ័យភាពគ្រប់គ្រងលើជីវភាពរស់នៅរបស់ ប្រជាពលរដ្ឋនៅមូលដ្ឋានដែលរដ្ឋអំណាចឬអាជ្ញា កណ្តាល មិនលូកដៃមិនចូលទៅធ្វើជំនួសឡើយ។

❖ វិមជ្ឈការឃុំ- សង្កាត់ មានអំណាចលើវិស័យ
   - អនុម័តលើគំរោងផែនការអភិវឌ្ឍន៍ឃុំសង្កាត់
   - ការអនុម័តលើថវិកាឃុំ-សង្កាត់
   - ការកំណត់តម្លៃសារបើពន្ធមូលដ្ឋាននិងកម្រៃសសេវាផ្សេងៗ
   - ការអនុម័តបទបញ្ញាផ្ទៃក្នុងនិងដីកាឃុំ-សង្កាត់ និងកិច្ចការផ្សេងៗទៀតដែលកំណត់ដោយរដ្ឋមន្ត្រី ក្រសួងមហាផ្ទៃ។

5. ដើម្បីសម្របសម្រួល និងគាំទ្រដល់ដំណើរការនៃកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការឱ្យមានប្រសិទ្ធិភាព រាជរដ្ឋាភិបាលត្រូវមាន វិធានការណ៍ដូច ខាងក្រោមដូចជា ៖

- រៀបចំកម្មវិធីជាតិដើម្បីធ្វើកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ
- រៀបចំឡើងវិញនូវរចនាសម្ព័ន្ធនៃប្រព័ន្ធគ្រប់គ្រងនៅ រដ្ឋបាលមូលដ្ឋាន

• ពង្រឹងប្រព័ន្ធគ្រប់គ្រង ។

## មេរៀនទី៤

## ស្ថាប័នតុលាការនៃព្រះរាជាណាចក្រកម្ពុជា

### <u>សំណួរ</u>

1. តើអំណាចតុលាការគឺជាអ្វី? តើឯករាជភាពនៃអំណាចតុលាការមានន័យដូចម្ដេច?
2. ចូរពន្យល់ពីភាពខុសគ្នា នៃតួនាទីរបស់សាលាជម្រះក្ដីនីមួយៗ។
3. ចូរពន្យល់ពីដំណើរការដំបូងនៃបណ្ដឹងរដ្ឋប្បវេណី។
4. តើដំណើរការបណ្ដឹងព្រហ្មទណ្ឌមានលក្ខណៈដូចម្ដេចខ្លះ?
5. ហេតុអ្វីបានជាបណ្ដឹងរដ្ឋប្បវេណីមានដំណាក់ផ្សេះផ្សា?
6. តើហេតុអ្វីបានជាបណ្ដឹងព្រហ្មទណ្ឌ មិនមានដំណាក់ផ្សះផ្សា? ចូរពន្យល់។
7. ចូរពន្យល់ពីសារៈសំខាន់របស់ស្ថាប័នតុលាការ។

### <u>ចម្លើយ</u>

1. អំណាចតុលាការគឺជាអំណាចឯករាជ មានន័យថាអំ ណាច តុលាការមិនស្ថិតនៅក្រោមឥទ្ធពលនិងការបង្គាប់បញ្ជាពីអំណាចនីតិប្បញ្ញត្តិឬនីតិប្រតិបត្តិឡើយ។

❖ ឯករាជភាព នៃអំណាចតុលាការមានន័យថាថៅក្រមសិទ្ធិក្នុងការកាត់សេចក្ដីដោយមិនស្ថិតនៅក្រោម ឥទ្ធិពលរបស់ស្ថាប័

នណាមួយឡើយ ហើយការការកាត់សេចក្តីឈរលើភាពឥត លំអៀង ដោយការពារសិទ្ធិប្រជាពលរដ្ឋដូចគ្នាទាំងអស់។

2. ពន្យល់ពីភាពខុសគ្នានៃតួនាទីរបស់សាលាជម្រះក្តីនីមួយៗ

- តុលាការដំបូងមាននៅតាមរាជធានី-ខេត្ត
- សាលាក្តីជាន់ទាប មានតុលាការខេត្តក្រុងមានដែនសមត្ថកិច្ច ក្នុងដែនដីរបស់ខ្លួន។ ហើយតុលាការយោធាមានវិសាលភាព ទូទាំងព្រះរាជាណាចក្រកម្ពុជា ជំនុំជម្រះលើរឿងក្តីយោធិន។
- សាលាឧទ្ធរណ៍ មាននៅរាជធានីភ្នំពេញ មានវិសាលភាពនៅ ទូទាំងប្រទេសកម្ពុជា ។ ជំនុំជម្រះក្នុងករណីមិនសុខចិត្តនឹង សេចក្តីសម្រេចរបស់សាលាដំបូង។
- តុលាការកំពូលមាននៅរាជធានីភ្នំពេញ មានវិសាលភាពនៅ ទូទាំងប្រទេសកម្ពុជា។ ជំនុំជម្រះក្នុងករណីដែលមិនសុខចិត្ត នឹងសេចក្តីសម្រេចរបស់សាលាឧទ្ធរណ៍។ ជំនុំជម្រះលើ អង្គច្បាប់ មិនជំនុំជម្រះលើអង្គហេតុទេ។

3. ដំណើរការដំបូងនៃបណ្តឹងរដ្ឋប្បវេណីមាន5 ដំណាក់កាល

- ដំណាក់កាលទី1៖ ការដាក់ពាក្យបណ្តឹង
- ដំណាក់កាលទី2 ៖ ដំណាកការផ្សះផ្សា
- ដំណាក់កាលទី3៖ការចុះបញ្ជីបណ្តឹង និងប្រាក់ប្រដាប់ក្តីនៅ ពេលដែលដើមបណ្តឹងដាក់សំអាងរបស់ខ្លួន ហើយតុលាការ បង្គាប់ឱ្យដើមបណ្តឹងនោះបង់ប្រាក់ប្រ ដាប់ក្តីជាមុនសិនព្រម ទាំងថ្លៃតែមប្រ៊ើលើពាក្យបណ្តឹង ទើបតុលាការអាចទទួល ពាក្យបណ្តឹងនិងធ្វើការជំនុំជម្រះបាន។

- ដំណាក់កាលទី4៖ ដំណាកការស៊ើបសួរក្នុងករណីដែលភាគីទាំងអស់មិនអាចសះជានឹងគ្នាក្នុងដំណាក់ការផ្សះផ្សា។
- ដំណាក់កាលទី5៖ ការប្ដឹងជិតចិត្តជាការប្ដឹងជំទាស់ទៅនឹងសមាសភាពចៅក្រមក្នុងពេលជំនុំជម្រះ។

4. ដំណើរការបណ្ដឹងព្រហ្មទណ្ឌមានលក្ខណៈ មានដូចជា៖

- ស្ថាប័នដែលមានសមត្ថកិច្ចជាពិសេសនគរបាលយុត្តិធម៌
- ជនរងគ្រោះ ឬសាច់ញាតិជនរងគ្រោះអាចប្ដឹងទៅនគរបាលយុត្តិធម៌ ឬទៅព្រះរាជអាជ្ញាតែម្ដង។
- ក្នុងករណីបទល្មើសព្រហ្មទណ្ឌកើតឡើងជាក់ស្ដែងព្រះ រាជអាជ្ញាអាចចាត់ការដំណើរការរឿងព្រហ្មទណ្ឌនោះ ដោយខ្លួនឯងតែម្ដង។
- ចំពោះបណ្ដឹងរដ្ឋប្បវេណី ប៉ុន្តែក្រោយមកតុលាការរកឃើញថាជាបទល្មើសព្រហ្មទណ្ឌនោះតុលាការប្រគល់ រឿងនេះទៅឱ្យអយ្យការចាត់ការជារឿងព្រហ្មទណ្ឌ។

❖ ***ដំណើការបណ្ដឹងព្រហ្មទណ្ឌមាន*** ៖

- ការរៀបចំសំនុំរឿងដោយនគរបាលយុត្តិធម៌ៈ នគរបាលយុត្តិធម៌អាចចាប់ខ្លួនជនល្មើសបានក្នុងករណីបទល្មើសជាក់ស្ដែងនៅកន្លែងកើតហេតុ

5. បានជាបណ្ដឹងរដ្ឋប្បវេណីមានដំណាក់ផ្សះផ្សាព្រោះ ដោយសារនៅក្នុងរឿងក្ដីនេះ មានលក្ខណៈស្រាល។

6. បានជាបណ្តឹងព្រហ្មទណ្ឌមិនមាន ដំណាក់ផ្សះផ្សាព្រោះជារឿងក្តីដែលមានលក្ខណៈធ្ងន់ធ្ងរ ប៉ះពាល់ដល់អាយុជីវិតមនុស្ស។
7. ពន្យល់ពីសារៈសំខាន់របស់ស្ថាប័នតុលាការមាន៖
   - ធ្វើឱ្យមានសណ្តាបធ្នាប់ សន្តិសុខ សុវត្ថិភាព
   - ផ្តល់ភាពយុត្តិធម៌ដល់មនុស្ស
   - ធ្វើឱ្យការអនុវត្តច្បាប់ប្រព្រឹត្តទៅដោយរលូន
   - ការពារសិទ្ធិសេរីភាពរបស់មនុស្ស
   - ទប់ស្កាត់នូវអំពើរំលោភសិទ្ធិលើអ្នកដ៏ទៃនិងការ ប្រើប្រាស់អំណាចហួសហេតុរបស់មនុស្ស។

   និយាយរួមទៅស្ថាប័នតុលាការមានប្រយោជន៍ ណាស់ហើយគ្រប់ប្រទេសទាំងអស់តែងតែមាន។ ជាស្ថាប័នមួយជួយឱ្យប្រទេសមានសន្តិភាព យុត្តិធម៌ សមធម៌ និងការគោរពច្បាប់ ដោយវាបានដោះស្រាយគ្រប់បញ្ហាទំនាស់ទាំងអស់។ បើសិនជាគ្មានស្ថាប័នតុលាការទេនោះប្រទេសនឹងមានភាពអនាធិបតេយ្យអសន្តិសុខ និងធ្វើឱ្យប្រទេសធ្លាក់អាប់អោន។

---

## មេរៀនទី៥ ចំណោទក្នុងសហគមន៍និងដំណោះស្រាយ

### សំណួរ

1. តើការបង្កើតគោលនយោបាយសាធារណៈ របស់រាជរដ្ឋាភិបាលនាំមកនូវផលប្រយោជន៍អ្វីខ្លះជូនដល់ សង្គមជាតិ?
2. តើកត្តាអ្វីខ្លះដែលជាមូលដ្ឋាននៃការបំផ្លាញ ធនធានធម្មជាតិក្នុងសហគមន៍របស់អ្នក?
3. ដើម្បីឱ្យសហគមន៍របស់អ្នកមានភាពរីក ចម្រើនជានិច្ចតើអ្នកមានវិធានការដូចម្ដេចខ្លះក្នុងការថែរក្សានិងការពារធនធានធម្មជាតិក្នុងសហគមន៍ កុំឱ្យមានការខូចខាតនិងវិនាស?

### ចម្លើយ

1. ការបង្កើតគោលនយោបាយសាធារណៈ របស់រាជរដ្ឋាភិបាលបាននាំមកនូវផលប្រយោជន៍ ជូនដល់សង្គមជាតិដូចជា ៖

- លប់បំបាត់ភាពក្រីក្រប្រជាពលរដ្ឋ
- សង្គមមានការអភិវឌ្ឍរីកចម្រើន
- ប្រជពលរដ្ឋគ្រប់រូបមានលទ្ធភាពទទួលសេវាសាធារណៈគ្រប់គ្រាន់
- កាត់បន្ថយការចំណាយរបស់ប្រជាពលរដ្ឋ

2. កត្តាដែលជាមូលដ្ឋាននៃការបំផ្លាញ ធនធានធម្មជាតិក្នុងសហគមន៍របស់ខ្ញុំ

- ការកាប់បំផ្លាញព្រៃឈើហួសប្រមាណ
- ការបំផ្លាញទីជម្រកសត្វព្រៃ មច្ឆជាតិ
- សំណឹកដី
- ទឹកជំនន់
- ការបំពុលទឹក
- ការនេសាទត្រីខុសច្បាប់និងខុសបច្ចេកទេស
- កត្តាភាពក្រីក្ររបស់ប្រជាជន
- ការអនុវត្តច្បាប់ពុំមានប្រសិទ្ធិភាព

3. វិធានការ ក្នុងការថែរក្សានិងការពារធនធានធម្មជាតិ ក្នុងសហគមន៍កុំឱ្យមានការខូចខាតនិងវិនាស
   - ត្រួតពិនិត្យឱ្យបានដិតដល់ទៅលើការបំពុលបរិស្ថាន
   - មានវិធានការប្រកបដោយប្រសិទ្ធិភាពដើម្បីកាត់ បន្ថយបញ្ហាសង្គមដែលកើតចេញពីការបំពុលបរិ ស្ថាន
   - រួមគ្នាថែរក្សាបរិស្ថានធម្មជាតិនិងបរិស្ថានសង្គម

**មេរៀនទី៦ សារៈសំខាន់ក្នុងការធ្វើជំរឿន**

## សំណួរ

1. តើជំរឿនជាអ្វី ? តើប្រទេសកម្ពុជាធ្លាប់ជំរឿនប៉ុន្មានដងមកហើយ? នៅពេលណាខ្លះ ?
2. ហេតុអ្វីបានជារដ្ឋាភិបាលចាំបាច់ធ្វើជំរឿន ? តើជំរឿនត្រូវការព័ត៌មានអ្វីខ្លះពីប្រជាជន ?
3. តើប្រជាពលរដ្ឋត្រូវធ្វើអ្វីខ្លះ ដើម្បីជួយការធ្វើជំរឿនឱ្យបានជោគជ័យ ?

## ចម្លើយ

1. ជំរឿនជាគឺជាការរាប់ចំនួនប្រជាជនទាំងប្រុសទាំងស្រី និងកុមារទាំងអស់ក្នុងប្រទេសមួយតាមពេលវេលា ដែលបានកំណត់ទុក ដើម្បីប្រមែប្រមូលទិន្នន័យក្នុងការធ្វើផែនការអភិវឌ្ឍន៍សម្រាប់អនាគត។

❖ ប្រទេសកម្ពុជាធ្លាប់ជំរឿនចំនួន3ដងមកហើយគឺ ៖

a) ជំរឿននៅឆ្នាំ1962

b) ជំរឿននៅឆ្នាំ 1998

c) ជំរឿននៅឆ្នាំ 2008

2. បានជារដ្ឋាភិបាលចាំបាច់ធ្វើជំរឿន

- ត្រូវការទិន្នន័យដើម្បីធ្វើផែនការអភិវឌ្ឍសេដ្ឋកិច្ច
- សិក្សាស្រាវជ្រាវ
- រៀបចំគំរោងអភិវឌ្ឍន៍ឱ្យចំគោលដៅ។

❖ជំរឿនត្រូវការព័ត៌មានពីប្រជាជនដូចជា៖

- អាយុ ភេទ
- ស្ថានភាពអាពាហ៍ពិពាហ៍
- កម្រិតវប្បធម៌
- ស្ថានភាពគ្រួសារ
- កម្រិតជីវភាព។

3. ដើម្បីជួយការធ្វើ ជំរឿនឱ្យបានជោគជ័យប្រជាពលរដ្ឋ ត្រូវ៖
   - ផ្តល់ពត៌មានដ៏ជាក់លាក់
   - ដឹងឱ្យបានច្បាស់អំពីពត៌មាននៅក្នុងគ្រួសារ ដូចជា ឆ្នាំកំណើត កម្រិតវប្បធម៌...
   - ចំណាយពេលវេលាដើម្បីផ្តល់ពត៌មានដល់មន្ត្រី ជំរឿន
   - សហការជាមួយមន្ត្រីជំរឿនដោយការពេញចិត្តនិងរាក់ទាក់។

## <u>សំណួរ</u>

1. ដូចម្ដេចហៅថា ប្រព័ន្ធនយោបាយ? រដ្ឋសភា? តុលាការ? រដ្ឋាភិបាល?
2. ចូរនិយាយពីគណបក្សនយោបាយ សិទ្ធិនិង សេរីភាព និង ការបោះឆ្នោត។
3. ចូររៀបរាប់ពីប្រព័ន្ធគណបក្ស។
4. ចូរអធិប្បាយពីនគរបាលនិងកងកម្លាំងប្រដាប់ អាវុធ។

## <u>ចម្លើយ</u>

1. ប្រព័ន្ធនយោបាយ គឺជាចង្កោមនៃការដឹកនាំដើម្បីឱ្យមានការអនុវត្តប្រកបដោយប្រសិទ្ធិភាព។

❖ រដ្ឋសភា គឺជាអង្គការនីតិបញ្ញត្តិដែលមាននាទីតាក់តែងច្បាប់។

❖ តុលាការ គឺជាស្ថាប័នឯករាជដែលមាននាទីជំនុំជម្រះក្ដីរឿងរ៉ាវទាំងអស់ និងមានអំណាចកំពូលឯករាជ។

❖ រដ្ឋាភិបាល ជាអង្គការ ឬជាភ្នាក់ងារមួយដែលប្រើអំណាចរបស់វាដើម្បីគ្រប់គ្រងរៀបចំ គោលនយោបាយបោះឆោះដឹកនាំត្រួតពិនិត្យសកម្មភាពអនុវត្តច្បាប់ក្នុងបំណងរក្សា សន្តិភាព សន្តិសុខ សណ្ដាប់ធ្នាប់ យុត្តិធម៌ សេរីភាព សិទ្ធិ មនុស្ស ការអភិវឌ្ឍនិងផ្ដល់សេវាផ្សេងៗទៀតដូចជា ការអប់រំ សុខាភិបាល រដ្ឋបាលជាដើម។

## 2. និយាយពី

- គណបក្សនយោបាយ ក្នុងលទ្ធិប្រជាធិបតេយ្យ មានគណៈនយោបាយដែលតំណាងឱ្យទស្សនៈប្លែកគ្នា។ ប៉ុន្តែសម្រាប់ប្រទេសកុំម៉ុយនីសវិញ គឺមានគណៈបក្សតែមួយប៉ុណ្ណោះ។
- សិទ្ធិ សិទ្ធិត្រូវបានប្រើដោយសេរីនៅក្នុងប្រទេសប្រជាធិបតេយ្យ ប៉ុន្តែនៅក្រោមច្បាប់ជាអ្នកកំណត់ហើយមិនត្រូវឱ្យប៉ះពាល់ដល់សិទ្ធិអ្នកដទៃនោះទេ។ នៅក្នុងប្រទេសកុំម៉ុយនីសគឺគេបានបំបិទសិទ្ធិមិន អាចធ្វើអ្វីៗតាមចិត្តបានឡើយ។
- សេរីភាព គឺមនុស្សមានសេរីភាពក្នុងការបោះឆ្នោត សេរីភាពនិយាយជាចំហ សេរីភាពក្នុងការចូលរួមប្រជុំផ្លាស់ប្តូរយោបល់គ្នាសម្រាប់ប្រទេសប្រជាធិបតេយ្យ។ ប៉ុន្តែសម្រាប់ប្រទេសកុំម៉ុយនីសវិញសេរីភាពត្រូវ បានគេកំណត់ យ៉ាងតឹងតែងជាទីបំផុត។
- ការបោះឆ្នោត ពលរដ្ឋចាប់ពីអាយុ18ឡើងទៅមានសិទ្ធិបោះឆ្នោតជ្រើសរើសសមាជិកសភា ហើយក៏គ្មានការចាប់បង្ខំឱ្យបោះឆ្នោតដែរ។ ការឃោសនាបោះឆ្នោតមានសភាពខ្លាំងក្លាក្នុងពេលបីបួនសប្តាហ៍មុនថ្ងៃបោះឆ្នោត ហើយអ្នកគាំទ្រគណៈបក្សនីមួយៗក៏ដើរបញ្ចុះបញ្ចូលរកសំឡេងឆ្នោតដែរ។
  - ការបោះឆ្នោតចែកជាពីរគឺ តាមឯកត្តនាម និងតាមប្រព័ន្ធសមាមាត្រ។

3. រៀបរាប់ពីប្រព័ន្ធគណបក្ស

- ប្រព័ន្ធពហុបក្ស(ប្រជាធិបតេយ្យ) មានគណៈបក្សជាច្រើន បានចូលរួមប្រកួតប្រជែងក្នុងការជ្រើសតាំងតំណាងឬការបោះឆ្នោត។ គណៈដែលឈ្នះឆ្នោតបានរៀបចំបង្កើតរដ្ឋាភិបាលក្នុង ការដឹកនាំប្រទេស។
- ប្រឯកបក្ស(ផ្តាច់ការ)

4. អធិប្បាយពីនគរបាលនិងកងកម្លាំងប្រដាប់ អាវុធ

នគរបាលទទួលខុសត្រូវចំពោះសហគមន៍មូលដ្ឋាន ដែលខ្លួនបម្រើការងារ។ គេអាចយកភ្នាក់ងារនគរបាល ដែលប្រព្រឹត្តបទល្មើសនឹងច្បាប់ក្នុងពេលបំពេញការងាររបស់ខ្លួនទៅឱ្យតុលាការជំនុំជម្រះបាន។ លើសពីនេះក្រមវិន័យរបស់នគរបាលជាឧបករណ៍រារាំងការរំលោភអំណាចរបស់នគរបាល។ ប្រសិបើភ្នាក់ងារនគរបាលម្នាក់ប្រព្រឹត្តល្មើសនឹងក្រមនេះ គេអាចបណ្តេញចេញពីអង្គភាព។ ភ្នាក់ងារនគរបាលធ្វើការពេញម៉ោង។ គេបង្កើតភ្នាក់ងារនគរបាលពិសេសផងដែរ ហើយភ្នាក់ងារពិសេសនេះ ជាភ្នាក់ងារស្ម័គ្រចិត្តក្នុងអង្គភាពនីមួយៗដែលធ្វើការក្រៅម៉ោងដោយមិនគិតពីបៀវត្សរ៍។

## មេរៀនទី៨ ច្បាប់អន្តោប្រវេសន៍

### សំណួរ

1. តើដូចម្ដេចហៅថា ច្បាប់អន្តោប្រវេសន៍?
2. ហេតុអ្វីបានជាប្រទេសយើងបង្កើតឱ្យមាន ច្បាប់អន្តោប្រវេសន៍?
3. ចូរប្រៀបធៀបជនបរទេសមិនមែនជាអន្តោ ប្រវេសន៍និងជាអន្តោប្រវេសន៍។
4. ចូរពន្យល់ពីការគ្រប់គ្រងជនបរទេស។
5. ចូរពន្យល់ពីការផ្ដន្ទាទោសចំពោះជនបរទេស ទាក់ទងនឹងការអនុវត្តច្បាប់អន្តោប្រវេសន៍។
6. ចូរពន្យល់ការផ្ដន្ទាទោសចំពោះអ្នកសមគំនិត ដែលប្រព្រឹត្តខុសនឹងច្បាប់អន្តោប្រវេសន៍។
7. តើប្អូនត្រូវធ្វើដូចម្ដេច ដើម្បីចូលរួមអនុវត្តច្បាប់អន្តោប្រវេសន៍?

### ចម្លើយ

1. ច្បាប់អន្តោប្រវេសន៍ ជាច្បាប់មួយប្រភេទដែលមានគោលដៅគ្រប់គ្រងជនបរទេសគ្រប់រូបដែលស្នាក់នៅលើទឹកដីនៃព្រះរាជាណាចក្រកម្ពុជា។
2. បានជាប្រទេសយើងបង្កើតឱ្យមាន ច្បាប់អន្តោប្រវេសន៍ ព្រោះប្រទេសយើងជាភាគីហត្ថលេខីនៃច្បាប់ អន្តរជាតិ។

3. ប្រៀបធៀបជនបរទេសមិនមែនជាអន្តោប្រវេសន៍និងជាអន្តោប្រវេសន៍

❖ ជនបរទេសដែលជាជនអន្តោប្រវេសន៍

- ជនដែលមកស្នាក់នៅប្រកបរបររកស៊ីរយៈពេលកំណត់មួយឬយូរ
- ជនបរទេសដែលចូលមកវិនិយោគ
- ជនបរទេសដែលទទួលបានលិខិតអនុញ្ញាតិ ឱ្យចូលមកធ្វើវិនិយោគ

❖ ជនបរទេសដែលមិនមែនជាជនអន្តោប្រវេសន៍

- ជនបរទេសដែលមកទេសចរនៅក្នុងប្រទេសរបស់យើង
- មន្ត្រីទូត មន្ត្រីកុងស៊ុល...។

4. ការគ្រប់គ្រងជនបរទេស

រាល់ជនបរទេសទាំងឡាយណាដែលចេញចូលក្នុងប្រទេសយើងត្រូវមានលិខិតឆ្លងដែនច្បាស់លាស់។

5. ការផ្តន្ទាទោសចំពោះជនបរទេស ទាក់ទងនឹងការអនុវត្តច្បាប់អន្តោប្រវេសន៍៖

ត្រូវបណ្តេញចេញពីប្រទេសក្នុងករណីដែលមិនអនុវត្តច្បាប់នេះ។ និងត្រូវដាក់គុកចំពោះជនបរទេសទាំងឡាយណាដែលចូលមក ព្រះរាជាណាចក្រកម្ពុជាដោយគ្មានច្បាប់អនុញ្ញាត។ ហើយនឹងត្រូវឱ្យបង់ជាប្រាក់ទៀត ផងដែរ។

6. ការផ្តន្ទាទោសចំពោះអ្នកសមគំនិតដែលប្រព្រឹត្តខុសនឹងច្បាប់អន្តោប្រវេសន៍។

- ផ្តន្ទាទោសចំពោះអ្នកណាដែលផ្តល់ជំនួយ ឬជួយលាក់បាំងក្នុងការបញ្ចូលជនបរទេស ដែលគ្មានការអនុញ្ញាតមកក្នុងព្រះរាជាណាចក្រកម្ពុជា ដាក់គុកពីបីទៅ6 ខែ។
- មន្ត្រី ឬភ្នាក់ងាររាជការមានសមត្ថកិច្ចរូបណា ជាអ្នកសមគំនិត ត្រូវដាក់គុក6ខែដល់មួយឆ្នាំ។
- ជនណាសរសេរឈ្មោះក្លែងក្លាយផ្តល់ប័ណ្ណស្នាក់នៅ ប័ណ្ណការងារ កិច្ចសន្យា ។ត្រូវផ្តន្ទាទោសពី5ឆ្នាំទៅ10ឆ្នាំ។
- ត្រូវពិន័យជាប្រាក់ទៀតផង។

7. ដើម្បីចូលរួមអនុវត្តច្បាប់អន្តោប្រវេសន៍យើងត្រូវ ៖

  - យល់ឱ្យបានច្បាស់អំពីច្បាប់អន្តោប្រវេសន៍
  - កុំសមគំនិតធ្វើការរំលោភច្បាប់នេះ
  - ជួយណែនាំប្រជាពលរដ្ឋឱ្យយលដឹងពីច្បាប់ អន្តោប្រវេសន៍។
  - ជួយផ្តល់ពត៌មានដល់មន្ត្រីមានសមត្ថកិច្ច។

## មេរៀនទី៩ ច្បាប់សញ្ជាតិ

### សំណួរ

1. ដូចម្តេចហៅថា ច្បាប់សញ្ជាតិ?
2. ហេតុអ្វីបានជារាជរដ្ឋាភិបាលបង្កើតច្បាប់នេះ ឡើង?
3. ចូរពន្យល់ពីការទទួលបានសញ្ជាតិខ្មែរពីកំណើតនិងដោយអាពាហ៍ពិពាហ៍។
4. តើជនបរទេសត្រូវមានលក្ខណសម្បត្តិដូច ម្តេចខ្លះ ដែលអាចសុំចូលជាសញ្ជាតិខ្មែរបាន?
5. ពន្យល់ពីទោសទណ្ឌទាក់ទងនឹងការក្លែងបន្លំ អត្តសញ្ញាណប័ណ្ណនិងលិខិតឆ្លងដែនប្រជា ពលរដ្ឋខ្មែរ។

### ចម្លើយ

1. ច្បាប់សញ្ជាតិគឺជាច្បាប់ដែលកំណត់អំពីពូជ ពង្សវង្សត្រកូលជាតិកំណើតរបស់មនុស្សនៅលើទឹក ដីដែលខ្លួនរស់នៅ។
2. បានជារាជរដ្ឋាភិបាលបង្កើតច្បាប់នេះ ឡើងព្រោះ
- ដើម្បីផលចំនេញខាងសិទ្ធិបោះឆ្នោត
- សិទ្ធិក្នុងការប្រកបអាជីវកម្មផ្សេងៗ
3. ពន្យល់ពីការទទួលបានសញ្ជាតិខ្មែរពីកំណើត
- ត្រូវទទួលបានសញ្ជាតិខ្មែរ ដោយកើតនៅក្នុងព្រះរាជាណាចក្រកម្ពុជា
  - កូនដែលកើតពីឪពុក និងម្តាយបរទេសដែលកើត និងរស់នៅស្របច្បាប់ក្នុងព្រះរាជាណាចក្រកម្ពុជា

- កូនដែលកើតពីឪពុកនិងម្តាយដែលមិនស្គាល់ និងកូនដែលដែលទើបនឹងកើតដែលគេរើសបាននៅក្នុងព្រះរាជាណាចក្រកម្ពុជា ត្រូវទុកថាកើតនៅក្នុងព្រះរាជាណាចក្រកម្ពុជាដែរ

• ត្រូវទទួលបានសញ្ជាតិខ្មែរ ទោះបីកើតនៅទីណាក៏ដោយ៖
  - កូនមានខាន់ស្លាដែលកើតមកពីឪពុកឬម្តាយមានសញ្ជាតិខ្មែរ
  - កូនឥតខាន់ស្លាដែលកើតមកពីឪពុកឬម្តាយមានសញ្ជាតិខ្មែរទទួលស្គាល់
  - កូនដែលឪពុកម្តាយមិនទទួលស្គាល់ កាលបើតុលាការបានចេញសាលក្រមថា កូននោះពិតជាកើតពីឪពុក ឬម្តាយដែលមានសញ្ជាតិខ្មែរ។

• ដោយអាពាហ៍ពិពាហ៍

សញ្ជាតិខ្មែរដោយអាពាហ៍ពិពាហ៍ ជាការទទួលបានសញ្ជាតិខ្មែរតាមរយៈអាពាហ៍ពិពាហ៍ដោយបានកំណត់ដោយច្បាប់ មានន័យថា ស្ត្រីឬបុរសបរទេស ដែលយកប្តី ឬប្រពន្ធខ្មែរដោយបានរៀបអាពាហ៍ពិពាហ៍ អាចទាមទារសញ្ជាតិខ្មែរបានលុះត្រាតែស្ត្រី ឬបុរសនោះរស់នៅជាមួយគ្នារយៈពេលបីឆ្នាំ ក្រោយ ពេលចុះសំបុត្រអាពាហ៍ពិពាហ៍។

បែបបទនិងនីតិវិធីនៃការទាមទារសញ្ជាតិខ្មែរ និងការផ្តល់សញ្ជាតិខ្មែរត្រូវសម្រេចតាមច្បាប់កំណត់។ផ្ទុយទៅវិញប្រជា

ពលរដ្ឋខ្មែរមិនបាត់សញ្ជាតិខ្មែរដោយសារការរៀបអាពាហ៍ពិពាហ៍ជាមួយបរទេស។

4. លក្ខណសម្បត្តិរបស់ជនបរទេសដែលអាចសុំចូលជាសញ្ជាតិខ្មែរបានមាន ៖

- **លក្ខខណ្ឌទូទៅ**
  - មានលិខិតបញ្ជាក់ថា មានគំនិតមារយាទនិងសីលធម៌ដែលចេញដោយមេឃុំ ឬចៅសង្កាត់ខ្លួនរស់នៅ
  - មានលិខិតថ្កោលទោសបញ្ជាក់ថា ពុំដែលមានទោសពីបទព្រហ្មទណ្ឌណាមួយ
  - មានលិខិតបញ្ជាក់ថា ជននោះមានលំនៅក្នុងព្រះរាជាណាចក្រកម្ពុជា ហើយស្នាក់នៅជាប់ចំនួន7ឆ្នាំ ដោយគិតពីថ្ងៃ ដែលបានទទួលប័ណ្ណស្នាក់នៅ ដែលចេញឱ្យក្នុងក្របខ័ណ្ឌនៃច្បាប់ជនអន្តោប្រវេសន៍
  - មានទីលំនៅក្នុងព្រះរាជាណាចក្រកម្ពុជានៅពេល ដាក់ពាក្យសុំសញ្ជាតូបនីយកម្ម
  -ចេះនិយាយភាសាខ្មែរ ចេះអក្សរខ្មែរ និងយល់ដឹងប្រវត្តិសាស្ត្រខ្មែរខ្លះៗ ហើយបង្ហាញភស្តុតាងច្បាស់ថាខ្លួនអាចរស់នៅក្នុងសង្គមខ្មែរ បានដោយសុខដុមព្រមទាំងទទួលបាននូវ ទំនៀមទំលាប់ និងប្រពៃណីខ្មែរ
  - មានបញ្ញានិងកាយសម្បទាដែលមិននាំឱ្យគ្រោះថ្នាក់ ឬនាំឱ្យមានបន្ទុកដល់ជាតិ។
- **លក្ខខណ្ឌគុណសម្បត្តិ**

ជនបរទេសដែលបានធ្វើអំណោយ ជាប្រាក់ដល់ថវិកាជាតិចាប់ពី មួយពាន់លានរៀលឡើងទៅ ឬបានបង្ហាញនូវភស្តុតាងថា ខ្លួនបានផ្តល់គុណសម្បត្តិពិសេសឬថ្វីដៃពិសេសអ្វីមួយជាប្រយោជន៍ដល់ការ ស្តារនិងកសាងសេដ្ឋកិច្ចនៃព្រះរាជាណាចក្រកម្ពុជា ជនបរទេសនោះអាចធ្វើពាក្យសុំចូលសញ្ជាតិខ្មែរបាន ក្នុងករណីដែលជននោះបំពេញបានចំណុចមួយចំនួន ក្នុងលក្ខខណ្ឌទូទៅ។

- **លក្ខខណ្ឌសហព័ន្ធ**

ជនបរទេសដែលមានសហព័ន្ធ ឬកូនដែលមានអាយុតិចជាង18ឆ្នាំដែលមានបំណងសុំចូលសញ្ជាតិជាចង្កោមគ្រួសារ។

បែបបទនិងនីតិវិធីនៃការសុំសញ្ជាតិខ្មែរ ការសម្រេចផ្តល់សញ្ជាតិខ្មែរត្រូវកំណត់ដោយច្បាប់ និងជនដែលបានអនុញ្ញាតឱ្យចូលជាសញ្ជាតិខ្មែរ ត្រូវធ្វើសម្បថនៅចំពោះមុខតុលាការកំពូល។

5. ពន្យល់ពីទោសទណ្ឌទាក់ទងនឹងការក្លែងបន្លំ អត្តសញ្ញាណប័ណ្ណនិងលិខិតឆ្លងដែនប្រជាពលរដ្ឋខ្មែរ ៖

- ជនបរទេសណាដែលកាន់កាប់ និងប្រើប្រាស់អត្ត សញ្ញាណប័ណ្ណសញ្ជាតិខ្មែរ ឬលិខិតឆ្លងដែននៃព្រះរាជាណាចក្រកម្ពុជា ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី 5 ឆ្នាំ ដល់10 ឆ្នាំ
- ជនដែលខ្លែងធ្វើការកោសលប់ សរសេរត្រួតឬឱ្យគេ សរសេរឈ្មោះក្លែងក្លាយនៅក្នុងអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ ឬ

លិខិតឆ្លងដែននៃព្រះរាជាណាចក្រកម្ពុជា ឬមួយប្រើប្រាស់ឯកសារទាំងនោះត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី5ទៅដល់10ឆ្នាំ។

- មន្ត្រីភ្នាក់ងាររាជការ ឬជនដែលសមគំនិតជួយលាក់បាំង ឬផ្តល់អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ ត្រូវផ្តន្ទាទោសដូចគ្នានឹងជនដែលកាន់កាប់អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ ឬលិខិតឆ្លងដែនដោយខុសច្បាប់។

---

## មេរៀនទី១០ សេដ្ឋកិច្ចពិភពលោក

### សំណួរ

1. ដូចម្តេចហៅថា វិសមភាពសេដ្ឋកិច្ច? ចូរបង្ហាញពីនិយមន័យនៃភាពក្រីក្រ។
2. តើអ្វីខ្លះជាបុព្វហេតុនៃភាពក្រីក្រ? ចូរនិយាយពីពាណិជ្ជកម្មពិភពលោក។
3. ក្នុងវិស័យសេដ្ឋកិច្ច តើប្រទេសណាខ្លះនៅអាស៊ីដែលគេចាត់ទុកថាជាខ្លាទាំងបួន? កូនខ្លា?

## ចម្លើយ

1.វិសមភាពសេដ្ឋកិច្ច (ឬភាពខុសគ្នាខាងទ្រព្យសម្បត្តិ និងប្រាក់ចំណូល)គឺរួមបញ្ចូលនូវភាពខុសគ្នាទាំង អស់នៅក្នុងរបាយការណ៍ស្តីពីទ្រព្យសកម្មសេដ្ឋ កិច្ចនិងប្រាក់ចំណូល ។ វិសមភាពសេដ្ឋកិច្ចសំដៅទៅរកសមភាពនៃលទ្ធផល និងទាក់ទងទៅនឹងគំនិតស្តីពីសមភាពខាងឱកាស។

❖ ភាពក្រីក្រ គឺជាលក្ខខណ្ឌសេដ្ឋកិច្ច ដែលប្រជាជនមិនមានប្រាក់ចំណូលគ្រប់គ្រាន់ដើម្បីទទួលបាន កម្រិតអប្បបរមានៃសេវាសុខភាព ម្ហូបអាហារ ផ្ទះសំបែង សំលៀកបំពាក់ និងការអប់រំដែលជា ទូទៅគេទទួលស្គាល់ថាជាភាពចាំបាច់ដើម្បីធ្វើ ឱ្យមានកម្រិតជីវភាពរស់នៅល្អប្រសើរ។

2.បុព្វហេតុនៃភាពក្រីក្រ

- កង្វះសមត្ថភាពក្នុងការរកចំណូល
- ការមិនឱកាសទទួលសេវាអប់រំ
- ការអនុវត្តសេដ្ឋកិច្ចនៅមានកម្រិតទាប
- គ្រោះធម្មជាតិ សង្គ្រាមរ៉ាំរ៉ៃ អំពើពុករលួយ កំណើនប្រជាជនហួសប្រមាណ។

❖ ពាណិជ្ជកម្មពិភពលោក

ពាណិជ្ជកម្ម ត្រូវបានគេវាយតម្លៃតាមរយៈការនាំចេញនិងការនាំចូលផលិតផលនិងសេវា ។ ការរីកចម្រើននៃផលិតផលនិងប្រាក់ចំណូលក្នុង ពិភពលោកកើតឡើង ព្រមគ្នាជាមួយការរីកចម្រើន នៃពាណិជ្ជកម្មអន្តរជាតិតាំងពីដើមស.

ទី១៩ ។ កត្តាទាំងនេះនាំឱ្យមានទស្សនៈទូទៅមួយ ជឿថា ពាណិជ្ជកម្មអន្តរជាតិគឺជា "ម៉ាស៊ីននៃការរីកចម្រើនខាងសេដ្ឋកិច្ច" ដែលរួមមានទាំងបុព្វហេតុនិងភាពងាយស្រួល។ ទំនាក់ទំនងនេះគេ អាចមើលឃើញតាមរយៈការកើនឡើង និងការ ថយចុះនៅក្នុងវដ្តនៃពាណិជ្ជកម្មទំនើប។

លក្ខណៈពិសេសនៃពាណិជ្ជកម្មអន្តរជាតិ ដែលអាចក្លាយទៅជាបាតុភូតសកល នោះគឺដោយសារតែក្នុងពេលបច្ចុប្បន្ន ជាទូទៅប្រទេសនីមួយៗបានធ្វើពាណិជ្ជកម្មជាមួយប្រទេសជាច្រើនពាសពេញពិភពលោក មិនមែនគ្រាន់តែធ្វើជាដៃគូនៃប្រទេសមួយ តាមរយៈកិច្ចព្រមព្រៀងនៃរដ្ឋាភិបាលរបស់ពួកគេប៉ុណ្ណោះទេ។ ស្ថាប័នសំខាន់ដែលរៀបចំបង្កើតពិភពពាណិជ្ជកម្មសេរីពហុប្រទេស គឺកិច្ចព្រមព្រៀងទូទៅស្តីពី ពាណិជ្ជកម្មនិងតារាងពន្ធគយ(GATT) ។ ផ្អែកលើ កិច្ចព្រមព្រៀងនេះ ប្រទេសនីមួយៗបានចូលរួម ក្នុងការចរចាដើម្បីកាត់បន្ថយរបាំងពន្ធគយនិង របាំងមិនមែនពន្ធគយក្នុងពាណិជ្ជ។ អង្គការពាណិជ្ជកម្មពិភពលោកត្រូវបានគេបង្កើតឡើង ដើម្បីរៀបចំច្បាប់ស្តីពីពាណិជ្ជពិភពលោក។

3. ក្នុងវិស័យសេដ្ឋកិច្ច ប្រទេសនៅអាស៊ីដែលគេចាត់ទុកថាជាខ្លាទាំងបួនគឺ ៖

- **តៃវ៉ាន់**
- **កូរ៉េខាងត្បូង**
- **សិង្ហបូរី**

• ហុងកុងរួមទាំងប្រទេសចិន

❖ ប្រទេសកូនខ្លានៅអាស៊ី មាន ថៃ ម៉ាលេស៊ី និង វៀតណាម។

---

## មេរៀនទី១១ បរិស្ថានពិភពលោក

### សំណួរ

1. តើបរិស្ថានជាអ្វី? តើអ្នកមានវិធានការដូចម្តេចខ្លះដើម្បីឱ្យបរិស្ថានក្នុងសហគមន៍របស់អ្នក មានភាពស្រស់បំព្រងជានិច្ចនិរន្តរ៍?
2. តើកត្តាអ្វីខ្លះដែលគេចាត់ទុកថា ជាការបំផ្លាញស្រទាប់អូសូន?
3. តើកត្តាអ្វីខ្លះដែលធ្វើឱ្យផែនដីឡើងកម្តៅ?

### ចម្លើយ

1. បរិស្ថានសំដៅលើពិភពមានជីវិត និងពិភពគ្មាន ជីវិត ដែលនៅជុំវិញខ្លួនយើងដូចជា ខ្យល់ ដី ទឹក រុក្ខជាតិ សត្វ ទន្លេ សត្វល្អិត មនុស្សនិងអ្វីៗដែល មនុស្ស បានបង្កើតឡើងដូចជា លំនៅឋាន កសិដ្ឋាន ប្រាសាទ នានាជាដើមដែលជាផ្នែកមួយនៃបរិស្ថាន ដែរព្រោះ សកម្មភាពរបស់មនុស្សយើង មានឥទ្ធិពលយ៉ាងខ្លាំង ខ្លាក្នុងការកែប្រែពិភព ធម្ម ជាតិ ។

❖ វិធានការដើម្បីឱ្យបរិស្ថានក្នុងសហគមន៍របស់យើង មានភាពស្រស់បំព្រងជានិច្ចនិរន្តរ៍ ៖

- កាត់បន្ថយការបញ្ចេញ ឧស្ម័នផ្ទះកញ្ចក់ដោយប្តូរទៅប្រើប្រាស់ប្រភពផ្សេងៗទៀតជំនួស
- បង្កើនការអភិរក្សថាមពល
- លប់បំបាត់ការកាប់បំផ្លាញព្រៃឈើ
- ដាំព្រៃឈើឡើងវិញ
- ស្តារដីវាលស្មៅ
- បង្កើតច្បាប់ការពារបរិស្ថាន
- ចូលរួមទិវាបរិស្ថាន
- កាត់បន្ថយភាពក្រីក្រ
- អប់រំប្រជាជន

2. កត្តាដែលគេចាត់ទុកថា ជាការបំផ្លាញស្រទាប់អូសូនមាន ៖

- សមាសធាតុកក្លរ៉ូភ្លុយអរ៉ូការបូន ដែលមាននៅ ក្នុងអង្គធាតុរាវសម្រាប់ធ្វើជាមេត្រជាក់ក្នុងទូទឹកកក ក្នុងកំប៉ុងថ្នាំបាញ់ និងមេបំប៉ោងនៅក្នុងរោង ចក្រជ័រប្លាស្ទិចវេចខ្ចប់។
- កំណើននៃរោងចក្រឧស្សាហកម្ម។

3. ផែនដីឡើងកម្តៅដោយសារ ៖

- ការកើនឡើងនៃឧស្ម័នផ្ទះកញ្ចក់
- កំណើនយ៉ាងឆាប់រហ័សនៃការអភិវឌ្ឍទីក្រុង
- កំណើននៃការប្រើប្រាស់ថាមពលនិងឥន្ធនៈមាន សារធាតុបំពុល
- កំណើនឧស្សាហកម្មនិងការកាប់ឆ្ការព្រៃឈើ យកដីដាំដំណាំ

• ការអនុវត្តច្បាប់បរិស្ថាននៅមានភាពធូរលុង។

## មេរៀនទី១២ ពលរដ្ឋពិភពលោក

### សំណួរ

1. ចូរបង្ហាញពីប្រទេសចំនួនប្រាំ ដែលមានប្រជាជនច្រើនជាងគេ?
2. តើប្រទេសណាដែលមានចំនួនប្រជាជនច្រើន ជាងគេបំផុតក្នុងពិភពលោក?
3. តើពិភពលោកទាំងមូលមានចំនួនប្រជាជនសរុបទាំងអស់ប៉ុន្មាន?
4. តើកំណើនប្រជាជនផ្តល់ការលំបាកអ្វីខ្លះដល់ សង្គមមនុស្ស? ចូរពន្យល់។
5. តើយើងត្រូវមានមធ្យោបាយអ្វីខ្លះដើម្បីដោះ ស្រាយបញ្ហានានាដែលកើតមកពីកំណើន ប្រជាជននេះ?

### ចម្លើយ

1. ប្រទេសចំនួនប្រាំដែលមានប្រជាជនច្រើនជាងគេ៖

- សាធារណរដ្ឋប្រជាមានិតចិន
- ឥណ្ឌា
- សហរដ្ឋអាមេរិច
- ឥណ្ឌូណេស៊ី
- ប្រេស៊ីល

2. ប្រទេសដែលមានចំនួនប្រជាជន ច្រើនជាងគេបំផុតក្នុង ពិភពលោកគឺប្រទេសចិនដែលមានមួយពាន់បីរយ សាមសិប ប្រាំពីលាន ប្រាំបីរយដប់ពាន់នាក់ (1 337 810 000នាក់) ក្នុងខែ ឧសភាឆ្នាំ 2010។

3. យោងតាមស្ថាប័នជំរឿនសហរដ្ឋអាមេរិច ដែលធ្វើការ ប៉ាន់ស្មានកាលពីថ្ងៃទី 12ខែឧសភាឆ្នាំ2010ចំនួនប្រជាជនសរុបនៅលើពិភពលោកមានប្រាំមួយពាន់ប្រាំបីរយ ម្ភៃបួនលាន បីរយពាន់នាក់( 6 824 300 000 នាក់)។

4. កំណើនប្រជាជនផ្តល់ការលំបាក ដល់សង្គមមនុស្សដូចជា៖

- ការខ្វះទឹកស្អាតសម្រាប់ផឹកនិងប្រើប្រាស់ ខ្វះថាមពល ការបង្កើនការបំពុល ឬការធ្វើឱ្យកខ្វក់ខ្យល់ ទឹក ដី ការរំខានដោយសំឡេង ការកាប់បំផ្លាញព្រៃឈើនិងការធ្វើឱ្យខូចប្រព័ន្ធអេកូឡូស៊ី ដែលជួយឱ្យមានលំនឹងរវាង អុកស៊ីសែននិងឧស្ម័នកាបូនិចក្នុងបរិយាកាស។
- ការកើនឡើងកម្តៅលើពិភពលោក បាត់បង់ដីដែលអាចដាំដំណាំបាន និងខ្សោះ ជី ជាតិដី បំផ្លាញសត្វព្រៃ ជាពិសេសប្រភេទ សត្វកម្រ។
- ការកើនឡើងនៃវិស័យឧស្សាហកម្ម នាំឱ្យមានការបំពុលកាន់តែខ្លាំង។
- ការកើនភាពក្រីក្រ ការទ្រុឌទ្រោមសុខភាព និងជំងឺដែលធ្វើឱ្យមនុស្សមានអាយុខ្លី។

- ការកើនឡើងនូវអំពើលួចប្លន់ ចាប់ជំរិត ភេរវកម្ម ការជួញដូរគ្រឿងញៀន អំពើអសីលធម៌ទៅលើកុមារនិងទារក ទំនាស់និងការប៉ះទង្គិចគ្នាក្នុងការដណ្ដើមធនធាន។
- សេរីភាពបុគ្គលថយចុះ ការរំលោភបំពានច្បាប់កើនឡើង។

5. យើងត្រូវមានមធ្យោបាយ ដើម្បីដោះស្រាយបញ្ហានានាដែលកើតមកពីកំណើនប្រជាជននេះគឺ៖

- យើងត្រូវផ្ដោតការយកចិត្តទុកដាក់ទៅលើការអប់រំអំពី ផលវិបាកនៃកំណើននេះ និងអប់រំប្រជាជនឱ្យចេះធ្វើផែនការគ្រួសារ វិធីគ្រប់គ្រងកំណើតនិងមធ្យោបាយគ្រប់គ្រងកំណើតដូចជាការប្រើប្រាស់ស្រោមអនាម័យ ថ្នាំគ្រាប់ ថ្នាំចាក់ កងដាក់ដៃ កងដាក់ស្បូន ការចងដៃ ស្បូន ការចងបំពង់មេជីវិតនិងវិធីផ្សេងទៀតសម្រាប់ពន្យារឬបញ្ឈប់កំណើត។
- ពង្រីកការអប់រំ ដើម្បីឱ្យមានការអភិវឌ្ឍប្រកបដោយនិរន្តរភាព។
- ចូលរួមការពារកុំឱ្យមានការបំពុល ឬធ្វើឱ្យតខូចបរិស្ថាន។
- ត្រូវចូលរួមចំណែកសន្សំសំចៃទឹកស្អាតសម្រាប់ផឹក ម្ហូបអាហារ ថាមពលនិងធនធានដទៃទៀត ទប់ស្កាត់ការបំផ្លាញព្រៃឈើ និងការបំផ្លាញធនធានកម្រផ្សេងទៀត។
- ចូលរួមកាត់បន្ថយភាពក្រីក្រនិងទប់ស្កាត់អំពើ លួច ប្លន់ ចាប់ជំរិត ភេរវកម្ម ការជួញដូរគ្រឿង ញៀន ទំនាស់និងការប៉ះទង្គិចគ្នាក្នុងការ ដណ្ដើមធនធាននិងទប់ស្កាត់ជំងឺតម្កាត់ផ្សេងៗ ។

# ចម្លើយបញ្ចប់ជំពូកទី3

I. គូសសញ្ញា✓ក្នុងប្រអប់ដែលមានចម្លើយ ត្រូវតែមួយគត់ ៖

1. ជំរឿនឆ្នាំ២០០៨ធ្វើឡើងក្នុងអំឡុងថ្ងៃ

☐ក.7–12ខែមីនា ☐ខ.3–12ខែមីនា

☑គ.3–13ខែមីនា។

2. ការធ្វើជំរឿនជាសមត្ថកិច្ចរបស់

☐ក.អង្គការអន្តរជាតិ ☐ខ.អង្គការរដ្ឋាភិបាលនានា

☐គ.អង្គការសង្គមស៊ីវិល ☑ឃ.ក្រសួងផែនការ

3. រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា(1993) បានប្រកាសឱ្យប្រើប្រាស់ជាផ្លូវការនៅថ្ងៃ

☐ក.23តុលា1991 ☑ខ.24កញ្ញា1993 ☐គ.7មករា1979

4. ប្រព័ន្ធច្បាប់នៅកម្ពុជាត្រូវបានគេបំផ្លាញទាំងស្រុងក្នុងអំឡុងឆ្នាំ

☐ក.1970–1975 ☑ខ.1975–1979

☐គ.1863–1953 ☐ឃ.1979–1985។

5. កាលបើមានវិវាទធ្ងន់ធ្ងរលើសសមត្ថកិច្ច គ.ជ.ប ដោះស្រាយបាន ស្ថាប័នដែលដោះស្រាយចុងក្រោយបង្អស់គឺ

☐ក.ក្រុមប្រឹក្សានៃអង្គចៅក្រម

☐ខ.ក្រុមប្រឹក្សារាជបល្ល័ង្ក ☑គ.ក្រុមប្រឹក្សាធម្មនុញ្ញ។

6. រដ្ឋបាលមូលដ្ឋានមានសិទ្ធិចេញ

☐ក.ប្រកាស ☑ខ.ដីកា

☐គ.អនុក្រិត្យ ☐ឃ.ព្រះរាជក្រិត្យ។

7. បណ្តឹងដែលទាក់ទងនឹងសិទ្ធិឯកជន ឬបណ្តឹងទាមទារឱ្យមានការជួសជុលការអន្តរាយខាងសម្ភារៈ និងសងជម្ងឺចិត្តហៅថា

☑ក.បណ្តឹងរដ្ឋប្បវេណី ☐ខ.បណ្តឹងអាជ្ញា

☐គ.បណ្តឹងឧទ្ធរណ៍។

8. បទល្មើសដែលប្រព្រឹត្តដោយយោធិនត្រូវ ទទួលការជំនុំជម្រះនៅ

☐ក.តុលាការរាជធានី-ខេត្ត☑ខ.តុលាការយោធា

☐គ.តុលាការកំពូល ☐ឃ.តុលាការឧទ្ធរណ៍។

9. សេចក្តីសម្រេចរបស់ក្រុមប្រឹក្សាធម្មនុញ្ញជា សេចក្តីសម្រេច

☑ក.បិទផ្លូវតវ៉ា ☐ខ.អាចប្តឹងឧទ្ធរណ៍ ☐គ.អាចប្តឹងទៅតុលាការកំពូល។

10.អំណាចដែលគ្របដណ្តប់លើរឿងក្តីទាំងអស់ រួមទាំងរឿងក្តីរដ្ឋបាលផងគឺ

☐ក.អំណាចនីតិប្រតិបត្តិ

☐ខ.អំណាចនីតិបញ្ញត្តិ ☑គ.អំណាចតុលាការ។

11.របបគ្រប់គ្រងដែលយកប្រជារាស្ត្រជាធំគឺ

☑ក.របបប្រជាធិបតេយ្យ ☐ខ.របបរាជាធិបតេយ្យ
☐គ.របបសក្តិភូមិ។

II. ចូរបំពេញឃ្លាខាងក្រោមឱ្យបានត្រឹមត្រូវ

1. ស្ថាប័នដែលមាននាទីការពាររដ្ឋធម្មនុញ្ញគឺ *នីតិប្រតិបត្តិ*។
2. គេកំណត់រដ្ឋបាលកណ្តាលនូវ *មជ្ឈការ*។
3. នាយករដ្ឋមន្ត្រីនៃរដ្ឋាភិបាលកម្ពុជាមានអាយុ យ៉ាងតិច ***25 ឆ្នាំ*** ។
4. គេកំណត់រដ្ឋបាលមូលដ្ឋាននូវ *វិមជ្ឈការ*។
5. ជំរឿននៅកម្ពុជាឆ្នាំ1921ធ្វើឡើងក្នុងបំណង *ប្រមូលពន្ធ* ។
6. ជំរឿននៅកម្ពុជាឆ្នាំ 2008 ធ្វើឡើងក្នុងបំណង ***រាប់ចំនួនប្រជាជន*** ។
7. គេកំណត់រយៈពេលជំរឿន ***10ឆ្នាំ*** ម្តង។
8. មន្ត្រីធ្វើការក្នុងឃុំបន្ទាប់ពីមេឃុំហៅថា *ជំទប់*។
9. ព្រះមហាក្សត្រទ្រង់ឡាយព្រះហស្តលេខាលើ *ព្រះរាជក្រឹត្យ* ដើម្បីតែងតាំង ឬដកហូតងារឧត្តមមន្ត្រី។
10. ជនជាប់ចោទដែលតុលាការបានសម្រេចដាក់ពន្ធនាគារតាមរយៈសាលក្រមស្ថាពរមួយគេ ហៅជននោះជា ***ទណ្ឌិត*** ។
11. ក្រៅពីជនជាតិភាគតិចដែលមានដើមកំណើត ក្នុងប្រទេសណាមួយ ជនជាតិផ្សេងៗដែលស្នាក់នៅប្រកបមុខរបរក្នុងប្រទេសនោះហៅថា ***អាណិកជន*** ។

12. ចៅក្រម និងព្រះរាជអាជ្ញាតែងតាំងដោយ *ព្រះមហាក្សត្រ*. តាមសំណើរបស់ឧត្តមក្រុមប្រឹក្សានៃអង្គ ចៅក្រម។

13. រដ្ឋបាលខេត្ត រាជធានីនៃព្រះរាជាណាចក្រកម្ពុជាជាស្ថាប័នចំណុះឱ្យ *ក្រសួងមហាផ្ទៃ* ។

14. យុត្តិធម៌ត្រូវបានគេស្វែងរកតាមរយៈ *ចៅក្រម*ហើយការដោះស្រាយវិវាទដោយឈរលើ *ការយោគយល់*។

15. អ្នកញុះញង់ អ្នកជួយទំនុកបម្រុងអ្នកផ្តល់មធ្យោបាយ ឬអ្នកជួយសម្រួលឱ្យគេប្រព្រឹត្តបទល្មើសហៅ ថា *ជនសមគំនិត*។

16. អ្នកចូលរួមប្រព្រឹត្តបទល្មើសមានឆន្ទៈដូចគ្នា ជាមួយចារី ហើយមានវត្តមានជាមួយគ្នានៅកន្លែងកើតហេតុហៅថា *សហចារី*។

III. ផ្គូផ្គងផ្នែក $A$ និង $B$

| A | B | ចម្លើយ |
|---|---|---|
| 1. បណ្តឹងអាជ្ញា<br>2. បណ្តឹងរដ្ឋប្បវេណី<br>3. បណ្តឹងរដ្ឋបាល<br>4. បណ្តឹងតវ៉ា<br>5. បណ្តឹងបរិហារ | ក.បណ្តឹងពីករណីមន្ត្រីពុករលួយ<br>ខ.ទំនាស់រវាងភាគីឯកជន និងរាជការ<br>គ.ប្តឹងពីករណីរំលោភសិទ្ធិ<br>ឃ.ប្តឹងទាមទារជំងឺចិត្តឬថ្លៃខូចខាត<br>ង.ប្តឹងបដិសេធមិនព្រមទទួលសាលក្រម<br>ច.ប្តឹងពីជនល្មើសធ្វើឱ្យខូច សណ្តាប់ធ្នាប់សាធារណៈ | 1. →ង<br>2. →ឃ<br>3. →ក<br>4. →ខ<br>5. →គ<br>6. → |

| A | B | ចម្លើយ |
| --- | --- | --- |
| 1. ពិរុទ្ធជន<br>2.ជនជាប់ ចោទ<br>3.ទណ្ឌិត | ក.ជនដែលតុលាការចេញសាលក្រមផ្តន្ទាទោសរួច<br>ខ.ជនដែលរង់ចាំការកាត់ក្តីពីតុលាការ<br>គ. ជនដែលត្រូវបានព្រះរាជអាជ្ញាផ្តើមធ្វើការចោទប្រកាន់<br>ឃ.ជនដែលតុលាការមិនទាន់ធ្វើការជំនុំជម្រះ | 1. →ខ<br>2. →ឃ<br>3. →ក |

| A | B | ចម្លើយ |
| --- | --- | --- |
| 1. ប្រទេសអភិវឌ្ឍ<br>2.ប្រទេសកំពុងអភិវឌ្ឍ<br>3.ប្រទេសតតិយលោក | ក.ប្រទេសដែលអន់ថយ ផ្នែកសេដ្ឋកិច្ចមិនព្រមធ្វើ ការកែប្រែ<br>ខ.ប្រទេសដែលអន់ថយផ្នែកសេដ្ឋកិច្ចខំប្រឹងប្រែងស្តារលើគ្រប់វិស័យឡើង វិញ<br>គ.ប្រទេសដែលមានខឿនសេដ្ឋកិច្ចរីកលូតលាស់ | 1. →គ<br>2. →ខ<br>3. →ក |

| A | B | ចម្លើយ |
| --- | --- | --- |
| 1. ច្បាប់លោកិយ<br>2. ច្បាប់អមតៈ<br>3. ច្បាប់ធម្មជាតិ | ក.ច្បាប់ដែលគេប្រកាស ឱ្យប្រើប្រាស់ជាអមតៈ<br>ខ.ច្បាប់ដែលគេប្រកាស ឱ្យប្រើក្នុងពេលកំណត់ មួយ<br>គ.ច្បាប់មួយដែលគេប្រកាសឱ្យប្រើតាមពន្លឺនៃវិចារណញ្ញាណ | 1. → ខ<br>2. → ក<br>3. → គ |

**សូមចាំអានកំរងវិញ្ញាសារសីលធម៌-ពលរដ្ឋវិជ្ជា**

# ចប់ដោយបរិបូរណ៍